# ក្រសួងអប់រំយុវជន និងកីឡា

**MINISTRY OF EDUCATION YOUTH AND SPORTS**

# វិទ្យាស្ថាន វ៉ាន់ដា

**VANDA INSTITUTE**

# របាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា
# ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

# កិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា នៃអគ្គនាយកដ្ឋានពន្ធដារ

Agreement on the Avoidance of Double Taxation of the General Department of Taxation

**ជំនាញៈ គណនេយ្យ**

**រៀបរៀងដោយៈ អាន គុន្ធា**

**អត្តលេខ:** MA20/047

**ឆ្នាំសិក្សា ៖ ឆ្នាំ២០២២ - ២០២៤**

ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

វិទ្យាស្ថាន វ៉ាន់ដា

VANDA INSTITUTE

# របាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា
# ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

# កិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា
# នៃអគ្គនាយកដ្ឋានពន្ធដារ

## Agreement on the Avoidance of Double Taxation of the General Department of Taxation

ជំនាញៈ គណនេយ្យ

សាស្ត្រាចារ្យណែនាំ ៖ បណ្ឌិត គង ឱម

បេក្ខបណ្ឌិត យ៉ាក ឌុទ្ធី

ឆ្នាំសិក្សា ៖ ឆ្នាំ២០២២ - ២០២៤

**គណៈកម្មការត្រួតពិនិត្យរបាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា**

**ប្រធានបទ៖ កិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា នៃអគ្គនាយកដ្ឋានពន្ធដារ**

សាស្ត្រាចារ្យណែនាំ

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

សាស្ត្រាចារ្យណែនាំ

បណ្ឌិត កង ឌិម

គណៈកម្មការអភិវឌ្ឍន៍កម្មវិធីសិក្សា និងស្រាវជ្រាវ

ប្រធាន

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

ប្រធានមជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

**នាយកវិទ្យាស្ថាន**

**បណ្ឌិត ហេង វ៉ាន់ដា**

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាញគណនេយ្យ នៅវិទ្យាស្ថាន វ៉ាន់ដា អស់រយៈពេល ២ឆ្នាំសិក្សារួចមក ខ្ញុំបាទបានទទួលនូវចំណេះដឹងជាច្រើន ដែលពាក់ព័ន្ធនឹងមុខវិជ្ជាសវនកម្ម គណនេយ្យ ពន្ធដារ ជាពិសេសយល់ច្បាស់ថាជំនាញពន្ធដារ គឺជាជំនាញមួយដ៏មានសារៈសំខាន់ សម្រាប់តម្រូវការស្ថាប័នទាំងអស់ មិនថាស្ថាប័នរដ្ឋ ស្ថាប័នឯកជន ឬអង្គការក្រៅរដ្ឋាភិបាលឡើយ។ ក្នុងនោះផងដែរដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែស៊ីជម្រៅលើជំនាញរបស់ខ្លួន វិទ្យាស្ថានក៏បានបញ្ចូលមុខវិជ្ជាជាច្រើន ដែលពាក់ព័ន្ធទៅនឹងកម្មវិធីសិក្សាទៅតាមកម្រិត ពីឆ្នាំសិក្សាទីមួយ រហូតដល់ឆ្នាំសិក្សាទីពីរដែលត្រូវបញ្ចប់ការសិក្សា។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែជាយានសម្រាប់ឱ្យនិស្សិតយកទៅប្រើប្រាស់ នៅក្នុងវិស័យការងារបានជាពិសេសនោះ គឺមុខវិជ្ជាពន្ធដារដែលស្ថាប័នត្រូវឱ្យបុគ្គលិកពាក់ព័ន្ធត្រូវមានចំណេះដឹង ដើម្បីរៀបចំនិងកាន់កាប់បញ្ជី និងរបាយការណ៍ឱ្យបានត្រឹមត្រូវ ស្របទៅតាមការណែនាំរបស់អគ្គនាយកដ្ឋានពន្ធដារ ដើម្បីជៀសវាងនូវបញ្ហាផ្សេងៗដែលអាចកើតមានឡើងនិងធ្វើឱ្យមានការរាំងស្ទះដល់ដំណើរការអាជីវកម្មទៅថ្ងៃក្រោយ។ ដោយខ្ញុំបាទយល់ថាចំណេះដឹងខាងពន្ធដារ ជាចំណេះដឹងបន្ថែមមួយទៀតដ៏មានសារៈសំខាន់ សម្រាប់និស្សិតទាំងអស់ធ្វើការសិក្សាស្វែងយល់និងស្របពេលដែលខ្ញុំបាទមានឱកាសបានសរសេររបាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផងនោះ ទើបខ្ញុំបាទសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី **«កិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា(Double Taxation Agreement) នាយកដ្ឋាននីតិកម្មគោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការអន្តរជាតិ នៃអគ្គនាយកដ្ឋានពន្ធដារ»** យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងជារបាយការណ៍ក្នុងគោលបំណងអោយអ្នកអាន និងអ្នកស្រាវជ្រាវក្រោយៗទៀតឱ្យយល់កាន់តែច្បាស់ពីពន្ធ។ ខ្ញុំបាទសង្ឃឹមថា ការរៀបចំរបាយការណ៍ស្រាវជ្រាវនេះ នឹងបានចូលរួមចំណែកក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកដទៃទៀត ដែលមានបំណងលើការសិក្សាពីជំនាញពន្ធដារ។

ជាទីបញ្ចប់ខ្ញុំបាទ សូមមេត្តាខន្តីអភ័យទោសពីសំណាក់សាស្ត្រាចារ្យ រាមច្បង និងមិត្តអ្នកអាន នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនានៅក្នុងរបាយការណ៍ស្រាវជ្រាវនេះ ហើយខ្ញុំបាទរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយៗទៀតមានភាពល្អប្រសើរ។

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី២០ ជំនាញគណនេយ្យនៃវិទ្យាស្ថាន វ៉ាន់ដា

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ៖**

លោកឪពុក និងអ្នកម្ដាយដែលបានផ្ដល់កំណើត ហើយខិតខំបីបាច់ថែរក្សាកូន ព្រមទាំងផ្គត់ផ្គង់ដល់កូនសព្វបែបយ៉ាង ខិតខំលើកទឹកចិត្តកូនក្នុងការសិក្សា តាំងពីកូនចូលរៀនដំបូងរហូតមកដល់ពេលនេះ និងបានបង្រៀនកូនឱ្យចេះស្នេហាជាតិមាតុភូមិកម្ពុជា។

នាយក គណៈគ្រប់គ្រង បុគ្គលិក សាស្ត្រាចារ្យនៃវិទ្យាស្ថាន វ៉ាន់ដាដែលជានិច្ចកាលតែងតែផ្ដល់នូវការលើកទឹកចិត្ត អនុគ្រោះដល់ខ្ញុំបាទរហូត ធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ជាពិសេសសាស្ត្រាចារ្យ **បណ្ឌិត កង ឱម** និងសាស្ត្រាចារ្យ **យ៉ាក ឧុទ្ធី** ដែលលោកបានឆ្លៀតពេលវេលាដ៏មានតម្លៃ ដើម្បីជួយណែនាំដល់ការសរសេររបាយការណ៍របស់ខ្ញុំបាទឱ្យរឹតតែមានភាពល្អប្រសើរ។

ជាទីបញ្ចប់ខ្ញុំបាទ សូមលើកដៃសំពះបួងសួងដល់គុណព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិក្នុងលោក ជួយបីបាច់ថែរក្សាដល់លោកអ្នកមានគុណខាងលើឱ្យជួបតែសេចក្ដីសុខគ្រប់ប្រការកុំបីអាក់ខានឡើយ។

សូមគោរពជូនពរដល់គុណូបការជនទាំងអស់ សូមជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ ដ៏មហាប្រសើរ គឺ៖ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

ខ្ញុំបាទសូមធានាអះអាង និងទទួលខុសត្រូវលើខ្លឹមសារនៅក្នុងរបាយការណ៍ស្រាវជ្រាវនេះថា របាយការណ៍ស្រាវជ្រាវនេះ គឺជាស្នាដៃស្រាវជ្រាវផ្ទាល់របស់ខ្ញុំបាទ ដោយគ្មានពាក់ព័ន្ធជាមួយសារណា ឬរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ចំពោះទិន្នន័យលទ្ធផលនៃការស្រាវជ្រាវដែលមានក្នុងរបាយការណ៍ស្រាវជ្រាវនេះ គឺថ្មីហើយក៏មិនទាន់មានជនណាម្នាក់យកទៅប្រើប្រាស់នៅក្នុងសារណា ឬរបាយការណ៍ស្រាវជ្រាវរបស់គេឡើយ។

ថ្ងៃ.................ខែ................ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

ភ្នំពេញ ថ្ងៃទី..........ខែ............ឆ្នាំ២០២៣

**ហត្ថលេខា**

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

អគ្គនាយកដ្ឋានពន្ធដារដំបូងឡើយមានឈ្មោះថា នាយកដ្ឋានពន្ធដារ បានបង្កើតឡើងក្នុង ឆ្នាំ១៩៥៣ តែត្រូវបានលុបបំបាត់វិញក្នុងរបបប្រល័យពូជសាសន៍ក្នុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ក្រោយរបបប្រល័យពូជសាសន៍ត្រូវបានដួលរលំ នាយកដ្ឋានពន្ធដារបានបង្កើតឡើងវិញក្នុងឆ្នាំ ១៩៨០ បន្ទាប់មកនាយកដ្ឋានពន្ធដារបានដំឡើងឈ្មោះទៅជាអគ្គនាយកដ្ឋានពន្ធដារក្នុងឆ្នាំ២០០៨ រហូតមកដល់បច្ចុប្បន្ន ស្ថិតក្រោមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

បន្ទាប់ពីទទួលបាននូវតារាងខាងលើ ដែលបង្ហាញពីចំណូលពន្ធរយៈពេលដប់ឆ្នាំបន្តបន្ទាប់ គ្នាមកយើងសង្កេតឃើញថា ចំណូលពន្ធ គឺមានការកើនឡើងជាលំដាប់រៀងរាល់ឆ្នាំ។ ដោយជា មធ្យមមានកំណើនប្រមាណ ២២.៣៥% ក្នុងមួយឆ្នាំ ដែលក្នុងនោះឃើញថាក្នុងឆ្នាំ២០០៧សម្រេចបាន កំណើនច្រើនជាងគេ ដែលកើនដល់ទៅ ៤២.១៤% ឯឆ្នាំ២០០៩ កើនបានត្រឹមតែ ០.៥១% ប៉ុណ្ណោះ ដោយសារការរងផលប៉ះពាល់ពីវិបត្តិសេដ្ឋកិច្ចក្នុងឆ្នាំ២០០៨។

តាមការពិតការបង់ពន្ធ វាគឺជាការចូលរួមចំណែកក្នុងថវិកាជាតិ ដើម្បីឱ្យរដ្ឋមានលុយយក ទៅចំណាយដោយមិនចាំបាច់បោះពុម្ពលុយ ដែលអាចបង្កឱ្យមានបញ្ហាអតិផរណា។ សម្រាប់កម្ពុជា ការបង្កើនចំណូលពីការបង់ពន្ធ គឺជាគន្លឹះដ៏សំខាន់មួយ ដើម្បីឈានទៅបញ្ឈប់កពឹងផ្អែកលើជំនួយពីបរទេស។ សម្រាប់អ្នកបង់ពន្ធ ថ្វីដ្បិតតែពន្ធនេះមិនមានការកំណត់អំពីសេវាណាមួយជាថ្នូរមកវិញ ជាក់លាក់ក៏ពិតមែន ក៏ប៉ុន្តែគេអាចទទួលបានផលប្រយោជន៍ជាច្រើន ដោយផ្ទាល់ ឬដោយ ប្រយោល ពីការបង់ពន្ធនេះ ពីព្រោះថា លុយដែលបានពីការបង់ពន្ធនេះនឹងត្រូវយកទៅចំណាយទៅ លើការបើកប្រាក់បៀវត្សដល់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ដែលជាអ្នកទទួលបន្ទុក ផ្តល់សេវារដ្ឋបាល ការពារសន្តិសុខ សណ្តាប់ធ្នាប់ និងការពារអធិបតេយ្យភាព និងបូរណភាពទឹកដីរបស់ ប្រទេស។

# មាតិកា

ទំព័រ

អារម្ភកថា ............ i
សេចក្តីថ្លែងអំណរគុណ ............ ii
អំណះអំណាង ............ iii
សេចក្តីសង្ខេបនៃការស្រាវជ្រាវ ............ iv

**ជំពូកទី១: សេចក្តីផ្តើម**

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ............ ១
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ............ ១
១.៣ គោលបំណងនៃការស្រាវជ្រាវ ............ ២
១.៤ ទំហំ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ............ ២
  ១.៤.១ ដែនកំណត់នៃការស្រាវជ្រាវ ............ ២
  ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ ............ ២
១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ ............ ៣
១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ............ ៣
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ............ ៣

**ជំពូកទី២: រំលឹកទ្រឹស្តី**

២.១ លក្ខណៈទូទៅនៃពន្ធ ............ ៥
  ២.១.១ និយមន័យពន្ធ ............ ៥
  ២.១.២ ប្រវត្តិពន្ធ ............ ៦
  ២.១.៣ ប្រភេទពន្ធ ............ ៧
២.២ ការបង្កើតឱ្យមានកិច្ចព្រមព្រៀងស្តីពីការជៀសវាងការយកពន្ធត្រួតគ្នា ............ ៨
  ២.២.១ និយមន័យកិច្ចព្រមព្រៀងស្តីពីការជៀសវាងការយកពន្ធត្រួតគ្នា ............ ៨
  ២.២.២ ប្រវត្តិនៃកិច្ចព្រមព្រៀងស្តីពីការជៀសវាងការយកពន្ធត្រួតគ្នារបស់កម្ពុជា ............ ៨
  ២.២.៣ លក្ខណៈទូទៅនៃកិច្ចព្រមព្រៀងស្តីពីការយកពន្ធត្រួតគ្នា ............ ៩
២.៣ នីតិវិធីក្នុងការអនុវត្តលើកិច្ចព្រមព្រៀងស្តីពីការយកពន្ធត្រួតគ្នា ............ ១០
  ២.៣.១ និយមន័យនីតិ ............ ១០
  ២.៣.២ ប្រវត្តិនៃនីតិ ............ ១០
  ២.៣.៣ ប្រភពនៃនីតិ ............ ១០
  ២.៣.៤ តួនាទីនៃនីតិ ............ ១១

**ជំពូកទី៣: លទ្ធផលនៃការស្រាវជ្រាវ**

៣.១ ស្ថានភាពទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ. ............ ១៣

៣.១.១ ប្រវត្តិរបស់អគ្គនាយកដ្ឋានពន្ធដារ ...... ១៣
៣.១.២ គោលនយោបាយ ...... ១៤
៣.១.៣ បេសកកម្ម និងទស្សនវិស័យរបស់អគ្គនាយកដ្ឋានពន្ធដារ ...... ១៤
៣.១.៤ តួនាទី និងកាតព្វកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ ...... ១៥
៣.២ ការបង្កើតកិច្ចព្រមព្រៀងស្តីពីការចៀសវាងយកពន្ធត្រួតគ្នា ...... ១៦
៣.២.១ ការបង្កើតឱ្យមានកិច្ចព្រមព្រៀង ...... ១៦
៣.២.២ ចំណូលពន្ធដារ ...... ១៦
៣.២.៣ ចំណូលតាមប្រភេទពន្ធ ...... ២១
៣.២.៤ ចំណូលពន្ធតាមប្រភេទអ្នកជាប់ពន្ធ ...... ២២
៣.៣ នីតីវិធីក្នុងការអនុវត្តលើកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការយកពន្ធត្រួតគ្នា ...... ២៣
៣.៣.១ នីតិវិធីនៃការអនុវត្តន៍( DTA ) ...... ២៣
៣.៣.២ ក្របខ័ណ្ឌគោលនយោបាយ និងគោលការណ៍ចម្បងៗសម្រាប់ការចរចា ...... ២៥
៣.៣.២.១ ពន្ធកាត់ទុកនៅក្នុងមាត្រា១០ស្តីពីភាគលាភ មាត្រា១១ស្តីពីការប្រាក់ និងមាត្រា១២ស្តីពី សួសសារ ...... ២៦
៣.៣.២.២ ការដាក់បញ្ចូលបញ្ញត្តិស្តីពីករណីលើកលែងពិសេសដល់ភាគីដែលប្រទេសកំពុងអភិវឌ្ឍន៍(Tax Sparing Credit) ...... ៣៩
៣.៣.២.៣ មាត្រា១៣ស្តីពីសេវាបច្ចេកទេស ...... ២៧
៣.៣.២.៤ ការផ្លាស់ប្តូរព័ត៌មានគ្នាទៅវិញទៅមក ( Exchange of information ) ...... ២៧
៣.៣.២.៥ បច្ចុប្បន្នភាពកិច្ចព្រមព្រៀង ...... ២៧
៣.៣.៣ កិច្ចព្រមព្រៀងស្តីពីការចៀសវាងយកពន្ធត្រួតគ្នាដែលបានចូលរួមជាធរមាននិងមានប្រសិទ្ធភាពអនុវត្ត ...... ២៨
៣.៣.៤ កិច្ចព្រមព្រៀមទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នាដែលបានបញ្ចប់ និងចុះហត្ថលេខារវាងកម្ពុជា-កូរ៉េខាងត្បូង ...... ៣៧

**ជំពូកទី៤: ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ**

៤.១ ការវិភាគលើចំណុចខ្លាំង ...... ៤១
៤.២ ការវិភាគលើចំណុចខ្សោយ ...... ៤២

**ជំពូកទី៥: សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍**

៥.១ សេចក្តីសន្និដ្ឋាន ...... ៤៣
៥.២ ការផ្តល់អនុសាសន៍ ...... ៤៤
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលកំពុងមានការអភិវឌ្ឍដែលមានប្រជាជន ១៧លាននាក់ គ្រប់គ្រងដោយរបបប្រជាធិបតេយ្យសេរីពហុបក្ស។ ជាមួយគ្នាផងដែរប្រទេសកម្ពុជាប្រកពចំណូលមកពីវិស័យជាច្រើន មានដូចជាវិស័យកសិកម្ម វិស័យឧស្សាហកម្មនឹងវិស័យទេសចរណ៍ដែលវិស័យទាំងនេះជាវិស័យចម្បងក្នុងការលើកកម្ពស់សេដ្ឋកិច្ចឱ្យមានការរីកចម្រើន។ ជាមួយនឹងគ្នាផងដែរ ប្រទេសកម្ពុជាមានការរីកចម្រើនដូចពេលបច្ចុប្បន្ន ដោយមានគោលនយោបាយពីរ ដែលធ្វើប្រតិបត្តិការទន្ទឹមគ្នា គឺគោលនយោបាយសារពើពន្ធ និងគោលនយោបាយរូបិយវត្ថុ។

ដាក់ស្តែងគោលនយោបាយសាពើពន្ធ និងគោលនយោបាយមួយប្រភេទដែលបង្កើតឡើង និងគ្រប់គ្រងដោយអគ្គនាយកដ្ឋានពន្ធដារ ក្នុងគោលបំណងតាមដានចំណូល ចំណាយរបស់រាជរដ្ឋាភិបាលតាមរយៈការប្រមូលពន្ធពីប្រជាពលរដ្ឋ សហគ្រាស ឬក្រុមហ៊ុនជាដើម។ ការប្រមូលពន្ធទាំងនេះ មានពន្ធទៅលើប្រាក់ចំណូល ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ពន្ធអប្បរមា ពន្ធកាត់ទុក ពន្ធលើប្រាក់បៀវត្ស អាករលើតម្លៃបន្ថែម អាករលើទំនិញនិងសេវាមួយចំនួន ពន្ធទៅលើផលរបរ ពន្ធលើឈ្នួលផ្ទះ ពន្ធតែម ពន្ធប៉ាតង់ ពន្ធប្រថាបត្រា ពន្ធដីធ្លីមិនបានប្រើប្រាស់ ពន្ធសត្វសត្តឃាត ពន្ធលើមធ្យាបាយដឹកជញ្ជូន និងយាន្តជំនិះគ្រប់ប្រភេទ អាករស្នាក់នៅ អាករបំភ្លឺសារណៈ និងពន្ធអចលនទ្រព្យ។ ម្យ៉ាងទៀតពន្ធដារ ក៏មានតួនាទីយ៉ាងសំខាន់ផងដែរ ក្នុងការបង្កើនថវិកាជាតិ សម្រាប់ជានាឱ្យបាននៅសេចក្តីត្រូវការ និងចំណាយសាធារណៈដែលតែងតែកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំទៀត។ ថ្វីត្បិតតែការគណនា និងការប្រមូលពន្ធគឺជាការងារស្នូល តែការប្រមូលចំណូលពន្ធមិនអាចប្រមូលបានដោយគ្រាន់តែមានច្បាប់ពន្ធដារតែប៉ុណ្ណោះទេ គឺអ្នកជាប់ពន្ធក៏ត្រូវរួមចំណែកយល់ដឹង ពីសារៈសំខាន់នៃពន្ធដារ ព្រមទាំងយល់ច្បាប់ពន្ធដារ ហើយរាយការណ៍ និងបង់ពន្ធជូនរដ្ឋដោយសោះត្រង់នោះរដ្ឋអាចទទួលយកប្រាក់ចំណូលបានយ៉ាងពេញលេញ។

ដោយឈរលើហេតុផលខាងលើនេះហើយ ទើបខ្ញុំបាទបានសម្រេចចិត្តជ្រើសរើសយកប្រធានបទ" **កិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា(DTA) របស់អគ្គនាយកដ្ឋានពន្ធដារកម្ពុជា**" យកមកស្រាវជ្រាវ និងចងក្រងរបាយការណ៍បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយការអនុវត្តរបបស្វ័យប្រកាសនាំអោយមានការគេចវេសពន្ធ ការបន្លំពន្ធ ការមិនព្រមបង់ពន្ធចូលថវិការដ្ឋពីអ្នកជាប់ពន្ធ ដោយសារតែមានការប្រកាសពន្ធគឺស្ថិតទៅលើអ្នកជាប់ពន្ធហេតុដូច្នេះហើយទើបអគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវច្បាប់ ការប្រមូលពន្ធត្រួតគ្នាចំពោះក្រុមហ៊ុនណាដែលមានសកម្មភាពអាជីវកម្មក្នុងស្រុក និងអន្តរជាតិ។ ដើម្បីសម្រេចបានទៅតាមផែនការថវិកាជាតិ អគ្គនាយកដ្ឋានពន្ធដារបានធ្វើការកែទម្រង់យុទ្ធសាស្ត្រដែលស្របតាមសម័យកាលនគរូបនីយកម្ម ដើម្បីផ្តល់ជាសេវាដល់អ្នកជាប់ពន្ធឱ្យកាន់តែមានប្រសិទ្ធិភាពដូចជា ការផ្តល់ព័ត៌មាន អប់រំ ពន្យល់ណែនាំ ដើម្បីឱ្យជាប់ពន្ធប្រតិបត្តិ និងការអនុវត្តត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារដល់អ្នកជាប់ពន្ធកាន់តែយល់ច្បាស់ចៀសវាងការគេចវេស

ពីកាតព្វកិច្ចសារពើពន្ធដែលធ្វើឱ្យបាត់បង់ចំណូលពន្ធ ហេតុដូចនេះការធ្វើកំណែទម្រង់ច្បាប់ស្តីពីការកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា គឺជាចំណុចសំខាន់មួយដើម្បីយល់ដឹងពីច្បាប់ស្តីពីពន្ធដារឱ្យកាន់តែមានភាពប្រសើរឡើង។

១-ហេតុអ្វីបានជា អគ្គនាយកដ្ឋានពន្ធដារ បង្កើតឱ្យមានកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា?

២-តើអគ្គនាយកដ្ឋានពន្ធដារ មាននីតិវិធីដូចម្តេចក្នុងការអនុវត្តលើកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវ គឺបង្ហាញពីការយល់ដឹងពីកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នារវាងប្រទេសឬដែនដីពីរ ដើម្បីចៀសវាងការយកពន្ធត្រួតគ្នា។ គោលបំណងចម្បងនៃកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា គឺផ្តល់ភាពច្បាស់លាស់លើការកំណត់ពន្ធក្នុងប្រទេស ឬដែនដីប្រភព (Sour Jurisdiction) ដែលមានសកម្មភាពបង្កើនចំណូលជាក់ស្តែង ឬការទូទាត់កើតឡើង។

ប៉ុន្តែជារួម កិច្ចព្រមព្រៀងទ្វេភាគីស្តីការចៀសវាងការយកពន្ធត្រួតគ្នាផ្តល់នៅអត្ថប្រយោជន៍ជាច្រើនដែលជាការប៉ះប៉ូវវិញដល់ប្រទេសជាហត្ថលេខីដូចជា ៖

១-ការទាក់ទាញនិងជំរុញការវិនិយោគនិងពាណិជ្ជកម្មអន្តរជាតិ ដែលមានផ្តល់នូវភាពច្បាស់លាស់តម្លាភាព និងគ្មានការរើសអើងក្នុងវិស័យពន្ធដារ។

២-កំណើនមូលដ្ឋានពន្ធ។

៣- រំហូរមូលធន ដោយការទាក់ទាញនៃអត្រាពន្ធកាត់ទុកលើការប្រាក់ និងភាពលាភ។

៤- ការផ្ទេរបច្ចេកវិទ្យានិងជំនាញពីបរទេស តាមរយៈបទប្បញ្ញត្តិស្តីពីសេវាបច្ចេកទេសនិងសួយសារ។

៥- ការការពារនៅវាសនជនកម្ពុជាដែលជាវិនិយោគិននៅបរទេស។

៦- ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងវិស័យពន្ធដារ ជាពិសេសការទប់ស្កាត់និងការបង្រ្កបការកិបកេងបន្លំពន្ធតាមរយៈការផ្លាស់ប្តូរពត៍មានរបស់អ្នកជាប់ពន្ធ។

## ១.៤ ទំហំ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាទៅលើកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា គឺផ្តោតទៅលើកិច្ចសហការណ៍របស់ប្រទេសកម្ពុជា ជាមួយរដ្ឋភាគីនៃកិច្ចព្រមព្រៀង។

### ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ

និយាយពីប្រធានបទដែលបានលើកយកមកសិក្សា គឺផ្តោតទៅសំខាន់ៗដូចជា៖

- បុគ្គលនិវាសនជននៃរដ្ឋភាគីម្ខាង ឬរដ្ឋទាំងពីរ

- ពន្ធ(សម្រាប់កម្ពុជា) ពន្ធទៅលើប្រាក់ចំណូល រួមបញ្ចូលទាំងពន្ធកាត់ទុក, ពន្ធលើឈ្នួលផ្ទះ និងដី, ពន្ធលើប្រាក់បៀវត្ស...

- កិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា(DTA)ការត្រូវអនុវត្តផងដែរចំពោះប្រភេទពន្ធណាដែលមានចរិតលក្ខណៈដូចគ្នាសុទ្ធសាធឬប្រហាក់ប្រហែលគ្នា ដែលបានដាក់ឱ្យអនុវត្តក្រោយកាលបរិច្ឆេទនិងការចុះហត្ថលេខាលើ កិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា(DTA) ដោយបន្ថែម ឬជំនួយឱ្យប្រភេទពន្ធជាធរមាន ។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីឱ្យការស្រាវជ្រាវសម្រេចទៅបានប្រកបដោយជោគជ័យ ការប្រមូលទិន្នន័យតាមវិធីសាស្ត្របន្ទាប់បន្សំ (Secondary Data)។ ការស្រាវជ្រាវមិនត្រឹមតែផ្តល់ផលប្រយោជន៍ជាច្រើនដល់អ្នកស្រាវជ្រាវផ្ទាល់នោះទេវាថែមទាំងផលប្រយោជន៍ដល់សាធារណៈជនទូទៅ ក៏ដូចជាសង្គមជាតិទាំងមូលផងដែរ។ ដើម្បីឱ្យការស្រាវជ្រាវនេះទទួលបានផ្លែផ្កាគួរជាទីពេញចិត្ត និងផ្តល់ផលប្រយោជន៍តាមវិធីសាស្ត្រខាងលើនេះគឺតម្រូវឱ្យមានទិន្នន័យមួយចំនួនដូចជា៖

- តាមគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ
- ច្បាប់ស្តីពីសារពើពន្ធ
- ការសាកសួរជាមួយមន្ត្រីដែលពាក់ព័ន្ធ និងទំនាក់ទំនងទៅសេវាបម្រើអ្នកជាប់ពន្ធ(Call Center 1277)
- ស្រាវជ្រាវតាមរយៈបណ្ណាល័យនៃវិទ្យាស្ថានវ៉ាន់ដារ
- តាមរយៈFace Book Page អគ្គនាយកដ្ឋានពន្ធដារ
- និងឯកសារផ្សេងៗនៅអគ្គនាយកដ្ឋានពន្ធដារ និងសាលាជាតិពន្ធដារ...។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ផលប្រយោជន៍ការសិក្សា មានដូចជា៖

- លុបបំបាត់ការយកពន្ធត្រួតគ្នា
- លុបបំបាត់ ឬកាត់បន្ថយពន្ធមួយចំនួនដែលនឹងត្រូវបង់ដោយវិនិយោគិនបរទេស
- លុបបំបាត់ការរើសអើងពន្ធ
- ផ្តល់វិធានច្បាស់លាស់លើការកំណត់សិទ្ធវាងរដ្ឋភាគីនៃកិច្ចព្រមព្រៀង

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវត្រូវចែកចេញជា ៥ ជំពូកដូចខាងក្រោម៖

ជំពូកទី១ ៖ សេចក្តីផ្តើម ត្រូវបង្ហាញពីលំនាំនៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ និងវិធីសាស្ត្រស្រាវជ្រាវ។

ជំពូកទី២ ៖ រំលឹកទ្រឹស្តី និយមន័យ ពន្ធ ទ្រឹស្តីដែលពាក់ព័ន្ធផ្សេងៗ ទស្សនទានផ្សេងៗពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងស្តីពីការចៀសវាការយកពន្ធត្រួតគ្នា(DTA)។

ជំពូកទី៣ ៖ លទ្ធផលនៃការស្រាវជ្រាវ លើកឡើងពីស្ថានភាពរបស់អគ្គនាយកដ្ឋានពន្ធដារ នឹងគោលនយោបាយស្តីពីនីតិវិធីរបស់អគ្គនាយកដ្ឋានពន្ធដារ ក្នុងការសហការណ៍រវាងរដ្ឋភាគីនៃកិច្ចព្រមព្រៀង ។

ជំពូកទី៤ ៖ ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ វិភាគទៅលើចំណុចខ្លាំងកិច្ចព្រមព្រៀងស្តីពីការចៀសវាការយកពន្ធត្រួតគ្នា(DTA) និងចំណុចខ្សោយកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា (DTA) ។

ជំពូកទី៥ ៖ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍ៈ ធ្វើការសិន្និដ្ឋានទៅលើគ្រប់ចំណុចទាំងអស់ និងផ្តល់ជាយោបល់អនុសាសន៍ទៅលើចំណុចដែលត្រូវកែលម្អ។

# ជំពូកទី២
# កិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា

## ២.១ លក្ខណៈទូទៅនៃពន្ធ

### ២.១.១ និយមន័យពន្ធ

ពន្ធ គឺជាបន្ទុកអ្នកជាប់ពន្ធចំពោះរដ្ឋ និងកាតព្វកិច្ចរបស់សមាភាពដែលកំណត់ដោយច្បាប់ ។ យោងតាមច្បាប់ស្តីពីពន្ធដារឆ្នាំ១៩៩៧ ពន្ធសំដៅដល់ផ្ទាល់ ដែលជាប្រភេទពន្ធប្រមូលយកដោយផ្ទាល់ពីអ្នកជាប់ពន្ធ(Taxpayer)ក្រៅពីពន្ធគយ ឬអាករដែលសំដៅដល់ពន្ធប្រយោលដែលជាប្រភេទនៃការប្រមូលពន្ធ ដោយប្រយោល( មិនបានប្រមូលដោយផ្ទាល់ពីអ្នកជាប់ពន្ធ ) ។ ការប្រមូលពន្ធនេះ គឺយកតាមតម្លៃ ទំនិញសេវា ហើយអ្នកជាប់ពន្ធគឺជាអ្នកប្រើប្រាស់ចុងក្រោយ[1] ។

ពន្ធ គឺជាប្រាក់ដែលយើងប្រមូលក្នុងនាមរដ្ឋាភិបាល[2]។

ពន្ធ គឺជានៃការបែងចែកឡើងវិញ នូវចំណូលជាតិដែលរដ្ឋាភិបាលបានប្រើប្រាស់ ដើម្បីប្រមូលចំណូល មួយផ្នែកពីគ្រប់សមាភាពសេដ្ឋកិច្ច មានដូចជាក្រុមហ៊ុន សហគ្រាស អាជីវកម្ម និងប្រជាពលរដ្ឋដើម្បីបម្រើឱ្យតម្រូវការរួមរបស់សង្គមជាតិទាំងមូល[3]។

ពន្ធ គឺជារូបធាតុនៃការប្រមូលចំណូល ដែលផ្សាភ្ជាប់ជាមួយនឹងសិទ្ធិអំណាច នយោបាយរដ្ឋាភិបាលដែលក្រិត្យច្បាប់ជាកំណត់ [4]។

ពន្ធ គឺជាការបង់វិភាគទាន នូវការព្វកិច្ចរបស់គ្រប់សមាសភាពសេដ្ឋកិច្ច ដែលរួមទាំងរូបវន្តបុគ្គល និងនីតិបុគ្គល ជូនរាជរដ្ឋាភិបាលដែលមានច្បាប់កំណត់[5]។

ពន្ធ គឺជាចំណូលចរន្តដ៏សំខាន់របស់រាជរដ្ឋាភិបាល សម្រាប់ធ្វើការទ្រទ្រង់នូវដំណើរការវិស័យសាធារណៈផ្សេងៗ[6]។

ពន្ធ មានលក្ខណៈបង្ខំហើយមិនសងឱ្យវិញផ្ទាល់ឡើយ ប៉ុន្តែនិងអាចសងឱ្យវិញជាលក្ខណៈ រូបភាពប្រយោលទៅតាមគោលនយោបាយប្រទេសនីមួយៗ។ គ្រប់អង្គភាពអាជីវកម្ម សេវាកម្មដែល ចំណុះឱ្យគ្រប់សមាសភាពសេដ្ឋកិច្ចត្រូវមានកាតព្វកិច្ចនិងទំនួលខុសត្រូវ ចំពោះមុខច្បាប់ក្នុងការអនុវត្តឱ្យបានគ្រប់គ្រាន់ក្នុងខ្ទង់ពន្ធទាំងឡាយដែលបានកំណត់និងមានសិទ្ធិស្មើៗគ្នា ក្នុងការទទួលមកវិញ នូវផលប្រយោជន៍ពីរដ្ឋាភិបាលដែលប្រកបដោយយុត្តិធម៌ព្រមទាំងមានភាពងាយស្រួល[7]។

ពន្ធ បានធ្វើឱ្យមានការផ្លាស់ប្តូរកម្មសិទ្ធិនៃប្រភពចំណូលដែលបានប្រមូល។ ផ្លាស់ប្តូរកម្ម សិទ្ធិនៃប្រភពចំណូលនេះបានកំណត់ដោយមុខងារគ្រប់គ្រងសេដ្ឋកិច្ចរបស់រដ្ឋាភិបាល ហើយបាន ស្តែងឡើងនៅឯក

---

[1] https;//www.bizkhmer.com/articles/41290 (10, December,2023)

[2] https;//www.ato.gov.au/General/Other-languages/In-detail/Khmer/Tax-and-super-in-Australia---what-you-need-to-know---Khmer/?page=2(10, December,2023)

[3] ដូចលេខ២

[4] *វិទ្យាស្ថានវ៉ាន់ដា: របាយការណ៍ស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី១៨ ទំព័រទី៤ របស់និស្សិតឈ្មោះ វ៉ែន វដ្ឋា*

[5] ដូចលេខ៤

[6] ដូចលេខ៤

[7] ដូចលេខ៤

ភាពគ្នាអំពីគោលចរិតផលប្រយោជន៍របស់រដ្ឋជាមួយនិងផលប្រយោជន៍របស់ ក្រុមហ៊ុនសេវាកម្ម និងប្រជាជនគ្រប់រូប។ នៅក្នុងល្បឿនសេដ្ឋកិច្ចទីផ្សារ ដែលសមាសភាពសេដ្ឋកិច្ច ច្រើនគោលនយោបាយពន្ធដារត្រូវយកមកប្រើប្រាស់ជាចំបាច់ ជាទូទៅពន្ធដារបានចាត់ទុកជា ឧបករណ៍ហិរញ្ញវត្ថុយ៉ាងមានប្រសិទ្ធភាព នៅក្នុងការគ្រប់គ្រងសេដ្ឋកិច្ចហិរញ្ញវត្ថុរបស់រដ្ឋាភិបាល ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសជាតិ[8]។

**២.១.២ ប្រវត្តិពន្ធ**

ប្រព័ន្ធពន្ធដារត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៥៣ បន្ទាប់មកប្រព័ន្ធពន្ធដារត្រូវបានលុប បំបាត់ចោលនៅក្នុងឆ្នាំ១៩៧៥-១៩៧៩ ដោយសារសង្គ្រាម(របបខ្មែរក្រហមនិងរបបប៉ុលពត) ហើយ បានធ្វើឱ្យប្រជាជនស្លាប់អស់ជាច្រើននាក់។ ប្រព័ន្ធពន្ធដារបានបង្កើតឡើងវិញនូវដំណាក់កាល ដំបូងនៅឆ្នាំ១៩៨០ ដោយបានអនុវត្តន៍នៅរាជធានីភ្នំពេញ និងខេត្តចំនួន១០ផ្សេងទៀត។ លើសពី នេះទៅទៀតអគ្គនាយកដ្ឋានពន្ធដារបានបង្កើតពន្ធមួយចំនួនផ្សេងទៀត ដើម្បីយកមកអនុវត្តន៍ និង មានការបែងចែកច្បាប់ និងមាត្រាយ៉ាងច្បាស់លាស់។ ផ្អែកទៅលើមាត្រា៤ នៃច្បាប់សារពើពន្ធ បានបង្កើតឡើងនូវការកំណត់របបពន្ធជាបីប្រភេទ៖ គឺរបបពិត របបម៉ៅការ និងរបបបំព្រួញ ក៏ប៉ុន្តែ បទប្បញ្ញត្តិស្តីពីរបបបំព្រួញមានចែងក្នុងក្រដាសមួយដាច់ដោយឡែក។ ដែលជាវិធាន និងជានីតិវិធី ដើម្បីចាត់បញ្ចូលអ្នកជាប់ពន្ធឱ្យស្ថិតនៅក្នុងរបបកំណត់ណាមួយនោះ ត្រូវកំណត់ដោយផ្អែកទៅលើ ទ្រង់ទ្រាយអាជីវកម្ម និងកម្រិតផលរបរ។ ប៉ុន្តែនៅពេលបច្ចុប្បន្ននេះក្នុងប្រទេសកម្ពុជាយើងមានតែ របបពិត(ស្វ័យប្រកាស) តែមួយប៉ុណ្ណោះ។

ការអនុវត្ត និងការកំណត់នៃរបបពិតរបស់សហគ្រាសដោយផ្អែកទៅលើទ្រង់ទ្រាយគតិយុត្តិ នៃកម្រិតផលរបរប្រចាំឆ្នាំ និងប្រភេទសកម្មភាពអាជីវកម្ម[9]។

ទ្រង់ទ្រាយគតិយុត្តិមានន័យថា រាល់សហគ្រាសដែលមិនមែនជាសហគ្រាសឯកបុគ្គលគឺ ត្រូវជាប់ពន្ធរបបពិត ទោះបីសហគ្រាសនោះមានសកម្មភាពអាជីកម្មប្រភេទអ្វី ឬមានកម្រិតផលរបរ ប្រចាំឆ្នាំប៉ុន្មានក៏ដោយ។ សហគ្រាសទាំងនោះមានដូចជាសហគ្រាសចម្រុះ ក្រុមហ៊ុនឯកជន សមូហភាពសាធារណៈ ឬអង្គការឯកជនដែលធ្វើសកម្មភាពក្នុងលក្ខខណ្ឌប្រាក់ចំណេញ ឬប្រាក់ចំណូល ដែលជាបេតិកភ័ណ្ឌរបស់ខ្លួន។ កម្រិតផលរបរប្រចាំឆ្នាំ គឺជាការកំណត់ពន្ធលើប្រាក់ចំណេញតាមរបបពិតដែលត្រូវអនុវត្តន៍ ហើយចំពោះសហគ្រាសដែលមានផលរបរប្រចាំឆ្នាំចាប់ពី៥០០លានរៀនឡើងទៅ។ ផ្គត់ផ្គង់ចម្រុះដែលមានរបរប្រចាំឆ្នាំចាប់ពី ២៥០ លានរៀលឡើងទៅ។

រាល់សហគ្រាសដែលធ្វើការដេញថ្លៃ ប្រសិនបើសហគ្រាសទាំងនោះបានទទួលសញ្ញាធ្វើ ឬ ក៏ជាការផ្គត់ផ្គង់របស់អង្គការសាធារណៈដែលមានចំនួនទឹកប្រាក់ប្រចាំឆ្នាំសរុប ១២៤លានរៀន សកម្មភាពសេវាកម្មដូចជា សណ្ឋាគារ កន្លែងម៉ាស្សា រង្គសាល ភោជនីយដ្ឋាន កន្លែងកម្សាន្តនានា ដែលចាត់ថ្នាក់ជាគ្រឹះស្ថានធើតសកម្មភាពអណ្តូងរ៉ែនិងអាជីវកម្មនេសាទ[10]។

---

[8] រៀបរៀងដោយសាស្ត្រាចារ្យ វ៉ែន ឈុនហួត

[9] *ដកស្រង់ពីបណ្ណាល័យវិទ្យាស្ថានវ៉ាន់ដាៈ របាយការណ៍ស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី១៩ ទំព័រទី៥ របស់និស្សិតឈ្មោះ ជួន សៅវណ្ណា*

[10] ដូចទី៩

ដើម្បីថែរក្សាផលប្រយោជន៍សាធារណៈទាំងអស់ ចាំបាច់ត្រូវទាមទារឱ្យមានការចូលរួមពី សំណាក់មហាជន។ តាមការស្រាវជ្រាវ ការកកើតពន្ធ ឬទ្រឹស្តីទាក់ទងនឹងពន្ធ ត្រូវបានគេរកឃើញ ថា បានកើតឡើងស្របជាមួយនឹងការកកើតឡើងនៃការប្រមូលផ្តុំគ្រប់គ្រងដំបូង និងនៅពេលដែល មានការកើតចេញឡើង នូវទម្រង់អង្គការចាត់តាំងនៃសង្គមមនុស្ស។ Evolution នៃសង្គមមនុស្សជា ហេតុផលដែលបង្ហាញពីភាពងាយស្រួលនៃការប្រមូលពន្ធ ដែលស្ថិតនៅលើរបត់មួយដ៏យូរលង់ ត្រូវបានឆ្លោះមករកភាពសាំញ៉ាំ និងពិបាកមកដល់បច្ចុប្បន្ននេះ[11]។

សហគ្រាសគ្រាសទាំងនោះមានដូចជាសហគ្រាសចម្រុះ ក្រុមហ៊ុនឯកជន សមូហភាពសារជារណៈ ឬអង្គការឯកជន ដែលមានសកម្មភាពក្នុងលក្ខខណ្ឌប្រាក់ចំណេញ ឬប្រាក់ចំណូលដែលជាបេតិភ័ណ្ឌរបស់ខ្លួន ។

កម្រិតផលរបបប្រចាំឆ្នាំ គឺជាការកំណត់ពន្ធទៅលើប្រាក់ចំណូលតាមរបបពិតដែលត្រូវអនុវត្តន៍ ហើយចំពោះសហគ្រាសដែលមានផលរបបប្រចាំឆ្នាំចាប់២៥០លានរៀលឡើងទៅ។

ប្រភេទអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសមានបីប្រភេទ៖

- ប្រភេទអ្នកជាប់ពន្ធតូច
- ប្រភេទអ្នកជាប់ពន្ធមធ្យម
- ប្រភេទអ្នកជាប់ពន្ធធំ

### ២.១.៣ ប្រភេទពន្ធ

ពន្ធ គឺជាចំណូលចរន្តដ៏សំខាន់របស់រដ្ឋ សម្រាប់ធ្វើការទ្រទ្រង់នូវដំណើរការវិស័យសាធារណៈផ្សេងៗ។ នៅកម្ពុជាបានកំណត់នូវច្បាប់ពន្ធចំនួន១៨ ប្រភេទ ដែលអាចឱ្យប្រជាពលរដ្ឋ ឬអ្នកជាប់ពន្ធាំទាំងត្រូវធ្វើការបង់ជូនរដ្ឋ។ ប្រភេទពន្ធទាំងរួមមាន៖

- ពន្ធលើប្រាក់ចំណូល
- ពន្ធលើប្រាក់បៀវត្ស
- ពន្ធលើប៉ាតង់
- ពន្ធលើប្រថាប់ត្រា
- ពន្ធលើដីធ្លីមិនបានប្រើប្រាស់
- ពន្ធលើអចលនទ្រព្យ
- ពន្ធលើឈ្នួលផ្ទះនិងដី
- ពន្ធលើតែមប្រ៍
- ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ
- ពន្ធលើសត្តឃាត
- ពន្ធលើចំណេញមូលធន
- ពន្ធលើរំដោះលើប្រាក់ចំណូល

[11] ស៊ីម សូលីន : Master of Business Administration (13.January.2024)

- ពន្ធអប្បបរមា
- ពន្ធកាត់ទុក
- អាករលើតម្លៃបន្ថែម
- អាករពិសេសលើទំនិញ និងលើសេវាកម្មមួយចំនួន
- អាករស្នាក់នៅ
- អាករបំភ្លឺសាធារណៈ[12]។

## ២.២ ការបង្កើតឱ្យមានកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា

### ២.២.១ និយមន័យកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា

កិច្ចព្រមព្រៀងស្តីពីការចៀសវាងយកពន្ធត្រួតគ្នា គឺដើម្បីលុបបំបាត់ការយកពន្ធទ្វេដងនៃប្រាក់ចំណូលដែលកើតឡើងនៅក្នុងទឹកដីមួយ និងបានបង់ទៅឱ្យអ្នកជាប់ពន្ធនៃតំបន់មួយទៀត សម្រាប់ កិច្ចព្រមព្រៀងស្តីពីការចៀសវាងយកពន្ធត្រួតគ្នា ដែលចូលជាធរមានសម្រាប់អ្នកជាប់ពន្ធកម្ពុជា ការបន្ធូរបន្ថយការយកពន្ធពីរដងត្រូវបានផ្តល់ដោយមធ្យោបាយមួយ។ ឥណទានពន្ធសម្រាប់ពន្ធដែលត្រូវបានបង់នៅក្នុងយុត្តាធិការផ្សេងទៀត[13]។

កិច្ចព្រមព្រៀងស្តីពីការចៀសវាងយកពន្ធត្រួតគ្នា ជាកិច្ចព្រមព្រៀងប្រទេសពីរ ឬច្រើនប្រទេសដែលធ្វើឡើងសម្រាប់កាត់បន្ថយបរិមាណពន្ធសម្រាប់អ្នកបម្រើការងារបរទេស ឬក្រុមហ៊ុនអន្តរជាតិ ឬដើម្បីចៀសផុតពីការបង់ពន្ធត្រួតគ្នាទ្វេដងលើប្រភពចំណូលដដែល[14]។

កិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា បែងចែកសិទ្ធិក្នុងការយកពន្ធរវាងប្រទេស ឬដែនដីជាហត្ថលេខីដែលអាចកម្រិតផ្នែកខ្លះនៃការអនុវត្តច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុកស្តីពីពន្ធដារ។ នៅក្នុងតំណាក់កាលនៃការអនុវត្តដំបូងអាចមានផលប៉ះពាល់ផ្ទាល់ដល់ចំណូលពន្ធរបស់ប្រទេសប្រភព ដោយសារការកាត់បន្ថយអត្រាពន្ធកាត់ទុក ដែលត្រូវអនុវត្តចំពោះអ្នកជាប់ពន្ធអនិវាសនជន និងការបែងចែកសិទ្ធិយកពន្ធលើប្រភេទប្រាក់ចំណូលមួយចំនួនឱ្យទៅប្រទេសនិវាសនដ្ឋាន[15]។

### ២.២.២ ប្រវត្តិនៃកិច្ចព្រមព្រៀងស្តីការចៀសវាងការយកពន្ធត្រួតគ្នារបស់កម្ពុជា

កម្ពុជាបានចាប់ផ្តើមរៀបចំគំរូកិច្ចព្រមព្រៀងទ្វេភាគី ស្តីពីកិច្ចព្រមព្រៀងស្តីការចៀសវាងការយកពន្ធត្រួតគ្នារបស់កម្ពុជាដំបូងរបស់ខ្លួននៅក្នុងឆ្នាំ២០០៦ ដោយយកលំនាំតាមគំរូរបស់អង្គការសហប្រជាជាតិ (UN Model)និងគំរូរបស់សមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN Model) ដែលផ្តល់ការអនុគ្រោះច្រើនដល់ប្រទេសកំពុងអភិវឌ្ឍន៍ តាមរយៈការការពារសិទ្ធិយកពន្ធរបស់ប្រទេសប្រភព និងផ្អែកលើគោលការណ៍មួយចំនួនដែលមានចែងក្នុងច្បាប់និងបទបញ្ញត្តិស្តីពីពន្ធដារកម្ពុជា។

គំរូរបស់ប្រទេសកម្ពុជា រួមមាន២៩មាត្រា ដែលមានខ្លឹមសារសំខាន់ៗពាក់ព័ន្ធនឹងវិសាលភាពនិយមន័យ ការបែងចែកសិទ្ធិយកពន្ធតាមប្រភេទចំណូល វិធីសាស្ត្រសម្រាប់លុបបំបាត់ការយកពន្ធត្រួតគ្នា និងការ

[12] https://www.ynn.com.kh/61357.html (13.01.2024)
[13] https://www.tax.gov.kh (13.01.2024)
[14] *ដកស្រង់ចេញពីសៀវភៅកំណែទម្រង់ពន្ធដារកម្ពុជា២០១៣ ២០២០ (ទំព័រទី៦០០)*
[15] ដូចលេខ១៤

មិនរើសអើងពន្ធ នីតិវិធីនៃកិច្ចព្រមព្រៀងទៅវិញទៅមក ការផ្លាស់ប្តូរព័ត៌មានគ្នាទៅវិញទៅមក ការចូលជាធរមាន និងការបញ្ចប់កិច្ចព្រមព្រៀង។

ក្នុងឆ្នាំ២០១០ សេចក្តីព្រាងទី២នៃគំរូកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នារបស់កម្ពុជាត្រូវបានរៀបចំឡើងក្រោមជំនួយបច្ចេកទេសរបស់ក្រសួងហរិញ្ញវត្ថុជប៉ុននិងក្រោមជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី(Asian Development Bank-ADB)។

សេចក្តីព្រាងគំរូទី៣ ត្រូវបានរៀបចំឡើងដោយការរួមបញ្ចូលឯកសារផែនការសកម្មភាព សម្រាប់ការចរចា និងពិនិត្យមើលនូវតម្រូវការនានារបស់អគ្គនាយកដ្ឋានពន្ធដារ ក្នុងករណីតម្រូវឱ្យមានការកែប្រែច្បាប់ស្តីពីសារពើពន្ធ ដើម្បីឱ្យមានសង្គតិភាពជាមួយនិងសេចក្តីព្រាងគំរូកិច្ចព្រមព្រៀងទ្វេភាគីស្តីការចៀសវាងការយកពន្ធត្រួតគ្នារបស់កម្ពុជា។

ក្រោមជំនួយបច្ចេកទេសនេះ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំឯកសារសំខាន់ៗមួយចំនួនរួមមានជាអាទិ៍៖ ក្របខ័ណ្ឌគោលនយោបាយស្តីពីកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការការចៀសវាងការយកពន្ធត្រួតគ្នារបស់កម្ពុជា សេចក្តីព្រាងគំរូកិច្ចព្រមព្រៀង កម្មវិធីចរចា និងជ្រើសរើសរដ្ឋសមាជិកអាស៊ានជាមួយប្រទេសអាតិភាពសម្រាប់ការចរចា។

នៅក្នុងឆ្នាំ២០១៤អគ្គនាយកដ្ឋានពន្ធដារបានស្នើសុំជំនួយបច្ចេសពីធនាគារពិភពលោក(World Bank) ក្នុងការផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការចរចាកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា ដើម្បីផ្តល់លទ្ធភាពឱ្យក្រុមការងារមានសមត្ថភាពគ្រប់គ្រាន់សម្រាប់ការចាប់ផ្តើមកិច្ចចរចា។ វគ្គបណ្តុះបណ្តាលនេះ ត្រូវបានរៀបចំឡើងក្រោមកិច្ចសហការរវាងធនាគារពិភពលោក (World Bank) និងអង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍(Organization for Economic Co-operation and Development-OECD) និងបណ្តុះបណ្តាលដោយអ្នកជំនាញការចរចារបស់សិង្ហបុរី[16]។

**២.២.៣ លក្ខណៈទូទៅ នៃកិច្ចព្រមព្រៀងស្តីពីការយកពន្ធត្រួតគ្នា**

កិច្ចព្រមព្រៀងស្តីពីការចៀសវាងយកពន្ធត្រួតគ្នា ផ្តល់ភាពច្បាស់លាស់អំពីសិទ្ធិនៃការយកពន្ធនៃប្រទេសរៀងៗខ្លួនដែលជាហត្ថលេខីនៅក្រោម កិច្ចព្រមព្រៀងស្តីពីការចៀសវាងយកពន្ធត្រួតគ្នា និងកំណត់ប្រភេទនៃប្រាក់ចំណូលដែលត្រូវបានគ្របដណ្តប់ក្រោមសន្ធិសញ្ញា។ លើសពីនេះ កិច្ចព្រមព្រៀងស្តីពីការចៀសវាងយកពន្ធត្រួតគ្នា មានច្បាប់ជាក់លាក់ស្តីពីការបង្កើតគ្រឹះស្ថានអចិន្ត្រៃយ៍ ការយកពន្ធលើបុគ្គល ការដឹកជញ្ជូនអន្តរជាតិ ជម្លោះ និងការផ្លាស់ប្តូរព័ត៌មាន។ កិច្ចព្រមព្រៀងស្តីពីការចៀសវាងយកពន្ធត្រួតគ្នា ក៏ដើរតួនាទីយ៉ាងសំខាន់ផងដែរ ទាក់ទងនឹងការព្រួយបារម្ភកាន់តែខ្លាំងឡើងពីរដ្ឋាភិបាលដែលកំពុងស្វែងរកការការពារមូលដ្ឋានពន្ធរៀងៗខ្លួនពីសំណើរតាមរយៈយន្តការដូចជាការផ្លាស់ប្តូរប្រាក់ចំណេញ។

ពន្ធកម្ពុជាដែលគ្របដណ្តប់ក្រោម កិច្ចព្រមព្រៀងស្តីពីការចៀសវាងយកពន្ធត្រួតគ្នា អាចរួមបញ្ចូលពន្ធលើប្រាក់ចំណូល។ ពន្ធកាត់ទុកលើភាគលាភ ការប្រាក់ និងសួយសារអាករ; ពន្ធអប្បបរមា; ពន្ធបន្ថែមលើការបែងចែកភាគលាភ; និងពន្ធលើប្រាក់ខែ ។

---

[16] ដកស្រង់ចេញពីកំណែទម្រង់ពន្ធដារឆ្នាំ២០១៣-២០២០(ទំព័រទី៥៩៩)

លក្ខណៈសំខាន់មួយនៃ កិច្ចព្រមព្រៀងស្តីពីការចៀសវាងយកពន្ធត្រួតគ្នា តាមទស្សនៈអ្នកជាប់ពន្ធកម្ពុជា គឺសមត្ថភាពក្នុងការប្រើប្រាស់អត្រាពន្ធកាត់ទុកដែលបានកាត់បន្ថយលើការទូទាត់ទាក់ទងនឹងភាគលាភ សួយសារអាករ ការប្រាក់ ឬថ្លៃសេវាបច្ចេកទេសដល់អ្នកជាប់ពន្ធនៅក្នុងប្រទេសដែលបានចុះហត្ថលេខាលើ កិច្ចព្រមព្រៀងស្តីពីការចៀសវាងយកពន្ធត្រួតគ្នា ។ អត្រាកាត់ទុកស្តង់ដារលើការបង់ប្រាក់ដែលធ្វើឡើងដោយអ្នកជាប់ពន្ធកម្ពុជាចំពោះអ្នកមិនមែនជានិវាសនជនគឺ ១៤% ចំណែកឯនៅក្រោម កិច្ចព្រមព្រៀងស្តីពីការចៀសវាងយកពន្ធត្រួតគ្នា ដែលចូលជាធរមាន នេះអាចកាត់បន្ថយមកត្រឹម ១០% ក្នុងករណីភាគច្រើន។

## ២.៣ នីតិវិធីក្នុងការអនុវត្តលើកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា

### ២.៣.១ និយមន័យ(ច្បាប់)

**នីតិ** ជាគ្រឿងណែនាំ បែបផែន ជាទំនៀម ប្រពៃណី ឬជាបណ្តុំនៃវិធានគតិយុត្តដែលមានចំណងសិទ្ធិ និងកាតព្វកិច្ច មានអានុភាពចាប់បង្ខំលក្ខណៈទូទៅមិនចំពោះនិងមានគោលដៅរៀបចំសណ្តាប់ធ្នាប់សាធារណៈ[17]។

### ២.៣.២ ប្រវត្តិនីតិ(ច្បាប់)

នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានការវិវត្តន៍ជាច្រើនពីច្បាប់ប្រពៃណី ដែលមិនសរសេរដែលរាលដាលតាំងពីសម័យអង្គរមកជាច្បាប់សរសេរ ដែលត្រូវអនុម័តដោយស្ថាប័ននីតិបញ្ញត្តិដែលពាក់ព័ន្ធជាច្រើន។ ប្រព័ន្ធច្បាប់នៅក្នុងប្រទេសកម្ពុជា ជះឥទ្ធិពលជាខ្លាំងពីប្រពន្ធ័ច្បាប់ស៊ីវិលរបស់ប្រទេសបារាំងនៅក្រោមអាណានិគមពីឆ្នាំ១៨៦៣ ដល់១៩៥៣ និងរហូតដល់១៩៧៥។ នៅក្រោមរបបខ្មែរក្រហមពីឆ្នាំ១៩៧៥ ខែមេសា ទៅដល់ខែមិថុនា ឆ្នាំ១៩៧៩ ប្រព័ន្ធច្បាប់របស់ប្រទេសកម្ពុជាទាំងមូល ទាំងច្បាប់ដែលមានស្រាប់ ដូចជាច្បាប់របស់រដ្ឋាភិបាល និងច្បាប់គ្រប់គ្រងប្រព័ន្ធយុត្តាធិការ ត្រូវបានបំភ្លេចបំផ្លាញ។ ចៅក្រម មេធាវី និងអ្នកច្បាប់ជាច្រើនត្រូវបានសម្លាប់។ បន្ទាប់ពីកងទ័ពវៀតណាមចូលមកប្រទេសកម្ពុជានៅឆ្នាំ១៩៧៩ ប្រព័ន្ធច្បាប់របស់ប្រទេសកម្ពុជាត្រូវ បានជះឥទ្ធិពលដោយវៀតណាមដូចជាច្បាប់កិច្ចសន្យា។ នៅក្នុងអំឡុង ពេលនៃការចុះអន្តរាគមន៍របស់ក្រុមការងារអង្គការសហប្រជាជាតិពីឆ្នាំ១៩៩១ ដល់១៩៩៣ ច្បាប់ជាច្រើន ត្រូវបានរៀបចំមានទាំងច្បាប់ព្រហ្មទណ្ឌ ច្បាប់ទាក់ទងនឹងយុត្តាធិការតុលាការ និងច្បាប់ដែលត្រូវប្រើប្រាស់ ក្នុងសង្គមជាច្រើនទៀត។ ជាលទ្ធផលការធ្វើកំណែទម្រង់ច្បាប់បរទេសមកជាច្បាប់នៅក្នុងប្រទេស ធ្វើឱ្យប្រព័ន្ធនៅក្នុងប្រទេសកម្ពុជា ត្រូវបានបញ្ជៀបចូលនូវប្រព័ន្ធច្បាប់ common law។ ប្រព័ន្ធច្បាប់នៅពេលបច្ចុប្បន្ន គឺត្រូវបានលាយបញ្ចូលគ្នារវាង Civil Law និង Common law ។

### ២.៣.៣ ប្រភពនីតិ(ច្បាប់)

នីតិមានប្រភពច្រើន ក្នុងនោះរួមមាន៖

- តាមការវិវិត្តរបស់សង្គម សហគមន៍
- ការរស់នៅហួសព្រំដែននៃសេរីភាពរបស់មនុស្ស
- មនុស្សចង់មាន ចង់បានហួសហេតុ
- មនុស្សមានជម្លោះរវាងគ្នា និងគ្នាឈានទៅរកការមានជម្លោះ
- នៅក្នុងសង្គមនោះមានសមាជិកច្រើនៗ ការផ្គត់ផ្គង់មិនគ្រប់គ្រាន់តាមតម្រូវការ

[17] អ្វីជានីតិ? ក្រម? ច្បាប់? 1.... - Law and social phally | Facebook (15.December.2023)

- ការប្រើប្រាស់អំណាចផ្តាច់ការឈានទៅដល់ការបង្កើនបទដ្ឋានដែលមានលក្ខណៈទំនើប
- ហើយបទដ្ឋានទំនើបទាំងនោះ ដើម្បីរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយ សេចក្តីថ្លៃថ្នូរ និងសន្តិភាព ទើបមានការកើតនូវនីតិឡើង
- ម៉្យាងវិញទៀត ការកកើតនូវនីតិ គឺមិនមានលក្ខណៈវណ្ណៈ និងជាឧបករណ៍របស់វណ្ណៈខ្លាំង ឬខ្សោយណាមួយទេ
- ជាស្មារតីទូទៅ ច្បាប់តែងតែលើកតម្កើងដល់តម្លៃសីលធម៌ សេដ្ឋកិច្ច និងនយោបាយរបស់សង្គម
- ដោយហេតុនេះ ហើយទើបគេសង្កេតឃើញថាច្បាប់ពីប្រទេសមួយទៅប្រទេសមួយទៀត តែងតែ
- មានលក្ខណៈខុសៗគ្នា តួយ៉ាងដូចជាច្បាប់ នៅក្នុងបណ្តាប្រទេសដែលគោរព និងប្រកាន់សាសនាឥស្លាម ដូចជាប្រទេស អ៊ីរ៉ង់ ប្រទេសប៉ាគីស្ថាន ប្រទេសឥណ្ឌូនេស៊ី
- តែងតែមានលក្ខណៈខុសប្លែកគ្នាពីបណ្តាប្រទេសដែលប្រកាន់តាមសាសនាព្រះពុទ្ធ សាសនាកាទូលិក ដូចជាប្រទេសថៃ ប្រទេសអ៊ីតាលី ប្រទេសម៉ិកស៊ិក..ជាដើម។ ច្បាប់ដែលមានប្រជាពលរដ្ឋភាគច្រើនមានក្រុមជាតិសាសន៍ដូចគ្នា ដូចជាប្រទេសវៀតណាម អាចមានលក្ខណៈខុសប្លែកពី បណ្តាប្រទេសដែលប្រកាន់សាសនាខុសៗគ្នា ដូចជាប្រទេសកាណាដា ប្រទេសឥណ្ឌា។
- ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក្នុងករណីដែលតម្លៃសង្គមមានការផ្លាស់ប្តូរ ពោលនោះច្បាប់ក៏ត្រូវមានការផ្លាស់ប្តូរផងដែរ។
- បើតាមផ្លូវច្បាប់ និងតាមការស្រាវជ្រាវកន្លងមក នីតិមានប្រភពសំខាន់ៗ ២ យ៉ាងគឺ:

  ១. ប្រភពសរសេរជាលាយលក្ខណ៍អក្សរ ( Written)

  ២. និងប្រភពមិនសរសេរជាលាយលក្ខណ៍អក្សរ (Unwritten) ។

**២.៣.៣ តួនាទីនីតិ( ច្បាប់)**

ច្បាប់មានមុខងារ ឬវត្ថុបំណងបួនយ៉ាងធំៗ

- ច្បាប់ គឺរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សង្គមក៏ដោយ ក៏នៅក្នុងប្រទេសប្រកាន់លទ្ធិប្រជាធិបតេយ្យតែងមានការថ្លឹងថ្លែងដោយប្រុងប្រយ័ត្នរវាងសណ្តាប់ធ្នាប់ និងសេរីភាពរបស់មនុស្ស។
- មុខងារទីពីររបស់ច្បាប់ គឺដោះស្រាយជម្លោះ។ ប្រសិនបើមនុស្សម្នាក់រស់នៅលើកោះមួយតែម្នាក់ឯង គាត់មិនចាំបាច់មានច្បាប់ទម្លាប់អីទេ។ ពេលនោះគាត់ចង់ស្លៀកសម្លៀកបំពាក់ក៏បាន គាត់មិនចង់ស្លៀកក៏បាន។ លើសពីនេះទៀតការរស់នៅលើកោះតែម្នាក់ឯង មិនចាំបាច់បែងចែកភោគផលធនធានធម្មជាតិសម្រាប់ចិញ្ចឹមជីវិតជាមួយអ្នកណាទៀតផង។ ប៉ុន្តែនៅពេលបរិមាណមនុស្សចេះតែកើនឡើង ភោគផលធនធាននៅលើកោះអាចនឹងត្រូវបែងចែកគ្នា។ នៅពេលចំនួនមនុស្សកាន់តែច្រើន ភោគផលចិញ្ចឹមជីវិតអាចថយចុះ ពេលនោះជម្លោះដណ្តើមភោគផលធនធានទ្រព្យសម្បត្តិក៏អាចកើតមានឡើង។ ដូច្នេះ ភាពចាំបាច់នៃការបង្កើតច្បាប់សម្រាប់បែងចែកភោគផលសម្រាប់សេដ្ឋកិច្ចគ្រួសារនៅលើកោះឱ្យមានសមធម៌ អាចនឹងត្រូវការ ដើម្បីជៀសវាងការផ្ទុះឡើងនៃជម្លោះ។ ដូច្នេះ សម្រាប់អ្នកដែលយល់ឃើញថា ច្បាប់គឺវិធានសម្រាប់ដោះស្រាយជម្លោះនោះ ច្បាប់ពិតជាសំខាន់ក្នុងការជួយកសាងសន្តិភាព និងផ្ទេរអំណាចដោយរលូន។

- មុខងារទីបីរបស់ច្បាប់ គឺការពារសិទ្ធិមនុស្ស។ សម្រាប់អ្នកយល់ឃើញថា ច្បាប់ជាវិធានសម្រាប់ការពារសិទ្ធិមនុស្ស តែងយកសិទ្ធិមនុស្សជាគោល នៅពេលតាក់តែងច្បាប់អ្វីមួយ។ ក្រោយពីប្រទេសកម្ពុជា ឆ្លងកាត់នូវសង្គ្រាមដ៏មហាវិនាសព្រាត់ប្រាស និងការរំលោភសិទ្ធិមនុស្សដ៏គួរឱ្យភ័យរន្ធត់ រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ គឺជាការឆ្លុះបញ្ចាំងអំពីបំណងប្រាថ្នារបស់ប្រជារាស្ត្រខ្មែរ ចង់បានច្បាប់ដែលបញ្ជាក់នូវការគោរពសិទ្ធិមនុស្ស។ ពេលនោះហើយ គឺជាលើកទី១ដែលរដ្ឋសភាកម្ពុជា បានបញ្ចូលច្បាប់សិទ្ធិមនុស្សអន្តរជាតិនានាទៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា។
- មុខងារទីបួនរបស់ច្បាប់ គឺការសម្តែងឆន្ទៈរបស់រាស្ត្រ។ រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៤៧ ដែលចម្លងចេញពីរដ្ឋធម្មនុញ្ញបារាំង ឱ្យនិយមន័យថា ច្បាប់ គឺជាការសម្តែងឆន្ទៈរបស់រាស្ត្រ។ ហេតុផលរបស់អ្នកដែលយល់ថា ច្បាប់ជាការសម្តែងឆន្ទៈរបស់រាស្ត្រនោះ គឺដោយសារថា ប្រជារាស្ត្រមានគ្នាច្រើនមិនអាចមកជួបជុំគ្នាបានក្នុងពេលតែមួយ ទើបរាស្ត្របោះឆ្នោតឱ្យមានតំណាងរបស់ខ្លួនដែលហៅថា តំណាងរាស្ត្រ ឱ្យទៅជួបជុំគ្នាធ្វើការងារ មានការងារធ្វើច្បាប់ និងការងារតាមដានសកម្មភាពរបស់រដ្ឋាភិបាលជាដើម។

# ជំពូកទី៣
# កិច្ចព្រមព្រៀងស្ដីពីការចៀសវាងការយកពន្ធត្រួតគ្នា នៃអគ្គនាយកដ្ឋានពន្ធដារ
# អគ្គនាយកដ្ឋានពន្ធដារ

## ៣.១ ស្ថានភាពទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ

### ៣.១.១ ប្រវត្តិរបស់អគ្គនាយកដ្ឋានពន្ធដារ



នាយកដ្ឋានពន្ធដារត្រូវបានបង្កើតឡើង នៅឆ្នាំ១៩៥៣ក្នុងអំឡុងពេលដែលប្រទេសជាតិមានការរីកចម្រើនស្ទើរគ្រប់វិស័យ។ ប៉ុន្តែក្រោយឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ របបប៉ុលពតបានចូលមកកម្ពុជា ដោយបានបំផ្លាញនូវហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេសជាតិ សាសនា ប្រពៃណីនិងទំនៀមទម្លាប់ គ្រប់យ៉ាងចោលទាំងអស់ រួមទាំងនាយកដ្ឋានពន្ធដារផងដែរ។ បន្ទាប់ពីបញ្ចប់សង្គ្រាមនៅឆ្នាំ១៩៨០ ពន្ធដារបានបង្កើតឡើងវិញ ដើម្បីលើកស្ទួយប្រទេសជាតិឱ្យមានការរីកចម្រើនជាងមុនរហូតដល់ឆ្នាំ២០០៨ នាយកដ្ឋានពន្ធដារបានដំឡើង ទៅជាអគ្គនាយកដ្ឋានពន្ធដារដោយសាលាជាតិពន្ធដារ ។ មកដល់ពេលនេះអគ្គនាយកដ្ឋានពន្ធដារមានសាខាពន្ធដារគ្រប់ខេត្តក្រុងក្នុងប្រទេសកម្ពុជា ក្នុងនោះមាន **សាខាពន្ធដារ** ជាច្រើនក៏ត្រូវបានបង្កើតឡើង ដោយមានទីតាំងស្ថិត នៅ រាជធានីភ្នំពេញនិងខេត្ត។ ដើម្បីជួយសម្រួលបន្ទុករបស់អគ្គនាយកដ្ឋានពន្ធដារ ក្នុងការប្រមូលពន្ធក៏ដូចជាជួយសម្រួលដល់អ្នកជាប់ពន្ធ មានភាពងាយស្រួលក្នុងការបង់ពន្ធ។ នៅព្រះរាជាណាចក្រកម្ពុជាបានបង្កើតនាយកដ្ឋានពន្ធដារតាមសេចក្ដីសម្រេចលេខ ៤១៥ សេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាន៍ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ១៩៨១ ដែលមានឈ្មោះដើមហៅថា នាយកដ្ឋានពន្ធដារឧស្សាហាពាណិជ្ជ ស្ថិតនៅក្រោមនៅក្រោមការគ្រប់គ្រងរបស់មន្ទីរហិរញ្ញវត្ថុ និងធនាគារខេត្តក្រុង។ ស្ថាប័ននេះបានប្ដូរឈ្មោះទៅជានាយកដ្ឋានពន្ធដារដោយផ្អែកតាមអនុក្រឹតលេខ២៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី និងសារាចរណែនាំអនុវត្តរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ០៥៧ សហវ ចុះទី១៣ ខែ កុម្ភៈ ឆ្នាំ

១៩៩១ ។ នៅថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០០៨ ដោយអនុក្រឹត្យលេខ ១៣៤ អនក្រ បានតម្លើងនាយកដ្ឋានពន្ធដាររបស់ទៅជា អគ្គនាយកដ្ឋានពន្ធដារ ដោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានសាខានៅតាមខេត្ត-ខណ្ឌផងដែរ។

សាខាពន្ធដារខណ្ឌដូនពេញ មានការិយាល័យចំណុះ៤ ហើយតួនាទី និងភារកិច្ចរបស់សាខាពន្ធដារជាទូទៅដូចគ្នានឹងតួនាទី និងភារកិច្ចរបស់នាយកដ្ឋានគ្រប់គ្រង់អ្នកជាប់ពន្ធធំដែរ និងមានតួនាទីនិងភារកិច្ចបន្ថែមក្នុងការគ្រប់គ្រង និងប្រមូលពន្ធលើអ្នកជាប់ពន្ធតូច និងប្រភេទពន្ធមួយចំនួន ទៀត។ តួនាទី និងភារកិច្ចបន្ថែមមានជាអាទិ៍៖

១. ការិយាល័យសេវាអ្នកជាប់ពន្ធ និងចុះបញ្ជីមានតួនាទីនិងភារកិច្ចបន្ថែមគឺ ប្រមូលតែមប្រិយ ពន្ធមធ្យោបាយលើយានយន្តគ្រប់ប្រភេទ ពន្ធឈ្នួលផ្ទះ ដី។
២. ការិយាល័យចាត់ចែងលិខិតប្រកាសមានតួនាទីនិងភារកិច្ចបន្ថែមគឺ ធ្វើការកំណត់ពន្ធលើអ្នកជាប់ ពន្ធតូចៗ
៣. ការិយាល័យសវនកម្មពន្ធមានតួនាទីនិងភារកិច្ចបន្ថែមគឺ អាចធ្វើសវនកម្មលើអ្នកជាប់ពន្ធតូចក្នុងករណីចាំបាច់។
៤. ការិយាល័យបំណុលពន្ធ មានតួនាទីនិងភារកិច្ចបន្ថែមគឺ ប្រមូលប្រាក់ពន្ធសរុបរបស់អ្នកជាប់ពន្ធ និងបង់ប្រាក់ពន្ធទៅរតនគាបុធនាគា ចុះបញ្ជីគណនេយ្យនិងគ្រប់គ្រងស្ថិតិគ្រប់ប្រភេទពន្ធ។

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។ ភារកិច្ចទាំងឡាយណា ដែលពាក់ព័ន្ធនិងសមត្ថកិច្ចរបស់នាយកដ្ឋាន ឬអង្គភាពជំនាញដ៏ទៃ និងសាខាពន្ធដារខណ្ឌត្រូវសហការជាមួយអង្គភាពពាក់ព័ន្ធទាំងនោះ ត្រូវសុំគោលការណ៍ពីថ្នាក់ដឹកនាំ អគ្គនាយកដ្ឋានពន្ធដារដើម្បីរួមគ្នាដោះស្រាយ។

### ៣.១.២ គោលនយោបាយ

គោលនយោបាយពន្ធដារតាមសាខានីមួយៗ សំដៅលើការយកពន្ធនិងវិធីរកចំណូលផ្សេងៗទៀត និងការចំណាយរបស់រដ្ឋ ដោយបែងចែកធនធានសេដ្ឋកិច្ច ក្នុងគោលបំណងជំរុញរបស់មានកំណើនសេដ្ឋកិច្ចប្រកបដោយជីវភាព និងសម្បុរសធម៌ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពគោលនយោយបាយសារពើពន្ធ រដ្ឋត្រូវអនុវត្តសកម្មភាពសំខាន់ៗដូចជា៖

១. ប្រសិទ្ធភាពនៃការគ្រប់គ្រង និងកៀរគរចំណូល
២. ការធ្វើវិចារណៈកម្មចំណាយ គឺបែងចែកចំណាយថវិការរដ្ឋ រវាងការប្រើប្រាស់ និងការវិនិយោគសាធារណៈឱ្យបានសមស្រប។

គោលនយោបាយសារពើពន្ធរបស់ប្រទេសនីមួយៗគួរតែមានគោលដៅជាគោលការណ៍ចំនួនបួនគឺ ការបែងចែកធនធាន ស្ថេរភាពវូបនីយកម្មកំណើន ការបែងចែកនៃប្រាក់ចំណូលនៃទ្រព្យសម្បត្តិឱ្យស្មើគ្នា។ តាមរយៈពន្ធ និងចំណាយសារធារណៈ រដ្ឋាភិបាលដើរតួនាទីសំខាន់ក្នុងការបែងចែកបណ្តាធនធាននៅក្នុងសេដ្ឋកិច្ច និងជំរុញខ្សែសង្វាក់ផលិតកម្មឱ្យកើនឡើង។

### ៣.១.៣ បេសកកម្ម និងទស្សនៈវិស័យ

បេសកកម្មរបស់អគ្គនាយកដ្ឋានពន្ធដារ គឺដើម្បីជួយពន្លឿននិងសម្រួលដល់ការធ្វើធុរកិច្ចស្របច្បាប់ និងបង្កើតចំណូលថវិការជាតិ ការធានាឱ្យមានការប្រកួតប្រជែងសេដ្ឋកិច្ច ប្រកបដោយសីលធម៌ ការធ្វើឱ្យ

ប្រសើរឡើងនូវសុវត្ថិភាពសង្គម និងសន្តិសុខជាតិ និងការធ្វើឱ្យមាននិរន្តភាពនៃការអភិវឌ្ឍន៍ និងសម្រេចបាន តាមគោលដៅកំណើនសេដ្ឋកិច្ចរបស់កម្ពុជា។ អគ្គនាយកដ្ឋានពន្ធដារ មានបេសកម្មធ្វើឱ្យសម្រេចការអនុវត្ត ច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារតាមការៈ

- ➢ ផ្តល់សេវាដល់អ្នកជាប់ពន្ធរួមមាន ការផ្តល់ព័ត៌មានអប់រំ ពន្យល់ណែនាំ ដើម្បីឱ្យអ្នកជាប់ពន្ធ ប្រតិបត្តិត្រឹមត្រូវ តាមច្បាប់ និងបទប្បញ្ញត្តិនាន
- ➢ អនុវត្តកម្មវិធីចាប់បង្ខំដោយការធ្វើសវនកម្ម ការអនុវត្តវិធានការតឹងរ៉ឹង និងអនុវត្តទោសទណ្ឌ តាមការ កំណត់នៃបទប្បញ្ញត្តិស្តីពីពន្ធដារចំពោះអ្នកជាប់ពន្ធដែលមិនបានប្រតិបត្តិត្រឹមត្រូវ តាមច្បាប់ និង បទប្បញ្ញត្តិនានាស្តីពីពន្ធដារ។
- ➢ ប្រមូលចំណូលពន្ធតាមការអនុវត្តត្រឹមត្រូវនូវច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ និងបង់គ្រប់គ្រាន់ ចូលថវិកាជាតិ។
- ➢ ផ្តល់សេវា និងការអប់រំអ្នកជាប់ពន្ធ ដើម្បីធានាឱ្យច្បាប់នានាស្តីពីពន្ធដារត្រូវបានគោរព និងអនុវត្ត ត្រឹមត្រូវ។
- ➢ អនុវត្តកម្មវិធីចាប់បង្ខំប្រកបដោយប្រសិទ្ធភាព មានការទទួលខុសត្រូវខ្ពស់ និងស្មើភាពគ្នាចំពោះ អ្នកជាប់ពន្ធ ដែលមិនគោរពច្បាប់ និងបទញ្ញត្តិស្តីពីសារពើពន្ធ។
- ➢ អនុវត្តគោលការណ៍យុត្តិធម៌ក្នុងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ ដើម្បីបង្កើនការ ជឿទុកចិត្តចំពោះរដ្ឋបាលសារពើពន្ធ។
- ➢ បន្ថយការចំណាយរបស់រដ្ឋបាលសារពើពន្ធ ក្នុងការរៀបចំកម្មវិធី និងកិច្ចដំណើរការរបស់ខ្លួន ធ្វើឱ្យ មានភាពសាមញ្ញចំពោះតម្រូវការផ្សេងៗ និងបន្ថយការចំណាយរបស់អ្នកជាប់ពន្ធ។
- ➢ បង្កើនសមត្ថភាពចំណេះដឹងដល់មន្ត្រីពន្ធដារជាប្រចាំដើម្បីបំពេញការងារឱ្យមានប្រសិទ្ធភាព
- ➢ បង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង តាមរយៈគោលនយោបាយកិច្ចដំណើរការការងារនិង ប្រព័ន្ធ ការងារដែលមានភាពច្បាស់លាស់ និងមានការទទួលខុសត្រូវខ្ពស់ចំពោះការងារខ្លួន។
- ➢ ទស្សនវិស័យរបស់ពន្ធដារ គឺការអភិវឌ្ឍនខ្លួនឱ្យក្លាយជារដ្ឋបាលសារពើពន្ធ មួយស្របតាម បមាណីយ និងឧត្តមានុវត្តន៍ ជាអន្តរជាតិដោយមានការទទួលស្គាល់ពីថ្នាក់ជាតិ និងអន្តរជាតិលើ ប្រសិទ្ធភាព នៃការគ្រប់គ្រងរដ្ឋបាល និងកិច្ចប្រតិបត្តិការ ព្រមទាំងជាស្ថាប័នផ្តល់សេវាយ៉ាងមាន ប្រសិទ្ធភាព ដល់សហគមន៍ធុរកិច្ចនិងភាគីពាក់ព័ន្ធ។

**៣.១.៤ តួនាទី និងភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ**

តួនាទីរបស់ពន្ធដារមាន ៣ គឺៈ

- ជាប្រភពចំណូលដ៏សំខាន់សម្រាប់ថវិកាជាតិ
- ជួយជម្រុញកំណើនសេដ្ឋកិច្ចជាតិ
- ទប់ស្កាត់ការនាំចូល ការនាំចេញ និងរក្សាតុល្យភាពចំណូលរបស់ប្រជាពលរដ្ឋ។

❖ កាតព្វកិច្ចពន្ធដារមានជាអាទិ៍ភាពដូចតទៅៈ

- រៀបចំគោលនយោបាយសារពើពន្ធ និងការប្រមូលពន្ធគ្រប់ប្រភេទបង់ចូលជាតិ
- រៀបចំសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋាននានាស្តីពីពន្ធដារ កំណត់បញ្ជីឯកសារចាំបាច់នានា និង លិខិតយុត្តិធម៌ការដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារត្រូវកាន់កាប់រក្សាទុក និងផ្តល់ជូនរដ្ឋបាលសារពើពន្ធ

- កំណត់មូលដ្ឋានគិតពន្ធលើអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកដោយផ្អែកលើការអង្កេត និងផ្តុំព័ត៌មាន
- គណនា និងប្រមូលប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងចំណូលផ្សេងៗ
- កសាងកម្មវិធី និងអនុវត្តការងារសេវនកម្មចំពោះអ្នកជាប់ពន្ធ
- ទទួលបន្ទុកសហប្រតិបត្តិការអន្តរជាតិក្នុងផ្នែកពន្ធដារ
- អនុវត្តទោសទណ្ឌតាមច្បាប់ចំពោះអ្នកជាប់ពន្ធ និងភ្នាក់ងារកាត់ទុក ដែលល្មើសបទប្បញ្ញត្តិនានាស្តីពីពន្ធដារ
- ចូលរួមរៀបចំគម្រោងថវិកាជាតិប្រចាំឆ្នាំ ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ។

## ៣.២ ការបង្កើតកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា

### ៣.២.១ ការបង្កើតឱ្យមានកិច្ចព្រមព្រៀង

យោងតាមផែនការមេរបស់សហគមន៍សេដ្ឋកិច្ចអាស៊ាន (ASEAN ECONOMIC COMMUNITY BLUEPRINT 2015) ត្រង់ចំណុច II.B.B5 ស្តីពីកិច្ចសហប្រតិបត្តិការក្នុងវិស័យ ពន្ធដារ (TAXATION COOPERATION)(៩៤) រដ្ឋសមាជិកត្រូវបញ្ចប់ការចរចាកិច្ចព្រមព្រៀង ទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា (Double Taxation Agreement - DTA) ក្នុង ចំណោមរដ្ឋជាសមាជិកទាំងអស់ឱ្យបានក្នុងឆ្នាំ ២០១០ ប្រសិនបើអាចធ្វើទៅបាន។ ដើម្បីបំពេញកាតព្វកិច្ចក្រោមក្របខ័ណ្ឌអាស៊ានក្នុងការទាក់ទាញ និងសម្រួលការវិនិយោគ និងពាណិជ្ជកម្មអន្តរជាតិ ព្រមទាំងដើម្បីទប់ស្កាត់ និងបង្ក្រាបការគិបកេងបន្លំពន្ធទាំងក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ ព្រះរាជាណាចក្រកម្ពុជាបានកំណត់ជ្រើសរើសប្រទេសជាអាទិភាពមួយចំនួន សម្រាប់ការចរចាកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា ក្នុងនោះរួមមានបណ្តា រដ្ឋជាសមាជិកអាស៊ាន អាស៊ានបូកបី និងបណ្តាប្រទេសមួយចំនួនទៀត ដោយផ្អែកលើលក្ខណៈ វិនិច្ឆ័យចម្បង ដូចជា៖ កាតព្វកិច្ចជាអន្តរជាតិ កិច្ចសហប្រតិបត្តិការអន្តរជាតិ ប្រទេសដែលជាដៃគូ វិនិយោគធំៗ និងតាមការស្នើសុំចរចារបស់បណ្តាប្រទេសមួយចំនួនទៀត។

### ៣.២.២ ចំណូលពន្ធដារ

ជាការពិតណាស់ គឺមានកត្តាចម្បង និងសមាសធាតុសំខាន់ៗមួយចំនួនទៀត ដែលជាឥទ្ធិពល និងជាចំណែកដ៏ធំដល់ការសម្រេចបានជោគជ័យជាប្រវត្តិសាស្ត្រនូវកំណើនចំណូល ពន្ធដារពីមួយឆ្នាំទៅមួយឆ្នាំក្នុងរយៈពេល៨ឆ្នាំ(២០១៣-២០២០)ជាប់ៗគ្នាដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបានបង់ចូលថវិកាជាតិ។ កត្តាចម្បង និងសមាសធាតុសំខាន់ៗទាំងនោះ មាន ដូចជា៖

- សុខសន្តិភាព ស្ថិរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ច
- គោលនយោបាយ និងយុទ្ធសាស្ត្រកែទម្រង់ស៊ីជម្រៅដ៏មុតស្រួចរបស់រាជរដ្ឋាភិបាល ដែលមានលក្ខណៈប្រទាក់ក្រឡាគ្នាល្អពីថ្នាក់ជាតិរហូតដល់ថ្នាក់មូលដ្ឋាន
- ការបន្តផ្តល់ការគាំទ្រពេញទំហឹងជាប្រចាំពីសំណាក់ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់នៃ រាជរដ្ឋាភិបាល
- បាវចនាគោលការណ៍រួមរបស់អគ្គនាយកដ្ឋានពន្ធដារក្នុងការបំពេញការងារ ៤ ចំណុច ដែលបានដាក់ចេញដោយ**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយក រដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- ឆន្ទៈ និងការប្តេជ្ញាចិត្តដ៏អង់អាចក្លាហាន និងហ្មត់ចត់ជាទីបំផុតរបស់ថ្នាក់ដឹកនាំ និង មន្ត្រីរាជការពន្ធដារក្នុងការខិតខំអនុវត្តកម្មវិធីកែទម្រង់ស៊ីជម្រៅដ៏មុតស្រួច ដើម្បីធ្វើ ទំនើបកម្មអគ្គនាយកដ្ឋានពន្ធដារ ឱ្យក្លាយជារដ្ឋបាលសារពើពន្ធទំនើបទាន់សម័យ ដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញបេសកកម្មគ្រប់គ្រង និងប្រមូលចំណូល ពន្ធដារបង់ចូលថវិកាជាតិប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព តម្លាភាព និង គណនេយ្យភាព តាមរយៈការប្រកាន់យកយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍អភិបាលកិច្ចល្អ រដ្ឋបាលកិច្ចល្អ អភិក្រមការងារ វិធីសាស្ត្រនៃប្រសិទ្ធភាពក្នុងការដឹកនាំ និងការគ្រប់គ្រង និងប្រព័ន្ធគុណាធិបតេយ្យ
- កិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិជុំវិញកិច្ចការពន្ធដារជាមួយអន្តរក្រសួង និង ស្ថាប័នរដ្ឋ វិស័យឯកជន និងអ្នកបង់ពន្ធ ព្រមទាំងដៃគូអភិវឌ្ឍន៍ អង្គការមិនមែន រដ្ឋាភិបាល និងមជ្ឈដ្ឋានពាក់ព័ន្ធមួយចំនួនទៀតដោយឈរលើដំហរគោរព និងផ្តល់តម្លៃឱ្យគ្នាទៅវិញទៅមកជាដៃគូដើម្បីប្រយោជន៍រួម។ល។
- កត្តា និងសមាសធាតុសំខាន់ៗ ដូចបានលើកឡើងខាងលើ គឺជាមូលហេតុ និងជាកាតាលិករដែលជំរុញ ឱ្យអគ្គនាយកដ្ឋានពន្ធដារសម្រេចបានជោគជ័យគួរជាទីមោទនៈជាប្រវត្តិសាស្ត្រនូវ កំណើនចំណូលពន្ធដារពីមួយឆ្នាំទៅមួយឆ្នាំក្នុងរយៈពេល៨ឆ្នាំជាប់ៗគ្នា។តារាងទី១ខាងក្រោមនេះបង្ហាញពីតួលេខជាក់ស្តែងនៃចំណូលពន្ធដារសរុបដែលអគ្គនាយកដ្ឋានពន្ធដារសម្រេចបាន ក្នុងមួយឆ្នាំៗ ចាប់ពីឆ្នាំ២០១១ ដល់ឆ្នាំ២០២០។

| ឆ្នាំ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|---|---|---|---|---|---|
| ចំណូល (ប៊ីលានរៀន) | 2,360.05 | 3,036.32 | 3,604.89 | 4,267.99 | 5,210.22 | 6,010.48 | 7,904.06 | 8,791.66 | 11,279.25 | 11,608.83 |
| ចំណូល (លានដុល្លា) | 590.01 | 759.08 | 901.22 | 1,067.00 | 1,302.56 | 1,502.62 | 1,976.02 | 2,197.92 | 2819.33 | 2,902.21 |

ប្រភព៖ ទិន្នន័យចំណូលពន្ធដារដកស្រង់ចេញពីតារាងផ្ទៀងផ្ទាត់ចំណូលថវិកាជាតិប្រចាំឆ្នាំនីមួយៗ ប្រភព៖ (២០១១-២០២០) រវាងអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ

កំណត់សម្គាល់៖ សន្មតអត្រាប្តូរប្រាក់ ១ ដុល្លារសហរដ្ឋអាមេរិក = ៤០០០ រៀល

ស្របតាមរំហូរបែបបទនៃការរៀបចំគម្រោងថវិកាជាតិ ផែនការចំណូលពន្ធដារប្រចាំឆ្នាំ ដែលអគ្គនាយកដ្ឋានពន្ធដារត្រូវសម្រេចឱ្យបានតាមការកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការ គ្រប់គ្រងប្រចាំឆ្នាំនីមួយៗ ដែលមានន័យដ៏សាមញ្ញថា ជារៀងរាល់ឆ្នាំ តាមរយៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជរដ្ឋាភិបាលបានធ្វើការកំណត់ផែនការចំណូលពន្ធដារដ៏ជាក់លាក់ និងសមស្រប មួយជូនអគ្គនាយកដ្ឋានពន្ធដារ ដើម្បីប្រមូលចំណូលពន្ធដារបង់ចូលថវិកាជាតិ។

ដ្យាក្រាមទី១៖ ចំណូលពន្ធដារ (ឆ្នាំ២០១១-២០២០)*




| ឆ្នាំ | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 |
|---|---|---|---|---|---|---|---|---|---|---|
| ចំណូល (ប៊ីលានរៀល) | 2,360.05 | 3,036.32 | 3,604.89 | 4,267.99 | 5,210.22 | 6,010.48 | 7,904.06 | 8,791.66 | 11,279.25 | 11,608.83 |
| ចំណូល (លានដុល្លារ)** | 590.01 | 759.08 | 901.22 | 1,067.00 | 1,302.56 | 1,502.62 | 1,976.02 | 2,197.92 | 2,819.33 | 2,902.21 |
| ផែនការ (ប៊ីលានរៀល) | 2,655.37 | 2,944.43 | 3,463.61 | 3,975.16 | 4,659.50 | 5,686.26 | 6,863.30 | 7,693.50 | 9,153.63 | 11,543.31 |
| ផែនការ (លានដុល្លារ)** | 663.84 | 736.11 | 865.90 | 993.79 | 1,164.88 | 1,421.56 | 1,715.83 | 1,923.38 | 2,288.41 | 2,885.83 |
| %កំណើននៃចំណូល | 88.88% | 103.12% | 104.08% | 107.37% | 111.82% | 105.70% | 115.16% | 114.27% | 123.22% | 100.57% |

ប្រភព៖ ទិន្នន័យចំណូលពន្ធដារដកស្រង់ចេញពីតារាងផ្លូវផ្គងចំណូលថវិកាជាតិប្រចាំឆ្នាំនីមួយៗ (២០១១-២០២០) រវាងអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ (សម្រាប់ទិន្នន័យចំណូលពន្ធដារពីឆ្នាំ១៩៩៤-២០២០

កំណត់សម្គាល់៖ តារាងផ្លូវផ្គងចំណូលថវិកាជាតិប្រចាំឆ្នាំនីមួយៗ រវាងអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ គឺជាតួលេខដែលកំណត់យកជាផ្លូវការដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពី ចំណូលពន្ធដារសរុបជាក់ស្តែងប្រចាំឆ្នាំនីមួយៗ

**សន្មតអត្រាប្តូរប្រាក់ ១ ដុល្លារសហរដ្ឋអាមេរិក = ៤០០០ រៀល

នៅក្នុងដ្យាក្រាមទី១ខាងលើបង្ហាញពីស្ថានភាពចំណូលពន្ធដារក្នុងមួយឆ្នាំៗធៀបទៅនឹងតួលេខផែនការច្បាប់ ដែលមានកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ ដែលរំលេចឱ្យឃើញច្បាស់ថា ជារៀងរាល់ឆ្នាំចាប់ពីឆ្នាំ២០១៣ ដល់ឆ្នាំ២០២០ អគ្គនាយកដ្ឋានពន្ធដារ តែងតែសម្រេចបានលើសផែនការដែលមានកំណត់ក្នុងច្បាប់ជានិច្ច។

ជាក់ស្តែង ក្នុងរយៈពេល៨ឆ្នាំជាប់គ្នាកន្លងមកនេះ (២០១៣-២០២០) បើគិតជាមធ្យមភាគចំណូលពន្ធដារប្រចាំឆ្នាំដែលអគ្គនាយកដ្ឋានពន្ធដារសម្រេចបានប្រៀបធៀបទៅនឹងតួលេខ ផែនការដែលមានកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ គឺក្នុងរង្វង់ប្រមាណ ១០,២៧%។ (សម្រាប់ព័ត៌មានបន្ថែមសូមពិនិត្យមើលដ្យាក្រាមទី២ ខាងក្រោម)



ដ្យាក្រាមទី២៖ ចំណូលពន្ធដារប្រមូលបានប្រចាំឆ្នាំនីមួយៗលើសផែនការច្បាប់កំណត់

ប្រភព៖ ទិន្នន័យចំណូលពន្ធដារដកស្រង់ចេញពីតារាងផ្លូផ្គងចំណូលថវិកាជាតិប្រចាំឆ្នាំនីមួយៗ (២០១១-២០២០) រវាងអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ

ដូចគ្នានេះដែរ បើយើងធ្វើការប្រៀបធៀបកំណើនចំណូលពន្ធពីមួយឆ្នាំទៅមួយឆ្នាំដែល អគ្គនាយកដ្ឋានពន្ធដារសម្រេចបានក្នុងរយៈពេល៨ឆ្នាំដូចបានលើកឡើងខាងលើ គិតជាមធ្យម គឺ ស្មើនឹងប្រមាណ ១៨,៦% ក្នុងមួយឆ្នាំៗ។ (សម្រាប់ព័ត៌មានបន្ថែមសូមពិនិត្យមើលដ្យាក្រាមទី៣ ខាងក្រោម)

ដ្យាក្រាមទី៣៖ មធ្យមភាគនៃកំណើនចំណូលពន្ធដារប្រមូលបានក្នុងរយៈពេល៨ឆ្នាំ




| ឆ្នាំ | 2013/ 2012 | 2014/ 2013 | 2015/ 2014 | 2016/ 2015 | 2017/ 2016 | 2018/ 2017 | 2019/ 2018 | 2020/ 2019 | ជាមធ្យម 2013-2020 |
|---|---|---|---|---|---|---|---|---|---|
| ចំណូល (ប៊ីលានរៀល) | 568.57 | 663.10 | 942.23 | 800.26 | 1,893.58 | 887.60 | 2,487.58 | 331.51 | 1,071.56 |
| %កំណើននៃចំណូល | 18.7% | 18.4% | 22.1% | 15.4% | 31.5% | 11.2% | 28.3% | 2.9% | 18.6% |

កំណត់សម្គាល់៖ ចំណូលពន្ធឆ្នាំ២០១២ មានចំនួន ៣,០៣៦.៣២ ប៊ីលានរៀល

សូមបញ្ជាក់ផងដែរថា អគ្គនាយកដ្ឋានពន្ធដារនៅតែអាចសម្រេចបាននូវលទ្ធផលចំណូល ពន្ធដារប្រកបដោយជោគជ័យគួរជាទីមោទនៈ បើទោះបីជាត្រូវបានចូលរួមយ៉ាងសកម្មក្នុងការអនុវត្ត គោលនយោបាយលើកទឹកចិត្តរបស់រាជរដ្ឋាភិបាល តាមរយៈការលើកលែងពន្ធលើវិស័យអាទិភាព មួយចំនួន ដែលស្ថិតក្នុងបរិបទជារួម **ស្របតាមគោលការណ៍៤ចំណុចនៃយុទ្ធសាស្រ្តកៀរគរចំណូល រយៈពេលមធ្យម ២០១៤-២០១៨** ជាអាទិ៍៖ (១). ប្រមូលឱ្យអស់លទ្ធភាពនូវសក្តានុពលប្រមូល ចំណូលដែលមាននាពេលបច្ចុប្បន្ន (២). មិនបង្កើតប្រភេទពន្ធថ្មី (៣). មិនដំឡើងអត្រាពន្ធ និង អាករលើកលែងតែក្នុងករណីប៉ះប៉ូវដល់ការបាត់ចំណូល និងការការពារសុខភាព និង/ឬការការពារ បរិស្ថាន និង(៤). ធានាឱ្យបាននូវភាពងាយស្រួល សមធម៌ និងយុត្តិធម៌ ព្រមទាំងធានាបាននូវប្រសិទ្ធភាព តម្លាភាពនិងគណនេយ្យភាពក្នុងការគ្រប់គ្រង និងប្រមូលចំណូលពន្ធ និង**ត្រូវប្រកាន់ ខ្ជាប់នូវអភិក្រម ៤ចំណុច នៃយុទ្ធសាស្រ្តកៀរគរចំណូល ២០១៩-២០២៣** គឺ៖ (១) ធានា បីរភាពកំណើនសេដ្ឋកិច្ច (២). រក្សាបាននូវបីរភាពចំណូលដែលឈានទៅដល់កម្រិតឧត្តមានុពល (optimal level) (៣). ធានានូវយុត្តិធម៌ក្នុងការអនុវត្តគោលនយោបាយសារពើពន្ធ និង មិនមែន សារពើពន្ធ ព្រមទាំងការប្រមូលចំណូល និង(៤). ធានានូវសមធម៌សង្គម ដើម្បីចូលរួមចំណែក បន្ធូរបន្ថយបន្ទុកពន្ធដល់ប្រជាជនមានចំណូលទាប បង្កើនសុខុមាលភាពប្រជាពលរដ្ឋ និងរក្សា ការពារបរិស្ថាន។

សម្រាប់ឆ្នាំ២០២០ ជាឆ្នាំទី២ ដែលអគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងអនុវត្តយុទ្ធសាស្រ្ត កៀរគរចំណូល ២០១៩-២០២៣ បន្ទាប់ពីអគ្គនាយកដ្ឋានពន្ធដារសម្រេចបាននូវលទ្ធផលចំណូល ពន្ធដារដ៏ល្អប្រសើរក្នុងឆ្នាំទី១ (២០១៩) ដោយសម្រេចបានលើសផែនការកំណត់កម្រិតខ្ពស់ថ្មី ឆ្នាំ២០១៩ ក្រោយ មួយក្នុងរង្វង់ប្រមាណ ២៣,២២% នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ក្រោយពីទទួលបានជោគជ័យលើការគ្រប់គ្រងចំណូលពន្ធ ស្របតាមយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨។ ជាក់ស្តែង ក្នុងឆ្នាំ២០២០ អគ្គនាយកដ្ឋានពន្ធដារនៅតែបន្តសម្រេច បានលទ្ធផលចំណូលពន្ធដារដ៏ល្អប្រសើរដដែល គឺមានចំនួន ១១ ៦០៨,៨៣ ប៊ីលានរៀល (ស្មើនឹង ប្រមាណ ២ ៩០២,២១ លានដុល្លារ) ទោះបីជាប្រទេសកម្ពុជា ក៏ដូចជាសកលលោកទាំងមូលបាន ប្រឈម និងទទួលរងផលប៉ះពាល់ដ៏ធ្ងន់ធ្ងរពីវិបត្តិវិករាលដាលដ៏សាហាវនៃជំងឺកូវីដ-១៩ ដែលបាន បង្កឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងដល់វិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសុខភាពប្រជាពលរដ្ឋជាទូទៅ ក៏ដោយ។ បើគិតជាភាគរយគឺស្មើនឹង ១០០,៥៧% នៃផែនការកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ពោលគឺលើសផែនការកំណត់ចំនួនប្រមាណ ៦៥,៥២ ប៊ីលានរៀល (ស្មើនឹងប្រមាណ ១៦,៣៨ លានដុល្លារ)។ បើប្រៀបធៀបចំណូលពន្ធដារសរុបក្នុងឆ្នាំ២០២០នេះ ទៅនឹងចំណូលពន្ធដារសរុបក្នុងឆ្នាំ២០១២ គឺមានការកើនឡើងជិតបួនដងពោលគឺមានការកើន ឡើងចំនួន ៨ ៥៧២,៥១ ប៊ីលានរៀល (ស្មើនឹងប្រមាណ ២ ១៤៣,១៣ លានដុល្លារ) នៃចំណូល ពន្ធដារសរុបក្នុងឆ្នាំ២០១២ ដែលមានចំនួនត្រឹម ៣ ០៣៦,៣២ ប៊ីលានរៀល (ស្មើនឹងប្រមាណ ៧៥៩,០៨ លានដុល្លារ)។ (សម្រាប់ព័ត៌មានបន្ថែម សូមពិនិត្យមើលជ្យាក្រាមទី៤ ខាងក្រោមនេះ)។




តាមរយៈនិន្នាការនៃការបន្តកើនឡើងជាលំដាប់នៃចំណូលពន្ធដារពីមួយឆ្នាំទៅមួយឆ្នាំ ក្នុង រយៈពេល ៨ឆ្នាំកន្លងទៅនេះ បានឆ្លុះបញ្ចាំងឱ្យឃើញច្បាស់ថាចំណូលពន្ធដារ ឬចំណូលពន្ធផ្ទៃក្នុង ដែលគ្រប់គ្រង និង ប្រមូលដោយអគ្គនាយកដ្ឋានពន្ធដារ រឹតតែមានតួនាទី និងមានចំណែកដ៏ធំចំពោះ ការផ្គត់ផ្គង់ថវិកាជាតិ សម្រាប់គាំទ្រដល់ការផ្តល់សេវាសាធារណៈ និងសង្គមទាំងមូលឱ្យកាន់តែមាន ភាពល្អប្រសើរឡើងជាលំដាប់ ព្រមទាំងសម្រាប់បន្តអភិវឌ្ឍប្រទេសជាតិឱ្យបានរីកចម្រើនរុងរឿង ប្រកបដោយចីរភាព និងយូរអង្វែង។




### ៣.២.៣ ចំណូលតាមប្រភេទពន្ធ

ជារួម កំណើនចំណូលពន្ធដារ ឬចំណូលពន្ធផ្ទៃក្នុងដែលអគ្គនាយកដ្ឋានពន្ធដារប្រមូល បានក្នុងរយៈពេល៨ឆ្នាំកន្លងទៅនេះ គឺបានមកពីគ្រប់ប្រភេទពន្ធ-អាករទាំងអស់។ ក្នុងរយៈពេល៨ឆ្នាំ (២០១៣-២០២០) ប្រភេទពន្ធ-អាករចំនួន៥ ប្រភេទដែលមានទំហំសមាមាត្រ និងមានកំណើនគួរឱ្យកត់សម្គាល់ជាងគេគឺមានពន្ធលើប្រាក់ចំណូល អាករលើតម្លៃបន្ថែម អាករពិសេសលើទំនិញនិងសេវាមួយចំនួន ពន្ធលើប្រាក់បៀវត្ស និងពន្ធ ប្រថាប់ត្រា។ ជាក់ស្តែង បើប្រៀបធៀបទៅនឹងលទ្ធផលនៃការប្រមូលចំណូលពន្ធ-អាករ ឆ្នាំ២០២០ ទៅនឹងឆ្នាំ២០១២ យើងពិនិត្យឃើញថា៖ (១). ពន្ធលើប្រាក់ចំណូលមានទំហំសមាមាត្រធំជាងគេ

បំផុតនៃចំណូលពន្ធ-អាករសរុប និងមានការកើនឡើងប្រមាណ ៥០២,៧% (២). អាករលើតម្លៃបន្ថែមមានទំហំសមាមាត្រធំជាងគេលំដាប់ទីពីរនៃចំណូលពន្ធ-អាករសរុប គឺមានការកើនឡើង ប្រមាណ ៣០២,៦% (៣). អាករពិសេសលើទំនិញនិងសេវាមួយចំនួនមានទំហំសមាមាត្រធំជាងគេ លំដាប់ទីបីនៃចំណូលពន្ធអាករសរុប គឺមានការកើនឡើងប្រមាណ ២៦៦,៧% (៤). ពន្ធលើ ប្រាក់បៀវត្សមានទំហំសមាមាត្រធំជាងគេលំដាប់ទីបួននៃចំណូលពន្ធ-អាករសរុប គឺមានការកើនឡើង ដល់ប្រមាណ ៣៩៣,២% និង(៥). ពន្ធប្រថាប់ត្រាដែលមានទំហំសមាមាត្រធំជាងគេលំដាប់ទីប្រាំ នៃចំណូលពន្ធ-អាករសរុប គឺមានការកើនឡើងដល់ ៥៣៦,៥%។

តារាងទី២៖ ទិន្នន័យចំណូលពន្ធតាមប្រភេទពន្ធ-អាករសំខាន់ៗ (២០១២-២០២០)




| ប្រភេទពន្ធ-អាករសំខាន់ៗ (ប៊ីលានរៀល) | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 | ឆ្នាំ 2020 ធៀបឆ្នាំ 2012 |
|---|---|---|---|---|---|---|---|---|---|---|
| ពន្ធលើប្រាក់ចំណូល | 966.60 | 1,167.23 | 1,446.19 | 1,841.51 | 2,181.89 | 2,841.31 | 3,354.30 | 4,197.44 | 4,858.78 | 502.7% |
| អាករលើតម្លៃបន្ថែម | 889.25 | 1,073.08 | 1,172.50 | 1,317.55 | 1,528.94 | 2,159.86 | 2,101.25 | 2,772.68 | 2,690.86 | 302.6% |
| អាករពិសេស | 360.32 | 417.10 | 472.31 | 549.41 | 677.83 | 795.13 | 865.33 | 1,130.46 | 960.94 | 266.7% |
| ពន្ធលើប្រាក់បៀវត្ស | 234.15 | 300.71 | 389.89 | 462.37 | 557.10 | 677.52 | 704.85 | 847.82 | 920.63 | 393.2% |
| ពន្ធប្រថាប់ត្រា | 154.22 | 181.86 | 278.99 | 342.96 | 273.58 | 454.92 | 660.27 | 942.00 | 827.42 | 536.5% |

### ៣.២.៤. ចំណូលពន្ធតាមប្រភេទអ្នកជាប់ពន្ធ

នៅក្នុងតារាងទី៣ ខាងក្រោមបានបង្ហាញពីស្ថានភាពចំណូលពន្ធដារ តាមប្រភេទអ្នកជាប់ពន្ធ ក្នុងរយៈពេល ៨ឆ្នាំ (២០១៣-២០២០)។ សូមកត់ចំណាំផងដែរថា មុនឆ្នាំ២០១៦ ប្រភេទអ្នក ជាប់ពន្ធត្រូវបានបែងចែកជាពីរប្រភេទ គឺប្រភេទអ្នកជាប់ពន្ធតាមរបបពិត ឬតាមរបបស្វ័យប្រកាស និងអ្នកជាប់ពន្ធតាមរបបម៉ៅការ។ ចាប់ពីឆ្នាំ២០១៦មក របបម៉ៅការត្រូវបានលុបបំបាត់ចោល ដោយតម្រូវឱ្យមានតែរបបស្វ័យប្រកាសតែមួយប៉ុណ្ណោះ ហើយនៅក្នុងនោះអ្នកជាប់ពន្ធត្រូវបាន បែកចែកជាអ្នកជាប់ពន្ធធំ អ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធតូច (អ្នកជាប់ពន្ធផ្សេងៗទៀត ដូចជាអ្នកបង់ពន្ធលើអចលនទ្រព្យ និង/ឬអ្នកបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះ គ្រប់ប្រភេទ។ល។)

តារាងទី៣៖ ចំណូលពន្ធដារតាមប្រភេទអ្នកជាប់ពន្ធ (២០១៣-២០២០)




| ឆ្នាំ | របបស្វ័យប្រកាស | | | របបម៉ៅការ | អ្នកជាប់ពន្ធផ្សេងៗ* |
|---|---|---|---|---|---|
| | អ្នកជាប់ពន្ធធំ | អ្នកជាប់ពន្ធមធ្យម | អ្នកជាប់ពន្ធតូច | | |
| 2013 | 93.0% | | | 7.0% | - |
| 2014 | 98.8% | | | 1.2% | - |
| 2015 | 98.9% | | | 1.1% | - |
| 2016 | 71.6% | 20.6% | 1.2% | - | 6.6% |
| 2017 | 72.9% | 16.0% | 0.9% | - | 10.3% |
| 2018 | 70.7% | 15.8% | 1.0% | - | 12.6% |
| 2019 | 70.8% | 15.1% | 0.8% | - | 13.3% |
| 2020 | 72.2% | 14.9% | 0.7% | - | 12.1% |

នៅក្នុងតារាងទី៣ខាងលើបង្ហាញឱ្យឃើញថា បើគិតជាមធ្យមភាគក្នុងរយៈពេល៥ឆ្នាំ(២០១៦-២០២០)៖ ចំណូលពន្ធពីអ្នកជាប់ពន្ធធំមានចំណែកធំជាងគេ គឺមានប្រមាណ ៧១,៦៤% នៃចំណូលពន្ធសរុប។ ចំណូលពន្ធពីអ្នកជាប់ពន្ធមធ្យម មានចំណែកធំជាងគេលំដាប់ទីពីរ គឺមានប្រមាណ ១៦,៤៨% នៃចំណូលពន្ធសរុប។ ចំណូលពន្ធពីអ្នកជាប់ពន្ធតូច គឺមានចំណែក តូចជាងគេបំផុតប្រមាណ ០,៩២% នៃចំណូលពន្ធសរុប។ ចំណែកឯចំណូលពន្ធពីអ្នកជាប់ពន្ធ ផ្សេងៗទៀតមានចំណែកធំជាងគេលំដាប់ទីបី គឺមានត្រឹមតែប្រមាណ ១០,៩៦% នៃចំណូលពន្ធសរុប ប៉ុណ្ណោះ។

## ៣.៣ នីតិវិធីក្នុងការអនុវត្តលើកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា

### ៣.៣.១ នីតិវិធីនៃការអនុវត្ត (DTA)

ក. លិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ

ដើម្បីឱ្យកិច្ចព្រមព្រៀង DTA មួយមានប្រសិទ្ធភាពអនុវត្ត ត្រូវមាន÷

- ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធ ត្រួតគ្នា និងការបង្ការការកិបកេងបន្លំ ពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល (កិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា DTA)
- ច្បាប់ស្តីពីសារពើពន្ធ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ ប្រកាសស្តីពីការអនុវត្តកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការ បង្ការការកិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល
- សេចក្តីណែនាំ (លេខ ០២០ សហវ, លេខ ៤០៨៤ អពដ, លេខ ១១៨១៥ អពដ, លេខ ៦២១៥ អពដ)

ខ. វិសាលភាពនៃ DTA

- DTA មានវិសាលភាពអនុវត្តលើនិវាសនជននៃភាគីនៃកិច្ចព្រមព្រៀង (អ្នកជាប់ពន្ធ) តែប៉ុណ្ណោះ និងត្រូវអនុវត្តចំពោះបណ្តាពន្ធលើប្រាក់ ចំណូលមួយចំនួន ដូចមានចែងលម្អិតក្នុង DTA នីមួយៗ។

គ. នីតិវិធីស្នើសុំអត្ថប្រយោជន៍ក្រោម DTA

អ្នកជាប់ពន្ធអាចទទួលបានអត្ថប្រយោជន៍ជាច្រើនពី DTA ហើយ អត្ថប្រយោជន៍សំខាន់ៗ មានដូចជា៖

- **ការទទួលបានការអនុញ្ញាតបន្ធូរបន្ថយពន្ធ ឬលើកលែងពន្ធកាត់ទុក និងបណ្តាប្រភេទពន្ធទាក់ទិននឹងប្រាក់ចំណូល ដែលទទួលបានពី ប្រតិបត្តិការនៃយន្តហោះ, នាវាឬទូក ឬតាមផ្លូវដែកឬផ្លូវគោកក្នុង ចរាចរណ៍អន្តរជាតិ ក្រោម DTA៖** អ្នកជាប់ពន្ធត្រូវមានការអនុញ្ញាត ពីអគ្គនាយកដ្ឋានពន្ធដារជាមុនសិន ដោយត្រូវដាក់ពាក្យស្នើសុំតាម ប្រព័ន្ធ Online និងភ្ជាប់មកជាមួយនូវឯកសារមួយចំនួនដូចជា៖

**ឯកសារតម្រូវសម្រាប់ការស្នើសុំ ចំពោះនីតិបុគ្គល៖**

- អត្តសញ្ញាណប័ណ្ណ/ លិខិតឆ្លងដែន៖ ថតចម្លង និង មានបញ្ជាក់ (Identification Card/Passport)
- វិញ្ញាបនបត្រនិវាសនជន៖ ច្បាប់ដើម ( Certificate of Residence)
- កិច្ចសន្យា/ឯកសារពាក់ព័ន្ធនឹងការទូទាត់ ÷ ថតចម្លង និង មានបញ្ជាក់ ( Contract/document related to income payment)
- លិខិតផ្ទេរសិទ្ធិ៖ច្បាប់ដើម ( Authorization Letter)
- ប៉ាតង់ក្រុមហ៊ុននៅខ្មែរ (អ្នកទូទាត់)៖ ថតចម្លង ( Patent Tax)
- វិញ្ញាបនបត្រនិវាសនជន៖ ច្បាប់ដើម ( Certificate of Residence)
- វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនដើម៖ ថតចម្លង និង មានបញ្ជាក់( Contract/document related to income payment)
- លិខិតផ្ទេរសិទ្ធិ ÷ ច្បាប់ដើម ( Authorization Letter)
- ប៉ាតង់ក្រុមហ៊ុននៅខ្មែរ (អ្នកទូទាត់) ÷ ថតចម្លង ( Patent Tax)
- នៅពេលអ្នកជាប់ពន្ធបានដាក់ពាក្យស្នើសុំ និងភ្ជាប់ឯកសារត្រឹមត្រូវនិងគ្រប់ ចំនួនហើយត្រូវបានពិនិត្យឃើញថាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់អគ្គនាយកដ្ឋានពន្ធដារនឹងចេញលិខិតជូនដំណឹងស្តីពីការផ្តល់អត្ថប្រយោជន៍ ក្រោម DTA ក្នុងរយៈពេល១៤ថ្ងៃ។
- នៅពេលដែលអគ្គនាយកដ្ឋានពន្ធដារចេញលិខិតជូនដំណឹង ស្តីពីការផ្តល់អត្ថប្រយោជន៍ក្រោម DTA អ្នកជាប់ពន្ធនឹងទទួលបានសារជូនដំណឹង តាម រយៈទូរស័ព្ទដៃ ឬសារអេឡិចត្រូនិក។
- **ការទទួលបានឥណទានពន្ធលើបណ្តាប្រភេទពន្ធ ដែលបានបង់នៅ ប្រទេសប្រភព ពីប្រទេសនិវាសនដ្ឋានរបស់អ្នកជាប់ពន្ធ៖** អ្នកជាប់ពន្ធអាចស្នើសុំលិខិតបញ្ជាក់ការបង់ពន្ធ ពីអង្គភាពកំណត់ពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារដែលខ្លួនស្ថិតនៅ ដើម្បីជាមូលដ្ឋានសម្រាប់ យកទៅប្រើប្រាស់ក្នុងការស្នើសុំឥណទានពន្ធ ពីប្រទេសនិវាសដ្ឋាន របស់ខ្លួន។

ឥណទានពន្ធ និងការកាត់បន្ថយពន្ធ

- អនុលោមតាមច្បាប់សារពើពន្ធរបស់កម្ពុជា និងកិច្ចព្រមព្រៀង DTA នេះ ពន្ធកម្ពុជាដែលត្រូវបង់ដោយអ្នកជាប់ពន្ធជានិវាសនជន នៃភាគីកិច្ចព្រមព្រៀងម្ខាង ទៀត ទាក់ទងនឹងប្រាក់ចំណូលដែលបានមកពីប្រទេសកម្ពុជា ត្រូវអនុញ្ញាតជា ឥណទានពន្ធដែលត្រូវបង់ទាក់ទងនឹងប្រាក់ចំណូលនោះនៅប្រទេសនិវាសដ្ឋាន របស់អ្នកជាប់ពន្ធនោះ។
- ពាក្យថា "ពន្ធកម្ពុជាដែលត្រូវបង់" ត្រូវចាត់ទុកថារួមបញ្ចូលចំនួនពន្ធកម្ពុជា ដែលត្រូវបង់ ទោះបីជាពន្ធកម្ពុជានោះ ត្រូវបានលើកលែង ឬកាត់បន្ថយ ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងបទ

ប្បញ្ញត្តិដែលពាក់ព័ន្ធ ឬ វិធានការលើកទឹកចិត្តពិសេសណាមួយផ្សេងទៀតដែលរៀបចំឡើងដើម្បីលើកកម្ពស់ការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅកម្ពុជា។

**ឃ. សុពលភាពអនុវត្តសម្រាប់អត្ថប្រយោជន៍ក្រោម DTA**

- **សម្រាប់ការស្នើសុំដំបូង៖** អត្ថប្រយោជន៍ក្រោម DTA នឹងមានប្រសិទ្ធភាព អនុវត្តគិតចាប់ពីថ្ងៃចុះហត្ថលេខាតទៅ រហូតដល់ដំណាច់ឆ្នាំជាប់ពន្ធចរន្ត។
- **សម្រាប់ការស្នើសុំបន្ត**៖ អត្ថប្រយោជន៍បន្តក្រោម DTA នឹងមានប្រសិទ្ធភាព អនុវត្តសម្រាប់រយៈពេលមួយឆ្នាំពេញដោយចាប់គិតពីថ្ងៃទី០១ ខែមករា នៃ ឆ្នាំជាប់ពន្ធចរន្ត ក្នុងករណីអ្នកជាប់ពន្ធទទួលបានការអនុញ្ញាតឱ្យបន្តអត្ថប្រយោជន៍ក្រោម DTA ពីអគ្គនាយកដ្ឋានពន្ធដារ។ ក្នុងករណីអ្នកជាប់ពន្ធពុំទាន់ ទទួលបានការអនុញ្ញាតឱ្យបន្តអត្ថប្រយោជន៍ក្រោម DTA នេះ អ្នកជាប់ពន្ធ ត្រូវអនុវត្តកាតព្វកិច្ចសារពើពន្ធតាមច្បាប់និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារជា ធរមាន។
- នៅពេលអ្នកជាប់ពន្ធបានដាក់ពាក្យស្នើសុំ និងភ្ជាប់ឯកសារត្រឹមត្រូវនិងគ្រប់ចំនួនហើយត្រូវបានពិនិត្យឃើញថាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ អគ្គនាយកដ្ឋានពន្ធដារនឹងចេញលិខិតជូនដំណឹងស្តីពីការផ្តល់អត្ថប្រយោជន៍ ក្រោម DTA ក្នុងរយៈពេល១៤ថ្ងៃ។
- នៅពេលដែលអគ្គនាយកដ្ឋានពន្ធដារចេញលិខិតជូនដំណឹង ស្តីពីការផ្តល់អត្ថប្រយោជន៍ក្រោម DTA អ្នកជាប់ពន្ធនឹងទទួលបានសារជូនដំណឹង តាម រយៈទូរស័ព្ទដៃ ឬសារអេឡិចត្រូនិក។

**៣.៣.២ ក្របខ័ណ្ឌគោលនយោបាយ និងគោលការណ៍ចម្បងៗសម្រាប់ការចរចា**

❖ **ក្របខ័ណ្ឌគោលនយោបាយ**

ក្នុងគោលដៅកាត់បន្ថយនូវផលប៉ះពាល់ជាអវិជ្ជមានជាយថាហេតុពីកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា កម្ពុជាបានប្រកាន់ខ្ជាប់នូវជំហររបស់ខ្លួនស្របតាមក្របខ័ណ្ឌគោលនយោបាយ ដែលបានដាក់ចេញដើម្បីការពារឱ្យបានជាអតិបរមានូវសិទ្ធិយកពន្ធរបស់ខ្លួនដែលសម្រេចបាននូវ៖

១. លក្ខខណ្ឌដែលបានផ្តល់ប្រយោជន៍ដល់កម្ពុជា ក្នុងការកំណត់ពន្ធតាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍។
២. ការយកពន្ធលើបុព្វលាភធានារ៉ាប់រង ដែលលក់ដោយសហគ្រាសអនិវាសនជន។
៣. ការយកពន្ធលើការដឹកជញ្ជូនអន្តរជាតិតាមផ្លូវទឹក។
៤. ការយកពន្ធលើសួយសារពីការជួលឧបករណ៍ឧស្សាហកម្ម ពាណិជ្ជកម្ម និងវិទ្យាសាស្ត្រ។
៥. ការយកពន្ធកាត់ទុកលើថ្លៃឈ្នួលសេវាបច្ចេកទេស។
៦. ការរក្សាបាននូវពន្ធកាត់ទុកខ្ពស់ចៀសវាងបាននូវផលប៉ះពាល់ខ្លាំងទៅលើចំណូលពន្ធជាតិ។
៧. ការអនុគ្រោះពន្ធដល់ចំណូលរបស់សាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវអនិវាសនជន។
៨. ការយកពន្ធលើចំណូលផ្សេងៗរបស់អនិវាសនជន។
៩.ការដាក់បញ្ចូលនូវគោលការណ៍លើកទឹកចិត្តសម្រាប់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដែលមានប្រយោជន៍សម្រាប់ធនាបាននូវភាពទាក់ទាញនៃការវិនិយោគផ្ទាល់មកពីបរទេសតាមរយៈការផ្តល់ការលើកទឹកចិត្តផ្នែកពន្ធដារ ដែលមានចែងក្នុងច្បាប់ស្តីពីវិនិយោគរបស់កម្ពុជា។

ទន្ទឹមនិងនេះ សេចក្តីព្រាងគំរូកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នារបស់កម្ពុជាត្រូវបានរៀបចំឡើង និងផ្តោតទៅលើគោលការណ៍សំខាន់ៗមួយចំនួន ដូចខាងក្រោម៖

ក. ការការពារសិទ្ធិយកពន្ធសម្រាប់ប្រទេសប្រភព មាត្រា៦ស្តីពីចំណូលអចលនទ្រព្យ **(Income from Immovable Property)**៖ផ្តល់សិទ្ធិយកពន្ធសម្រាប់តែប្រទេស ដែលមានទីតាំងជាក់ស្តែងនៃអចលនទ្រព្យស្ថិតនៅនោះ។

ខ. **មាត្រា៧ ស្តីពីប្រាក់ចំណេញអាជីវកម្ម (Business Profits)៖** កម្ពុជាបានជ្រើសរើសយកតាមគំរូ UN ដោយហេតុថា គំរូនេះផ្តល់សិទ្ធិដល់ប្រទេសប្រភពច្រើនលើការយកពន្ធលើប្រាក់ចំណេញអាជីវកម្ម ដោយបានបន្ថែមការយកពន្ធលើទំនិញ និងសេវាប្រហាក់ប្រហែល ដែលហៅថា **Force of Attraction Rule** ។ ក្នុងមាត្រានេះ កម្ពុជាក៏បានបញ្ចូលកថាខណ្ឌថ្មីដែលទាក់ទិននិងការយកពន្ធលើវិស័យធានារ៉ាប់រង ដើម្បីឱ្យសង្គតិភាពជាមួយនឹងច្បាប់ស្តីពីសារពើពន្ធប្រទេសកម្ពុជា។

គ. **មាត្រា៨ ស្តីពីការដឹកជញ្ជូនអន្តរជាតិ (International Transport)៖** ជាទូទៅប្រទេសជាប្រភពមិនមានសិទ្ធិយកពន្ធលើប្រាក់ចំណូល ដែលទទួលបានពីការដឹកជញ្ជូនអន្តរជាតិនោះទេ ដែលអាចធ្វើឱ្យកម្ពុជាបាត់បង់ចំណូលពីការយកពន្ធលើវិស័យនេះ នៅពេលដែលកម្ពុជាចុះកិច្ចព្រមព្រៀងជាមួយបណ្តាលប្រទេសជាភាគី។ ជាគោលនយោបាយសម្រាប់ការចរចា កម្ពុជាបានស្នើសុំសិទ្ធិយកពន្ធចំនួន៥០%លើប្រាក់ចំណូលដែលបានមកការដឹកជញ្ជូនជាអន្តរជាតិតាមផ្លូវទឹក (សម្រាប់ប្រទេសដែលមានព្រំប្រទល់ជាប់និងកម្ពុជា ក៏មានការរួមបញ្ចូលទាំងការដឹកជញ្ជូនតាមផ្លូវគោក និងផ្លូវដែកផងដែរ) និងបោះបង់ចោលសិទ្ធិយកពន្ធលើប្រាក់ចំណូល ដែលបានការដឹកជញ្ជូនជាអន្តរជាតិតាមផ្លូវអាកាស។

**៣.៣.២.១ ពន្ធកាត់ទុកនៅក្នុងមាត្រា១០ស្តីពីភាគលាភ មាត្រា១១ស្តីពីការប្រាក់ និងមាត្រា១២ស្តីពី សួសសារ**

សម្រាប់មាត្រាស្តីពីពន្ធកាត់ទុក រដ្ឋភាគីនៃកិច្ចព្រមព្រៀងទាំងសងខាងមានសិទ្ធិយកពន្ធលើប្រាក់ចំណូលបានបែកចែកភាគលាភ ការប្រាក់ និងសួយសារដោយប្រទេសប្រភពមានសិទ្ធិយកពន្ធតាមអាត្រាដែលបានកំណត់ក្នុងច្បាប់ស្តីពីសារពើពន្ធរបស់ខ្លួន និងមិនលើសពីអាត្រាកំណត់នៅក្នុងកិច្ចព្រមព្រៀង។ជាទូទៅ អាត្រាពន្ធកាត់ទុកដែលបានឯកភាពនៅក្នុងកិច្ចព្រមព្រៀង ដែលចុះហត្ថលេខារួច គឺទាបជាងអាត្រាពន្ធដែលមាននៅក្នុងច្បាប់ក្នុងស្រុកប្រទេសនីមួយៗ ដើម្បីទាក់ទាញវិនិយោគ រំហូរមូលធន និងការផ្ទេរបច្ចេកវិទ្យា និងជំនាញពីបរទេស។ ជាជំហរសម្រាប់ការចរចា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានទទួលការឯកភាពជាគោលការណ៍ដ៏ខ្ពង់ខ្ពស់ពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ឱ្យមានភាពទន់ភ្លន់លើអាត្រាពន្ធការទុក ១៤% ដែលមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធនៅក្នុងចន្លោះពី ១៤% មក ១០% វិញតាមរយៈលិខិតលេខ ១០១៨៥សហវ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**៣.៣.២.២ ការដាក់បញ្ចូលបញ្ញត្តិស្តីពីករណីលើកលែងពិសេសដល់ភាគីដែលប្រទេសកំពុងអភិវឌ្ឍន៍**(Tax Sparing Credit)

បញ្ញត្តិស្តីករណីលើកលែងពិសេសដល់ភាគីប្រទេសដែលកំពុងអភិវឌ្ឍន៍ មានចែងក្នុងមាត្រា២៣ នៃកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការយកពន្ធត្រួតគ្នារបស់កម្ពុជាស្តីពីវិធីសាស្ត្រសម្រាប់លុបបំបាត់ការយកពន្ធត្រួតគ្នាដែលជាទូទៅមានវិធីសាស្ត្រចំនួនពីរគឺ៖ **វិធីសាស្ត្រឥណទាន(Credit Method) និងវិធីសាស្ត្រលើកលែងពន្ធ (Exemption Method)**។ ដោយកម្ពុជាជាប្រទេសយកពន្ធលើចំណូលសកល កម្ពុជាបានជ្រើសរើសយកវិធី

សាស្រ្តឥណទាននិងបានបញ្ចូលបញ្ញត្តិស្តីពីករណីលើកលែងពិសេសដល់ភាគីប្រទេសកំពុងអភិវឌ្ឍន៍(Tax Sparing Credit)នេះ ដើម្បីផ្តល់អត្ថប្រយោជន៍ដល់ការទាក់ទាញការវិនិយោគពីបរទេស។ ការលើកលែងពិសេសដល់ភាគី ដែលជាប្រទេសកំពុងអភិវឌ្ឍន៍(Tax Sparing Credit )មានន័យថាទោះបីជាសហគ្រាសដែលស្ថិតនៅក្នុងគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់(QIP)មានប្រាក់ចំណូល ហើយមិនត្រូវជាប់ពន្ធនៅកម្ពុជាដោយសារតែសហគ្រាសនោះស្ថិតនៅក្នុងរយៈពេលនៃការលើកលែងពន្ធក៏ដោយ ក៏ប៉ុន្តែសហគ្រាសនោះត្រូវបានចាត់ទុកថាបានបង់ពន្ធនៅកម្ពុជា និងអាចយកធ្វើឥណទានសម្រាប់កាត់កង ជាមួយពន្ធលើប្រាក់ចំណូលនៅប្រទេសរបស់ខ្លួនផងដែរ។ ជាទូទៅ មាត្រានេះមិនមានក្នុងគំរូសន្ធិសញ្ញាពន្ធផ្សេងៗទេ ប៉ុន្តែមានក្នុងកិច្ចព្រមព្រៀងជាក់ស្តែងមួយចំនួន ដែលធ្លាប់ផ្តល់ចំពោះប្រទេសកំពុងអភិវឌ្ឍន៍។ នេះជាគោលនយោបាយដ៏មានសារសំខាន់បំផុតមួយផ្សេងទៀតសម្រាប់ការចរចា ដោយហេតុថាកម្ពុជាចង់ទាមទារផលប្រយោជន៍សម្រាប់អ្នកវិនិយោគដែលមានការលើកទឹកចិត្ត ក្រោមគម្រោងមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលទទួលបានពីច្បាប់ស្តីពីវិនិយោគរបស់កម្ពុជា។ ដូចនេះ កម្ពុជាត្រូវខិតខំទាមទារដាក់បញ្ចូលឱ្យបាននូវបញ្ញត្តិនេះទៅក្នុងកិច្ចព្រមព្រៀងដែលកម្ពុជាបានចុះហត្ថលេខា។

**៣.៣.២.៣ មាត្រា១៣ស្តីពីសេវាបច្ចេកទេស**

មាត្រា១៣ស្តីពីកម្រៃសេវាបច្ចេកទេស គឺជាមាត្រាពិសេសដែលមានក្នុងសេចក្តីព្រាងគំរូកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការយកពន្ធត្រួតគ្នារបស់កម្ពុជា ដោយពុំមានក្នុងគំរូ UN, OECD និងASEAN មុនឆ្នាំ២០១៧នោះទេ ក៏ប៉ុន្តែមានចែងនៅកិច្ចព្រមព្រៀងបណ្តាលប្រទេសមួយចំនួន ដូចជាប្រទេសម៉ាឡេស៊ី ព្រុយណេ និងប្រទេសឥណ្ឌាជាដើម ដែលបានចុះហត្ថលេខាជាមួយប្រទេសដៃគូរបស់ខ្លួនរួចហើយ។ មាត្រានេះមានសារៈសំខាន់សម្រាប់កម្ពុជាក្នុងការយកពន្ធកាត់ទុកលើសេវានានា ស្របតាមច្បាប់សារពើពន្ធរបស់កម្ពុជា ដែលអាចការពារបានជាអតិបរមានូវសិទ្ធិយកពន្ធរបស់កម្ពុជា។ ដូចនេះ កម្ពុជាត្រូវខិតខំទាមទារដាក់បញ្ចូលឱ្យបាននូវមាត្រានេះទៅក្នុងកិច្ចព្រមព្រៀងដែលកម្ពុជាបានចុះហត្ថលេខា ប៉ុន្តែកម្ពុជាក៏បានភាពទន់ភ្លន់ទៅលើមាត្រាពន្ធក្នុងចន្លោះ១៤%មក១០%ដូចពន្ធកាត់ទុកមាត្រាដទៃទៀតដែរ។

**៣.៣.២.៤ ការផ្លាស់ប្តូរព័ត៌មានគ្នាទៅវិញទៅមក** (Exchange of Information )

ចំណុចនៃការផ្លាស់ប្តូរព័ត៌មាន មានចែងក្នុងមាត្រា២៦នៃសេចក្តីព្រាងគំរូកិច្ចព្រមព្រៀងទ្វេភាគីស្តីពីកិច្ចការចៀសវាងការយកពន្ធត្រួតគ្នារបស់កម្ពុជា ដោយយកតាមគំរូតាមគំរូ UN ២០១១ ដែលផ្តល់សិទ្ធិអំណាច និងតម្រូវឱ្យរដ្ឋបាលសារពើពន្ធធ្វើការផ្លាស់ប្តូរព័ត៌មានគ្នាទៅវិញទៅមកសម្រាប់គោលបំណងស្តីពីសារពើពន្ធ រួមបញ្ចូលទាំងព័ត៌មានដែលគ្រប់គ្រងដោយគ្រឹះស្ថានហិរញ្ញវត្ថុ និងតតិយជន។ ការផ្លាស់ប្តូរព័ត៌មានគ្នាទៅវិញទៅមក គឺជាឧបករណ៍ដ៏មានឥទ្ធិពលក្នុងការទប់ស្កាត់ការគេចវេះ និងបន្លំពន្ធណាមួយ ដែលប្រព្រឹត្តដោយអ្នកជាប់ពន្ធ។ ការផ្លាស់ប្តូរព័ត៌មានក៏ជាយន្តការដ៏សំខាន់ជួយដល់កិច្ចការសវនកម្ម និងការបង្ក្រាបបទល្មើសពន្ធដារនានាផងដែរ។

**៣.៣.២.៥ បច្ចុប្បន្នភាពកិច្ចព្រមព្រៀង**

- អគ្គនាយកដ្ឋានពន្ធដារកម្ពុជា (GDT) បានប្រកាសជាផ្លូវការថា កិច្ចព្រមព្រៀងពន្ធទ្វេរ (DTA) ដែលព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខាជាមួយប្រទេសប្រ៊ុយណេ ដារូសាឡឹម សាធារណរដ្ឋប្រជា

- មានិតចិន និងសាធារណៈរដ្ឋសង្គមនិយមវៀតណាមចូលជាធរមានជាផ្លូវការនៅថ្ងៃទី ១ ខែមករា ឆ្នាំ ២០១៩ សម្រាប់ អ្នកជាប់ពន្ធកម្ពុជា។
- ការវិវឌ្ឍន៍ទាំងនេះតំណាងឱ្យព្រឹត្តិការណ៍សំខាន់ៗនៅក្នុងការវិវត្តន៍ពន្ធដែលកំពុងបន្តរបស់កម្ពុជា ហើយក្នុងន័យជាក់ស្តែង ពួកវាបង្ហាញថា ភាគច្រើននៃបទប្បញ្ញត្តិសំខាន់ៗដែលមាននៅក្នុង DTAs ទាំងនេះ រួមទាំងការកាត់បន្ថយពន្ធកាត់ទុកលើប្រតិបត្តិការឆ្លងព្រំដែនមួយចំនួន អាចអនុវត្តបានចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ ២០១៩ សម្រាប់អ្នកជាប់ពន្ធកម្ពុជា ។
- ចំនួនសរុបនៃ DTA ដែលចុះហត្ថលេខាដោយកម្ពុជាជាមួយប្រទេសផ្សេងទៀតឥឡូវនេះមានដល់ទៅប្រាំមួយ ជាមួយនឹងប្រាំនៃ DTA ទាំងនោះឥឡូវនេះបានចូលជាធរមានដូចតារាងខាងក្រោម៖

| Parties to the DTA | | Date of Effect |
|---|---|---|
| kingdom of Cambodia | Republic of Singapore | 1-Jan-18 |
| | Kingdom of Thailand | 1-Jan-18 |
| | Brunei Darussalam | 1-Jan-19 |
| | People’s Republic of China | 1-Jan-19 |
| | Socialist Republic of Vietnam | 1-Jan-19 |
| | Republic of Indonesia | To be determined |

### ៣.៣.៣ កិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នាដែលបានចូលជាធរមាន និងមានប្រសិទ្ធិភាពអនុវត្ត

ការរៀបចំកម្មវិធីចរចាសន្ធិសញ្ញាពន្ធត្រូវបានពិនិត្យពិភាក្សា និងធ្វើឡើងផ្តោតទៅលើលក្ខខណ្ឌមួយចំនួនដូចជា៖ រដ្ឋជាសមាជិកអាស៊ាន ប្រទេសឬតំបន់ពិសេសដែលមានការវិនិយោគធំៗនៅកម្ពុជា ប្រទេសឬតំបន់ពិសេសដែលស្នើសុំការចរចា និងមានទំនាក់ទំនងសេដ្ឋកិច្ច និងនយោបាយជិតស្និទ្ធជាមួយកម្ពុជា ប្រទេសឬតំបន់ពិសេសដែលកម្ពុជាធ្វើវិនិយោគជាមួយនិងប្រទេសឬតំបន់ពិសេសដែលមានគោលនយោបាយនិងប្រព័ន្ធពន្ធដារប្រហាក់ប្រហែលគ្នា។ មកដល់ឆ្នាំ២០២០ កម្ពុជាសម្រេចបាននូវលទ្ធផលនៃការចរចា ដូចខាងក្រោម៖

**ក. ប្រទេសសិង្ហបុរី**

- ប្រទេសសិង្ហបុរីធ្លាប់បានស្នើសុំតាមផ្លូវទូត ដើម្បីចរចាកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នាជាមួយនិងកម្ពុជា ចំនួន៣លើកចាប់តាំងពីឆ្នាំ២០០៨មកម្លេះ
- នៅឆ្នាំ២០១៥ អគ្គនាយកដ្ឋានពន្ធដារបានឆ្លើយតបតាមរយៈលិខិតផ្លូវទូតទៅកាន់អាជ្ញាធរចំណូលក្នុងស្រុកនៃប្រទេសសិង្ហបុរី (Inland Revenue Authority of Singapore – IRAS) ដើម្បីបញ្ជាក់អំពីការត្រៀមលក្ខណៈរួចរាល់សម្រាប់ការចរចាកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នាជាមួយភាគីសិង្ហបុរី

- ភាគីទាំងពីរបានឯកភាពចាប់ផ្តើមធ្វើការចរចានៅថ្ងៃទី០៧-១១ ខែកញ្ញា ឆ្នាំ២០១៥ នៅអគ្គនាយកដ្ឋានពន្ធដារ
- ដោយមានឆន្ទៈក្នុងការបញ្ចប់ការចរចា និងក្លាយជាប្រទេសដំបូងក្នុងរដ្ឋសមាជិកអាស៊ាន ដែលមានកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នាជាមួយកម្ពុជា ភាគីសិង្ហបុរីបានផ្តល់ភាពទន់ភ្លន់ច្រើនដល់កម្ពុជា។ ភាគីទាំងពីរបានបញ្ចប់ការចរចាទាំងស្រុងជាកញ្ចប់ (Package deal) បន្ទាប់ពីមានការឯកភាពលើកិច្ចព្រមព្រៀងពីរដ្ឋាភិបាល
- កិច្ចព្រមព្រៀងទ្វេភាគីស្តីការចៀសវាងការយកពន្ធត្រួតគ្នារវាងកម្ពុជា-សិង្ហបុរី ត្រូវបានចុះហត្ថលេខានៅថ្ងៃទី២០ ខែឧសភា ឆ្នាំ ២០១៦
- កិច្ចព្រមព្រៀងទ្វេភាគីស្តីការចៀសវាងការយកពន្ធត្រួតគ្នារវាងកម្ពុជា-សិង្ហបុរី នេះត្រូវបានចូលជាធរមាន និងមានប្រសិទ្ធិភាពក្នុងការអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨។

**លទ្ធផលសំខាន់ៗដែលកម្ពុជាសម្រេចបាន៖**

- ការដាក់បញ្ចូលគោលការណ៍បែងចែកចំណេញ៥០% សម្រាប់ការដឹកជញ្ជូន អន្តរជាតិតាមនាវា ដែលជាទូទៅសិទ្ធិយកពន្ធសម្រាប់ការដឹកជញ្ជូនអន្តរជាតិត្រូវបានផ្តល់ទៅប្រទេសនិវាសនជនតែម្ខាង
- ឯកភាពលើអត្រា ១០% ចំពោះពន្ធកាត់ទុកលើអនិវាសនជនសម្រាប់ការបែងចែក ភាពលាភ ការប្រាក់ សួសសារ និងថ្លៃឈ្នួលសេវាបច្ចេកទេស ដែលអត្រានេះជាទូទៅគឺសិង្ហបុរីផ្តល់ត្រឹមតែ ៥% ប៉ុណ្ណោះ
- ការផ្តល់សិទ្ធិយកពន្ធឱ្យប្រទេសប្រភពលើប្រាក់ចំណូលពីអចលនទ្រព្យ ចំណេញមូលធន សេវាបុគ្គលឯករាជ្យ សេវាបុគ្គលមិនឯករាជ្យ សិល្បករ និងកីឡាករ ការបំពេញសេវាឱ្យរដ្ឋាភិបាល និងចំណូលផ្សេងៗទៀត។ ផ្អែកទៅលើឯកភាពបែងចែកសិទ្ធិយកពន្ធជាច្រើនដោយសារកម្ពុជាជាប្រទេសប្រភព។

**ខ. ប្រទេសថៃ**

- ភាគីថៃធ្លាប់ប្រទេសធ្លាប់បានស្នើសុំតាមផ្លូវទូត ដើម្បីចរចាកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នាជាមួយនិងកម្ពុជា ចំនួន៣លើក ចាប់តាំងពីឆ្នាំ១៩៩៦ មក
- បន្ទាប់ពីមានជំនួបពិភាក្សារវាងឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាពនៃប្រទេសថៃប្រចាំព្រះរាជាណាចក្រកម្ពុជានិងខ្ញុំ គង់ វិបុល ស្តីការជំរុញឱ្យមានការចាប់ផ្តើមធ្វើការចរចាក្តីព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នារវាងកម្ពុជា-ថៃ ក្រសួងសេដ្ឋកិច្ចនិងហរិញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជាបានផ្ញើលិខិតផ្លូវការ កាលពីថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៤ តាមរយៈផ្លូវទូត ដើម្បីស្នើសុំការផ្លាស់ប្តូរគំរូកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងធ្វើកិច្ចចរចាកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នារវាងកម្ពុជា-ថៃ
- ជាលិទ្ធផល ភាគីទាំងពីរបានជួបប្រជុំត្រៀមសម្រាប់ការចរចានៅថ្ងៃទី០៤-០៦ ខែកុម្ភៈ ឆ្នាំ ២០១៥ នៅទីក្រុងបាងកកប្រទេសថៃ និងបានចរចាចំនួន៤ជុំដែលជុំទី៤ និងជុំចុងក្រោយបានប្រព្រឹតទៅនៅថ្ងៃ ០៣-០៤ ខែសីហា ឆ្នាំ២០១៧ នៅទីក្រុងបាងកកប្រទេសថៃ និងបានបញ្ចប់ការចរចាទាំងស្រុងលើកិច្ចព្រមព្រៀងនេះ

- កិច្ចព្រមព្រៀងនេះត្រូវបានចុះហត្ថលេខា ដោយឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** តំណាងរាជរដ្ឋាភិបាលនៃកម្ពុជា និងឯកឧត្តម **DON PRAMUDWINAI រដ្ឋមន្ត្រីក្រសួងការបរទេសតំណាងអោយព្រះរាជាណាចក្រថៃ** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងឧត្តម **PRAYUT CHAN-O-CHA នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃ** នាអំឡុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រីចម្រុះកម្ពុជា-ថៃ លើកទី៣ កាលពីថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ២០១៧ នៅរាជធានីភ្នំពេញ
- កិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នារវាងកម្ពុជា-ថៃនេះ ត្រូវបានចូលជាធរមាននិងមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩។

**លទ្ធផលសំខាន់ៗដែលកម្ពុជាសម្រេចបាន៖**

- ការផ្តល់សិទ្ធិយកពន្ធ ឱ្យប្រទេសប្រភព លើចំណូលពីការដឹកជញ្ជូនអន្តរជាតិតាម ផ្លូវទឹក ផ្លូវដែក និងផ្លូវគោក ចំនួន៥០% នៃពន្ធដែលត្រូវបង់ ប៉ុន្តែមានដាក់បញ្ចូល នូវលក្ខខណ្ឌសម្រាប់ប្រជាជាតិដែលមានភាពអនុគ្រោះ (MFN)
- ការឯកភាពលើអត្រា១០% ចំពោះពន្ធកាត់ទុកលើអនិវាសនជន សម្រាប់ការបែងចែក ភាគលាភ និងសួយសារ ចំណែកពន្ធកាត់ទុកលើការប្រាក់ក្នុងអត្រា១០% (ប្រសិន បើអ្នកទទួលការប្រាក់ជាស្ថាប័នហិរញ្ញវត្ថុ រួមទាំងក្រុមហ៊ុនធានារ៉ាប់រង) និង១៥% (ក្នុងករណីផ្សេងទៀត)
- ការដាក់បញ្ចូលមាត្រាស្តីពីកម្រៃសេវាបច្ចេកទេសក្នុងអត្រា១០% ភាគីថៃមិនដែល មានមាត្រានេះ នៅក្នុងកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា ជាមួយប្រទេសផ្សេងៗទៀតទេ
- ការផ្តល់សិទ្ធិយកពន្ធឱ្យប្រទេសប្រភពលើចំណូលពីអចលនទ្រព្យ ចំណេញមូលធន សេវាបុគ្គលឯករាជ្យ សេវាបុគ្គលមិនឯករាជ្យ សិល្បករ និងកីឡាករ ការបំពេញសេវា ឱ្យរដ្ឋាភិបាល និងចំណូលផ្សេងទៀត។ ផ្អែកលើការឯកភាពបែងចែកសិទ្ធិយកពន្ធ ឱ្យប្រទេសប្រភព ដូចមានរៀបរាប់ខាងលើនេះ កម្ពុជារក្សាបាននូវសិទ្ធិយកពន្ធ ច្រើន ដោយសារកម្ពុជាជាប្រទេសប្រភព
- ការបញ្ចូលបញ្ញត្តិស្តីពី Tax Sparing Credit (ដោយមានរយៈពេលកំណត់ ១០ឆ្នាំ) សម្រាប់សហគ្រាសដែលទទួលបានការលើកទឹកចិត្តផ្នែកពន្ធដារ។ ជាការផ្លាស់ប្តូរគោលនយោបាយរបស់ខ្លួន ភាគីថៃបានឈប់ដាក់បញ្ចូលបញ្ញត្តិស្តីពី Tax Sparing Credit នៅក្នុងកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយក ពន្ធត្រួតគ្នារបស់ខ្លួនជាមួយប្រទេសផ្សេងទៀត។ ប៉ុន្តែដោយសារបញ្ញត្តិស្តីពី Tax Sparing Credit នេះជាគោលនយោបាយម៉ឺងម៉ាត់របស់កម្ពុជា ដែលចាំបាច់ត្រូវ បញ្ចូល ដូចមាននៅក្នុងកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួត គ្នារវាងកម្ពុជា-ចិន និងកម្ពុជា-ព្រុយណេដែលកម្ពុជាបានចុះហត្ថលេខារួច។ ជា ការសម្របសម្រួលភាគីថៃបានយល់ព្រមបញ្ចូលបទប្បញ្ញត្តិនេះ តែដោយមាន រយៈពេលកំណត់ ១០ឆ្នាំ។

**គ. ប្រទេសចិន**

- ប្រទេសចិនធ្លាប់បានស្នើសុំតាមផ្លូវទូត ដើម្បីចរចាកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នាជាមួយកម្ពុជាចំនួន២លើក ចាប់តាំងពីឆ្នាំ២០០១ មក ដែលលើកចុងក្រោយគឺនៅក្នុងឆ្នាំ២០១៤
- ជាការឆ្លើយតប កម្ពុជាបានឯកភាពលើសំណើសុំលើកទី២របស់ចិន ហើយភាគីទាំងពីរបានឯកភាពរៀបចំកិច្ចប្រជុំត្រៀមនៅថ្ងៃទី១៦-១៨ ខែវិច្ឆិកា ឆ្នាំ២០១៥ នៅទីក្រុងប៉េកាំងប្រទេសចិន

- បន្ទាប់ពីបានចរចាចំនួនពីរលើក ដែលជុំទី១ នៅថ្ងៃទី២៩-៣១ ខែមីនា ឆ្នាំ២០១៦ និងជុំទី២ នៅថ្ងៃទី០៤-០៦ ខែឧសភា ឆ្នាំ២០១៦ នៅអគ្គនាយកដ្ឋានពន្ធដារ និងការចរចាជាកញ្ចប់(Package Deal)តាមរយៈសារអេឡិចត្រូនិកជាបន្តបន្ទាប់ ភាគីទាំងពីរបានបញ្ចប់ការចរចាទាំងស្រុងនៅក្នុងខែតុលា ឆ្នាំ២០១៦

- កិច្ចព្រមព្រៀងនេះត្រូវបានចុះហត្ថលេខាកាលពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ នៅរាជធានីភ្នំពេញ ក្នុងអំឡុងពេលទស្សនកិច្ចផ្លូវរដ្ឋរបស់ប្រធានាធិបតី សាធារណរដ្ឋប្រជាមានិតចិនមកកាន់កម្ពុជាកាលពីថ្ងៃ១៣-១៤ ខែតុលា ឆ្នាំ២០១៦ ដោយឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតំណាងរាជរដ្ឋាភិបាលកម្ពុជា និងឯកឧត្តម WANG YI រដ្ឋមន្ត្រីក្រសួងការបរទេសតំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន**

- កិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នារវាងកម្ពុជា-ចិន នេះត្រូវ បានចូលជាធរមាន និងមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩។

**លទ្ធផលសំខាន់ៗដែលកម្ពុជាសម្រេចបាន៖**

- ការដាក់បញ្ចូលគោលការណ៍បែងចែកប្រាក់ចំណេញ៥០% សម្រាប់ការដឹកជញ្ជូន

- អន្តរជាតិតាមនាវា ដែលជាទូទៅសិទ្ធិយកពន្ធសម្រាប់ការដឹកជញ្ជូនអន្តរជាតិ ត្រូវបានផ្តល់ទៅឱ្យប្រទេសនិវាសនដ្ឋានតែម្ខាង

- ការឯកភាពលើអត្រា ១០% ចំពោះពន្ធកាត់ទុកលើអនិវាសនជនសម្រាប់ការបែងចែក ភាគលាភ ការប្រាក់ស្ងួយសារ និងកម្រៃសេវាបច្ចេកទេស។ ជាការផ្លាស់ប្តូរគោលនយោបាយ ភាគីចិនបានឈប់ដាក់បញ្ចូលមាត្រាស្តីពីកម្រៃសេវាបច្ចេកទេស នៅក្នុងកិច្ចព្រមព្រៀងទ្វេភាគី ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នារបស់ខ្លួន ជាមួយប្រទេសផ្សេងទៀត។ ប៉ុន្តែភាគីចិនបានយល់ព្រមដាក់បញ្ចូលមាត្រាស្តីពី កម្រៃសេវាបច្ចេកទេសនេះក្នុងកិច្ចព្រមព្រៀងជាមួយកម្ពុជា

- ការផ្តល់សិទ្ធិយកពន្ធឱ្យប្រទេសប្រភពលើចំណូលពីអចលនទ្រព្យ ចំណេញមូលធនសេវាបុគ្គលឯករាជ្យ សេវាបុគ្គលមិនឯករាជ្យ សិល្បករ និងកីឡាករ ការបំពេញ សេវាឱ្យរដ្ឋាភិបាល និងចំណូលផ្សេងទៀត។ ផ្អែកលើការឯកភាពបែងចែកសិទ្ធិ យកពន្ធឱ្យប្រទេសប្រភពដូចមានរៀបរាប់ខាងលើនេះ កម្ពុជារក្សាបាននូវសិទ្ធិ យកពន្ធច្រើនដោយសារកម្ពុជាជាប្រទេសប្រភព

- ការផ្តល់សិទ្ធិឱ្យប្រទេសនិវាសនដ្ឋានយកពន្ធលើប្រាក់សោធននិវត្តន៍ដែលជាទូទៅសិទ្ធិយកពន្ធសម្រាប់សោធននិវត្តន៍ត្រូវបានផ្តល់ទៅឱ្យប្រទេសប្រភព

- ការបញ្ចូលបទប្បញ្ញត្តិស្តីពី Tax Sparing Credit (ដោយមានរយៈពេលកំណត់១០ឆ្នាំ) សម្រាប់សហគ្រាសដែលទទួលបានការលើកទឹកចិត្តផ្នែកពន្ធដារ។ ដោយមានការផ្លាស់ប្តូរគោលនយោបាយរបស់ខ្លួន ភាគីចិនបានឈប់ដាក់បញ្ចូល បទប្បញ្ញត្តិស្តីពី Tax Sparing Credit នៅក្នុងកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀស- វាងការយកពន្ធត្រួតគ្នារបស់ខ្លួនជាមួយប្រទេសផ្សេងទៀត។ប៉ុន្តែ ដោយសារបញ្ញត្តិ ស្តីពី Tax Sparing Credit នេះជាគោលនយោបាយម៉ឺងម៉ាត់របស់កម្ពុជា ដែល ចាំបាច់ត្រូវបញ្ចូល ភាគីចិនយល់ព្រមបញ្ចូលបទប្បញ្ញត្តិនេះ តាមរយៈការចរចា ជាកញ្ចប់ (Package Deal)។

**ឃ. ប្រទេសព្រុយណេ**

- ភាគីព្រុយណេបានស្នើសុំចរចាកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នាជាមួយកម្ពុជា តាមរយៈផ្លូវទូតក្នុងឆ្នាំ២០១៥។ ជាការឆ្លើយតប កម្ពុជាបានឯកភាពលើសំណើនេះ ហើយភាគីទាំងពីរបាន ឯកភាពចាប់ផ្តើមធ្វើការ ចរចាជុំទី១ នៅថ្ងៃទី០៣-០៧ ខែសីហា ឆ្នាំ២០១៥ នៅប្រទេសព្រុយណេ។ ភាគី ទាំងពីរបានបញ្ចប់ការចរចាទាំងស្រុងលើការចរចាជាកញ្ចប់ (Package Deal) តាមរយៈសារអេឡិចត្រូនិកនៅ ក្នុងខែកុម្ភៈ ឆ្នាំ២០១៧
- កិច្ចព្រមព្រៀងនេះត្រូវបានចុះហត្ថលេខានៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៧ នៅរាជធានីភ្នំពេញដោយឯក ឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តំណាង រាជរដ្ឋាភិបាលកម្ពុជា** និងឯកឧត្តម **PENGIRANKASMIRHAN BIN PENGIRAN HAJI MOHAMMAD TAHIR ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពនៃប្រទេសព្រុយណេដារូសាឡឹម** ប្រចាំព្រះរាជាណាចក្រកម្ពុជាតំណាងរដ្ឋាភិបាលនៃប្រទេសព្រុយណេ
- កិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នារវាងកម្ពុជា-ព្រុយណេ នេះត្រូវបានចូល ជាធរមាន និងមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩។

**លទ្ធផលសំខាន់ៗដែលកម្ពុជាសម្រេចបាន៖**

- ការដាក់បញ្ចូលគោលការណ៍បែងចែកប្រាក់ចំណេញ៥០% សម្រាប់ការដឹកជញ្ជូន អន្តរជាតិតាមនាវា ដែល ជាទូទៅសិទ្ធិយកពន្ធសម្រាប់ការដឹកជញ្ជូនអន្តរជាតិត្រូវ បានផ្តល់ទៅឱ្យប្រទេសនិវាសនជនតែម្ខាង
- ការឯកភាពលើអត្រា ១០% ចំពោះពន្ធកាត់ទុកលើអនិវាសនជនសម្រាប់ការ បែងចែកភាគលាភ ការប្រាក់ និងសួយសារ និងអត្រា ១៤% ចំពោះពន្ធកាត់ទុក លើកម្រៃសេវាបច្ចេកទេស
- ការផ្តល់សិទ្ធិយកពន្ធឱ្យប្រទេសប្រភពលើចំណូលពីអចលនទ្រព្យ ចំណេញមូលធន
- សេវាបុគ្គលឯករាជ្យ សេវាបុគ្គលមិនឯករាជ្យ សិល្បករ និងកីឡាករ ការបំពេញសេវាឱ្យរដ្ឋាភិបាល និង ចំណូលផ្សេងទៀត។ ផ្អែកលើការឯកភាពបែងចែកសិទ្ធិយកពន្ធ ឱ្យប្រទេសប្រភព ដូចមានរៀបរាប់ខាងលើ នេះ កម្ពុជារក្សាបាននូវសិទ្ធិយកពន្ធ ច្រើនដោយសារកម្ពុជាជាប្រទេសប្រភព
- ការផ្តល់សិទ្ធិឱ្យប្រទេសនិវាសនដ្ឋានយកពន្ធលើប្រាក់សោធននិវត្តន៍ ដែលជាទូទៅសិទ្ធិយកពន្ធសម្រាប់ សោធននិវត្តន៍ ត្រូវបានផ្តល់ទៅឱ្យប្រទេសប្រភព
- ការផ្តល់ការអនុគ្រោះពន្ធលើប្រាក់ចំណូលរយៈពេល៣ឆ្នាំ ចំពោះសាស្ត្រាចារ្យ និង អ្នកស្រាវជ្រាវក្នុងទិស ដៅជំរុញឱ្យមានលំហូរនៃជំនាញចំណេះដឹង និងបទពិសោធន៍ សម្រាប់វិស័យអប់រំ
- ការបញ្ចូលបទប្បញ្ញត្តិស្តីពី Tax Sparing Credit ដោយពុំបានដាក់កម្រិតកាលបរិច្ឆេទបញ្ចប់ (Sunset Clause) សម្រាប់សហគ្រាសដែលទទួលបានការលើកទឹកចិត្តផ្នែកពន្ធដារ ដោយសារប្រទេសទាំងពីរមានគោល នយោបាយ ដូចគ្នាក្នុង ការទាក់ទាញវិនិយោគ។

**ង. ប្រទេសវៀតណាម**

- វៀតណាមគឺជាប្រទេសទី១ ដែលកម្ពុជាបានចាប់ផ្តើមចរចាកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការ យកពន្ធត្រួតគ្នាជាមួយ កាលពីចុងឆ្នាំ២០១៤ និងបានចរចា ចំនួន ០៣ជុំរួច
- ការចរចាជុំទី៣ បានប្រព្រឹត្តទៅកាលពីថ្ងៃទី២៧-២៩ ខែកញ្ញា ឆ្នាំ២០១៧ នៅរាជធានីភ្នំពេញ ប្រទេសកម្ពុជា

- ជាលទ្ធផលនៃកិច្ចចរចាទាំង០៣ជុំ ភាគីទាំងពីរបានឯកភាពលើ មាត្រាភាគច្រើននៃកិច្ចព្រមព្រៀងសរុបចំនួន២៥មាត្រាក្នុងចំណោម២៩មាត្រា
- កិច្ចព្រមព្រៀងទ្វេភាគីស្ដីពីការចៀសវាងការយកពន្ធត្រួតគ្នារវាងកម្ពុជា-វៀតណាម ត្រូវបានចុះហត្ថលេខាកាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៨ នៅរដ្ឋធានីហាណូយ សាធារណរដ្ឋសង្គមនិយមវៀតណាម ក្នុងអំឡុងពេលនៃកិច្ចប្រជុំកំពូលមហា អនុតំបន់មេគង្គលើកទី៦ និងកិច្ចប្រជុំកំពូលកម្ពុជា-ឡាវ-វៀតណាម លើកទី១០ ស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណ។ កិច្ចព្រមព្រៀងនេះ ត្រូវបានចុះហត្ថលេខាដោយឯកឧត្តមបណ្ឌិតសភាចារ្យ ថូ វិចិត្ត រដ្ឋមន្ត្រីប្រតិភូអមនាយក- រដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តំណាងរាជរដ្ឋាភិបាលន ព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម TRAN XUAN HA អនុរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ វៀតណាម តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ក្រោម អធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្ដេចអគ្គមហាសេនាតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងសមភាគីវៀតណាម **ឯកឧត្តម ង្វៀន សួនហ៊្វុក នាយករដ្ឋមន្ត្រីនៃប្រទេសវៀតណាម**។
- កិច្ចព្រមព្រៀងទ្វេភាគីស្ដីពីការចៀសវាងការយកពន្ធត្រួតគ្នារវាងកម្ពុជា-វៀតណាមនេះត្រូវបានចូលជាធរមាន និងមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២០។

**លទ្ធផលសំខាន់ៗដែលកម្ពុជាសម្រេចបាន៖**

- លក្ខខណ្ឌដែលផ្ដល់ប្រយោជន៍ដល់ប្រទេសប្រភព ក្នុងការកំណត់ពន្ធតាមរយៈ គ្រឹះស្ថានអចិន្ត្រៃយ៍
- ការយកពន្ធលើបុព្វលាភធានារ៉ាប់រង ដែលលក់ដោយសហគ្រាសអនិវាសនជន
- អត្រាពន្ធកាត់ទុក ១០%លើភាគលាភការប្រាក់សួយសារនិងកម្រៃសេវាបច្ចេកទេស
- ការលើកលែងពន្ធកាត់ទុកលើការប្រាក់ទទួលបានដោយម្ចាស់សិទ្ធិអាស្រ័យផល ជារដ្ឋភាគីនៃកិច្ចព្រមព្រៀង
- ប្រាក់ចំណូលពីប្រតិបត្តិការយន្តហោះនៅក្នុងចរាចរណ៍អន្តរជាតិរបស់ក្រុមហ៊ុន អាកាសចរណ៍ ត្រូវជាប់ពន្ធតនៅក្នុងប្រទេសនិវាសនដ្ឋានប៉ុណ្ណោះ
- ប្រាក់ចំណូលពីប្រតិបត្តិការតាមនាវា តាមផ្លូវដែក ផ្លូវថ្នល់ ឬទូកនៅក្នុងចរាចរណ៍ អន្តរជាតិ ក៏ទទួលបានការលើកលែងពន្ធ ៥០% នៅក្នុងប្រទេសប្រភពផងដែរ
- កិច្ចព្រមព្រៀងនេះ នឹងអាចឱ្យភាគីទាំងពីរធ្វើការផ្លាស់ប្ដូរព័ត៌មានគ្នាទៅវិញទៅមក ក្នុងគោលបំណងពង្រីកតម្លាភាពផ្នែកពន្ធ និងប្រយុទ្ធប្រឆាំងនឹងការកិបកេងបន្លំពន្ធ
- ការបញ្ចូលបទប្បញ្ញត្តិស្ដីពី Tax Sparing

**ច. តំបន់រដ្ឋបាលពិសេសហុងកុង**

- កិច្ចព្រមព្រៀងទ្វេភាគីស្ដីពីការចៀសវាងការយកពន្ធត្រួតគ្នារវាង កម្ពុជា-ហុងកុង ជុំទី១បានប្រព្រឹត្តទៅថ្ងៃទី១៩-២២ ខែមិថុនា ឆ្នាំ២០១៩ នៅទីក្រុងហុងកុង។ កិច្ចចរចាបានប្រព្រឹត្តទៅរវាងភាគីទាំងពីរក្នុងបរិយាកាសយោគយល់គ្នា រីករាយស្និទ្ធស្នាល និងប្រកបដោយផ្លែផ្កាវិជ្ជមានជាច្រើន
- ដោយឡែកបញ្ហាដែលនៅសេសសល់ពីកិច្ចប្រជុំជុំទី១ បានត្រូវចរចា និងដោះស្រាយតាមរយៈសារអេឡិចត្រូនិក ជាលទ្ធផលនៃការចរចាត្រូវបានបញ្ចប់ទាំងស្រុងនៅ ក្នុងអំឡុងខែមីនា ឆ្នាំ២០១៩

- កិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នារវាងកម្ពុជា-ហុងកុងត្រូវបានចុះហត្ថលេខាដោយ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** តំណាងឱ្យរាជរដ្ឋាភិបាល កម្ពុជានៅរាជធានីភ្នំពេញ នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ និង **ឯកឧត្តម JAME H. LAU JR. រដ្ឋមន្ត្រីហិរញ្ញវត្ថុនិងរតនាគារហុងកុង** តំណាងឱ្យរដ្ឋាភិបាល នៃតំបន់រដ្ឋបាលពិសេសហុងកុង នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩ នៅទីក្រុងហុងកុង
- កិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នារវាងកម្ពុជា-ហុងកុងនេះត្រូវបានចូលជាធរមាន និងមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២០។

លទ្ធផលសំខាន់ៗដែលកម្ពុជាសម្រេចបាន៖

- អត្រាពន្ធកាត់ទុក ១០% លើភាគលាភ ការប្រាក់ សួយសារ និងកម្រៃសេវា បច្ចេកទេស
- ប្រាក់ចំណូលពីប្រតិបត្តិការយន្តហោះនៅក្នុងចរាចរណ៍អន្តរជាតិរបស់ក្រុមហ៊ុន អាកាសចរណ៍ ត្រូវជាប់ពន្ធតែនៅក្នុងប្រទេសនិវាសនដ្ឋានប៉ុណ្ណោះ
- ប្រាក់ចំណូលពីប្រតិបត្តិការតាមនាវានៅក្នុងចរាចរណ៍អន្តរជាតិ ក៏ទទួលបានការលើកលែងពន្ធ៥០% នៅក្នុងប្រទេសប្រភពផងដែរ
- កិច្ចព្រមព្រៀងនេះ នឹងអាចឱ្យភាគីទាំងពីរធ្វើការផ្លាស់ប្តូរព័ត៌មានគ្នាទៅវិញទៅមកក្នុង គោលបំណងពង្រឹកតម្លាភាពផ្នែកពន្ធ និងប្រយុទ្ធប្រឆាំងនឹងការកិបកេងបន្លំពន្ធ។

**ឆ. ប្រទេសឥណ្ឌូនេស៊ី**

- ប្រទេសឥណ្ឌូនេស៊ីធ្លាប់បានស្នើសុំតាមផ្លូវទូត ដើម្បីចរចាកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នាជាមួយកម្ពុជាចំនួន ២លើក ចាប់តាំងពីឆ្នាំ ១៩៩៨ មក
- ក្នុងឆ្នាំ២០១៥កម្ពុជាបានផ្ញើលិខិតទៅឥណ្ឌូនេស៊ីតាមរយៈផ្លូវទូតដើម្បីចាប់ផ្តើមចរចាកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា
- ការចរចាកិច្ចព្រមព្រៀងទ្វេភាគីជុំទី១ បានប្រព្រឹត្តទៅកាលពីថ្ងៃទី២០-២៣ ខែកញ្ញា ឆ្នាំ២០១៦ នៅរដ្ឋធានីហ្សាកាតាប្រទេសឥណ្ឌូនេស៊ី និងការចរចា ជុំទី២ និងជាជុំចុងក្រោយបានប្រព្រឹត្តទៅកាលពីថ្ងៃ០៧-០៩ ខែមីនា ឆ្នាំ២០១៧ នៅខេត្តសៀមរាបប្រទេសកម្ពុជា
- កិច្ចព្រមព្រៀងនេះត្រូវបានចុះហត្ថលេខាដោយ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** តំណាង ឱ្យរាជរដ្ឋាភិបាលកម្ពុជា នៅរាជធានីភ្នំពេញ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៧ និង**ឯកឧត្តមបណ្ឌិត SRI MULYANI INDRAWATI រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ប្រទេសឥណ្ឌូនេស៊ី** តំណាងឱ្យរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌូនេស៊ី នៅរដ្ឋធានី ហ្សាកាតា នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៧។
- កិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នារវាងកម្ពុជា-ឥណ្ឌូនេស៊ី នេះនឹងត្រូវបានចូលជាធរមាន និងមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២១។

**លទ្ធផលសំខាន់ៗដែលកម្ពុជាសម្រេចបាន៖**

- លក្ខខណ្ឌដែលផ្តល់ប្រយោជន៍ដល់ប្រទេសប្រភព ក្នុងការកំណត់ពន្ធតាមរយៈ
- គ្រឹះស្ថានអចិន្ត្រៃយ៍ ការយកពន្ធលើបុព្វលាភធានារ៉ាប់រង ដែលលក់ដោយសហគ្រាសអនិវាសនជន

- អត្រាពន្ធកាត់ទុក ១០% លើភាគលាភ ការប្រាក់ សួយសារ និងកម្រៃសេវា បច្ចេកទេស
- ការលើកលែងពន្ធកាត់ទុកលើការប្រាក់ទទួលបាន ដោយម្ចាស់សិទ្ធិអាស្រ័យផលជារដ្ឋភាគីនៃកិច្ចព្រមព្រៀង
- ការលើកលែងពន្ធដល់និយោជិត សាស្ត្រាចារ្យ គ្រូបង្រៀន និងអ្នកស្រាវជ្រាវតាម លក្ខខណ្ឌរបស់ DTA
- ប្រាក់ចំណូលពីប្រតិបត្តិការយន្តហោះនៅក្នុងចរាចរណ៍អន្តរជាតិរបស់ក្រុមហ៊ុន អាកាសចរណ៍ ត្រូវជាប់ពន្ធតែនៅក្នុងប្រទេសនិវាសនដ្ឋានប៉ុណ្ណោះ
- ប្រាក់ចំណូលពីប្រតិបត្តិការតាមនាវានៅក្នុងចរាចរណ៍អន្តរជាតិ ក៏ទទួលបានការលើកលែងពន្ធ ៥០% នៅក្នុងប្រទេសប្រភពផងដែរ
- កិច្ចព្រមព្រៀងនេះ នឹងអាចឱ្យភាគីទាំងពីរធ្វើការផ្លាស់ប្តូរព័ត៌មានគ្នាទៅវិញទៅមក ក្នុងគោលបំណងពង្រឹកតម្លាភាពផ្នែកពន្ធ និងប្រយុទ្ធប្រឆាំងនឹងការកិបកេងបន្លំពន្ធ
- រួមបញ្ចូលបទប្បញ្ញត្តិស្តីពី Tax Sparing។

**ខ. ប្រទេសម៉ាឡេស៊ី**

- ប្រទេសម៉ាឡេស៊ីធ្លាប់បានស្នើសុំតាមផ្លូវទូត ដើម្បីចរចាកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នាជាមួយកម្ពុជាចំនួន ៣លើក ចាប់តាំងពីឆ្នាំ ២០០១ មក
- ឆ្នាំ២០១៤ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានធ្វើការស្នើសុំទៅភាគីម៉ាឡេស៊ីតាមរយៈផ្លូវទូតឱ្យធ្វើការផ្លាស់ប្តូរគំរូសេចក្តីព្រាងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នារវាងកម្ពុជា និងម៉ាឡេស៊ីដើម្បីសិក្សាមុននឹងចាប់ផ្តើមចរចា
- កិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា រវាងកម្ពុជា-ម៉ាឡេស៊ី ជុំទី១ បានប្រព្រឹត្តទៅកាលពីថ្ងៃទី២៥-២៩ ខែមេសា ឆ្នាំ២០១៦ នៅប្រទេស ម៉ាឡេស៊ី ដែលភាគីទាំងពីរបានឯកភាពគ្នាទាំងស្រុងលើ១៩មាត្រា
- កិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា រវាងកម្ពុជា-ម៉ាឡេស៊ី ជុំទី២បានប្រព្រឹត្តទៅកាលពីថ្ងៃទី០៧-០៩ ខែសីហា ឆ្នាំ២០១៨ នៅប្រទេសកម្ពុជា
- បន្ទាប់ពីបានចរចាចំនួនពីរ ភាគីទាំងពីរបានបន្តការចរចាតាមរយៈសារអេឡិចត្រូនិកលើបញ្ហាដែលនៅសេសសល់ និងបានបញ្ចប់ការចរចាទាំងស្រុងនៅក្នុង ខែសីហា ឆ្នាំ២០១៩
- កិច្ចព្រមព្រៀងនេះត្រូវបានចុះហត្ថលេខានៅរាជធានីភ្នំពេញ នៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៩ ដោយ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** តំណាងឱ្យរាជរដ្ឋាភិបាលកម្ពុជា និង**ឯកឧត្តម SAIFUDDIN ABDULLAH រដ្ឋមន្ត្រីក្រសួងការបរទេសម៉ាឡេស៊ី** តំណាងឱ្យ រដ្ឋាភិបាលនៃម៉ាឡេស៊ី។
- កិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នារវាងកម្ពុជា-ម៉ាឡេស៊ីនេះ នឹងត្រូវបានចូលជាធរមាន និងមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២១។

**លទ្ធផលសំខាន់ៗដែលកម្ពុជាសម្រេចបាន៖**

- ការដាក់បញ្ចូលគោលការណ៍បែងចែកប្រាក់ចំណេញ៥០%សម្រាប់ការដឹកជញ្ជូន អន្តរជាតិតាមនាវា ដែលជាទូទៅសិទ្ធិយកពន្ធសម្រាប់ការដឹកជញ្ជូនអន្តរជាតិត្រូវ បានផ្តល់ទៅឱ្យប្រទេសនិវាសនជនតែម្ខាង
- ការរក្សាបានអត្រា ១០% ចំពោះពន្ធកាត់ទុកលើអនិវាសនជនសម្រាប់ការបែងចែក ភាគលាភ ការប្រាក់ សួយសារ និងកម្រៃសេវាបច្ចេកទេស
- ការផ្តល់សិទ្ធិយកពន្ធឱ្យប្រទេសប្រភពលើចំណូលពីអចលនទ្រព្យ ចំណេញមូលធន សេវាបុគ្គលឯករាជ្យ សេវាបុគ្គលមិនឯករាជ្យ សិល្បករនិងកីឡាករ ការបំពេញ សេវាឱ្យរដ្ឋាភិបាល និងចំណូលផ្សេងទៀត
- ការផ្តល់សិទ្ធិឱ្យប្រទេសនិវាសនដ្ឋានយកពន្ធលើប្រាក់សោធននិវត្តន៍ ដែលជាទូទៅសិទ្ធិយកពន្ធសម្រាប់សោធននិវត្តន៍ ត្រូវបានផ្តល់ទៅឱ្យប្រទេសប្រភព
- រក្សាបាននូវគោលការណ៍ផ្តល់ Tax Sparing Credit ដែលជាប្រយោជន៍មួយ នៃការទាក់ទាញវិនិយោគិនម៉ាឡេស៊ី។

**៣.៣.៤ កិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នាដែលបានបញ្ចប់ និងចុះហត្ថលេខារវាងកម្ពុជា-កូរ៉េខាងត្បូង**

តាមសំណើរបស់ប្រទេសកូរ៉េខាងត្បូងតាមផ្លូវទូតមកប្រទេសកម្ពុជាចំនួនពីរលើក ដែលលើកទី១ នៅឆ្នាំ២០០៦ និងលើកទី២នៅឆ្នាំ២០១៤ កម្ពុជាបានឯកភាពក្នុងការចាប់ផ្តើមចរចា លើកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នាជាមួយប្រទេសកូរ៉េខាងត្បូង។ កិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នារវាងកម្ពុជា-កូរ៉េខាងត្បូងនេះ បានរៀបចំកិច្ចប្រជុំចរចាចំនួន ៣ជុំ ដែលជុំទី១ បានប្រព្រឹត្តទៅនៅថ្ងៃទី០៦-០៨ ខែកញ្ញា ឆ្នាំ២០១៦ នៅរាជធានីភ្នំពេញ ជុំទី២ បានធ្វើឡើងនៅថ្ងៃទី០៥-០៨ ខែកញ្ញា ឆ្នាំ២០១៧ នៅរាជធានីភ្នំពេញ និង ជុំទី៣ បានប្រព្រឹត្តទៅនៅថ្ងៃទី២៨-៣១ ខែឧសភា ឆ្នាំ២០១៨ នៅប្រទេសកូរ៉េ។ បញ្ហាដែលនៅសេសសល់ពីកិច្ចចរចាជុំទី៣ ត្រូវបានភាគីទាំងពីរពិភាក្សានិងចរចាតាមរយៈប្រព័ន្ធអេឡិចត្រូនិក ហើយត្រូវបានដោះស្រាយចប់ទាំងស្រុងនៅក្នុងអំឡុងខែកញ្ញា ឆ្នាំ២០១៩។ តបតាមសំណើរបស់ភាគីកូរ៉េខាងត្បូង កិច្ចព្រមព្រៀងទ្វេភាគីនេះត្រូវបានចុះហត្ថលេខានៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ នៅទីក្រុងប៊ូសានប្រទេសកូរ៉េខាងត្បូង។ កិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នារវាងកម្ពុជា-កូរ៉េខាងត្បូងនេះ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១២០/០២៣ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០។ កិច្ចព្រមព្រៀងទ្វេភាគីនេះ នឹងចូលជាធរមាន និងមានប្រសិទ្ធភាព អនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២២។

**លទ្ធផលសំខាន់ៗដែលសម្រេចបាន៖**

- លក្ខខណ្ឌដែលផ្តល់ប្រយោជន៍ដល់ប្រទេសប្រភពក្នុងការកំណត់ពន្ធ តាមរយៈ គ្រឹះស្ថានអចិន្ត្រៃយ៍
- ការយកពន្ធលើបុព្វលាភធានារ៉ាប់រង ដែលលក់ដោយសហគ្រាសអនិវាសនជន
- អត្រាពន្ធកាត់ទុក ១០% លើភាគលាភ ការប្រាក់ សួយសារ និងកម្រៃសេវា បច្ចេកទេស

ការលើកលែងពន្ធកាត់ទុកលើការប្រាក់ទទួលបានដោយម្ចាស់សិទ្ធិអាស្រ័យផល ជារដ្ឋភាគីនៃកិច្ចព្រមព្រៀង

- ការលើកលែងពន្ធដល់និយោជិត សាស្ត្រាចារ្យ គ្រូបង្រៀន និងអ្នកស្រាវជ្រាវ តាមលក្ខខណ្ឌរបស់ DTA

• ប្រាក់ចំណូលពីប្រតិបត្តិការយន្តហោះនៅក្នុងចរាចរណ៍អន្តរជាតិរបស់ក្រុមហ៊ុន អាកាសចរណ៍ ត្រូវជាប់ពន្ធតែនៅក្នុងប្រទេសនិវាសនដ្ឋានប៉ុណ្ណោះ

• ប្រាក់ចំណូលពីប្រតិបត្តិការតាមនាវានៅក្នុងចរាចរណ៍អន្តរជាតិ ក៏ទទួលបានការលើកលែងពន្ធ ៥០% នៅក្នុងប្រទេសប្រភពផងដែរ

• កិច្ចព្រមព្រៀងនេះ នឹងអាចឱ្យភាគីទាំងពីរធ្វើការផ្លាស់ប្ដូរព័ត៌មានគ្នាទៅវិញទៅមក ក្នុងគោលបំណងពង្រីកតម្លាភាពផ្នែកពន្ធ និងប្រយុទ្ធប្រឆាំងនឹងការកិបកេងបន្លំពន្ធ

• រួមបញ្ចូលបទប្បញ្ញត្តិស្ដីពី Tax Sparing Credit ដែលមានប្រសិទ្ធភាពអនុវត្ត សម្រាប់រយៈពេល១ឆ្នាំ ចាប់ផ្ដើមពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ប៉ុន្តែ រយៈពេលនេះ អាចត្រូវបានពន្យារតាមការព្រមព្រៀងគ្នាទៅវិញទៅមក (Mutual Agreement Procedure-MAP) របស់អាជ្ញាធរមានសមត្ថកិច្ចនៃភាគីទាំងពីរ។

**៣.៣.៤ កិច្ចព្រមព្រៀងទ្វេភាគីស្ដីពីការចៀសវាងការយកពន្ធត្រួតគ្នា ដែលកំពុងស្ថិតក្នុង ដំណាក់កាលនៃការចរចា**

ក្រៅពីកិច្ចព្រមព្រៀងទាំង ៩ ខាងលើ ដែលបានបញ្ចប់ការចរចា និងបានចុះហត្ថលេខារួច ការចរចាស្ដីពីកិច្ចព្រមព្រៀងទ្វេភាគីស្ដីពីការចៀសវាងការយកពន្ធត្រួតគ្នា ជាមួយបណ្ដាប្រទេស មួយចំនួនដទៃទៀតនិងតំបន់រដ្ឋបាលពិសេស ដូចខាងក្រោម៖

**ក. តំបន់រដ្ឋបាលពិសេសម៉ាកាវ**

តាមសំណើរបស់តំបន់រដ្ឋបាលពិសេសម៉ាកាវ កម្ពុជាបានឯកភាពក្នុងការចាប់ផ្ដើមចរចា លើកិច្ចព្រមព្រៀងទ្វេភាគីស្ដីពីការចៀសវាងការយកពន្ធត្រួតគ្នា ជាមួយតំបន់រដ្ឋបាលពិសេស ម៉ាកាវ។ កិច្ចប្រជុំត្រៀម (Pre-Meeting) សម្រាប់ការចរចាកិច្ចព្រមព្រៀងទ្វេភាគីស្ដីពីការចៀសវាងការយកពន្ធត្រួតគ្នារវាងភាគីទាំងពីរបានប្រព្រឹត្តទៅកាលពីថ្ងៃទី១១-១២ ខែធ្នូ ឆ្នាំ២០១៨ នៅ ទីក្រុងម៉ាកាវ។ បន្ទាប់មកកិច្ចចរចាជុំទី១ រវាងភាគីទាំងពីរបានប្រព្រឹត្តទៅនៅថ្ងៃទី ២២-២៤ ខែមករា ឆ្នាំ២០១៩ នៅអគ្គនាយកដ្ឋានពន្ធដារក្នុងប្រទេសកម្ពុជា និងកិច្ចប្រជុំចរចាជុំទី២ បានប្រព្រឹត្តទៅនៅថ្ងៃទី១៩-២០ ខែកញ្ញា ឆ្នាំ២០១៩ នៅទីក្រុងម៉ាកាវ។ ជាលទ្ធផលនៃកិច្ចប្រជុំចរចា ជុំទី២នេះ ភាគីទាំងពីរបានឯកភាពគ្នាទាំងស្រុង។ ក្នុងឆ្នាំ២០២០ តាមរយៈទំនាក់ទំនងជាសារអេឡិចត្រូនិកជាបន្តបន្ទាប់ភាគីទាំងពីរបានពិភាក្សា និងពិនិត្យលើជម្រើសចុះហត្ថលេខានៃការចុះហត្ថលេខាកិច្ចព្រមព្រៀងទ្វេភាគីនេះ តាមរយៈការផ្ញើរឯកសារកិច្ចព្រមព្រៀងទ្វេភាគីនេះទៅវិញ ទៅមក (way of carrier) ដែលជាជម្រើសប្រសើរក្នុងដំណាក់កាលនៃការរីករាលដាលជំងឺ កូវីដ-១៩ (Covid-19)។ បច្ចុប្បន្ន ភាគីទាំងពីរបានបញ្ចប់ការចរចា និងកំពុងរៀបចំឯកសារកិច្ចព្រមព្រៀងរវាងទ្វេភាគីកម្ពុជា-ម៉ាកាវនេះ សម្រាប់ត្រៀមចុះហត្ថលេខាតាមរយៈមធ្យោបាយដឹក ជញ្ជូនរហ័សខាងលើ។

**ខ. ប្រទេសតួកគី**

តាមសំណើរបស់ប្រទេសតួកគីប្រទេសកម្ពុជាបានឯកភាពក្នុងការចាប់ផ្ដើមចរចាលើកិច្ចព្រមព្រៀងទ្វេភាគីស្ដីពីការចៀសវាងការយកពន្ធត្រួតគ្នាជាមួយប្រទេសតួកគី។ ការចរចាកិច្ចព្រមព្រៀងទ្វេភាគីស្ដីពីការចៀសវាងការយកពន្ធត្រួតគ្នានេះ បានប្រព្រឹត្តទៅកាលពីថ្ងៃទី០៥-០៨ ខែមីនា ឆ្នាំ២០១៩ នៅទីក្រុងអង់ការ៉ាសាធារណរដ្ឋតួកគី ដោយភាគីទាំងពីរបានឯកភាពគ្នាទាំងស្រុង លើមាត្រាចំនួន ២៣។ ភាគីកម្ពុជាបានបង្ហាញអំពីជំហរចំពោះចំណុចដែលនៅសេសសល់ និងកំពុងរង់ចាំការឆ្លើយតបពីភាគីតួកគី អេឡិចត្រូនិកក្នុងឆ្នាំ

២០២០។ ក្រោយពីបានទំនាក់ទំនងទៅភាគីពួកគីជាថ្មីតាមរយៈសារ កិច្ចព្រមព្រៀងនេះកំពុងស្ថិតក្នុងដំណាក់កាលចរចានៅឡើយ។

**គ. ប្រទេសហ្វីលីពីន**

តាមសំណើរបស់កម្ពុជា ប្រទេសហ្វីលីពីនបានឯកភាពក្នុងការចាប់ផ្តើមចរចាលើកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នាជាមួយកម្ពុជា។ កិច្ចប្រជុំត្រៀម (Pre-Meeting) សម្រាប់ការចរចាកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នារវាងភាគីទាំងពីរ បានប្រព្រឹត្តទៅកាលពីថ្ងៃទី ១៣-១៥ ខែធ្នូ ឆ្នាំ២០១៧ នៅរាជធានីភ្នំពេញ ប្រទេសកម្ពុជា។ បន្ទាប់មក កិច្ចចរចាជុំទី១ រវាងភាគីទាំងពីរ បានប្រព្រឹត្តទៅនៅទី២៦-២៩ ខែមិថុនា ឆ្នាំ២០១៨ នៅ ទីក្រុងម៉ានីល សាធារណរដ្ឋហ្វីលីពីន ក្រោមបរិយាកាសរីករាយ ស្និទ្ធស្នាល យោគយល់គ្នា និង ប្រកបដោយផ្លែផ្កា ហើយភាគីទាំងពីរបានឯកភាពគ្នាទាំងស្រុងលើចំនួន ១៥ មាត្រា។ បន្ទាប់មកកិច្ចប្រជុំចរចាជុំទី២ បានប្រព្រឹត្តទៅនៅថ្ងៃទី១១-១៣ ខែធ្នូ ឆ្នាំ២០១៩ នៅខេត្តសៀមរាប ប្រទេសកម្ពុជា ជាលទ្ធផលនៃកិច្ចប្រជុំចរចាជុំទី២នេះភាគីទាំងពីរ បានឈានដល់ការឯកភាពលើចំណុច សំខាន់ៗបន្ថែមទៀត។ កិច្ចព្រមព្រៀងនេះកំពុងស្ថិតក្នុងដំណាក់កាលចរចានៅឡើយ។

**ឃ. ប្រទេសជប៉ុន**

តាមសំណើរបស់កម្ពុជា ប្រទេសជប៉ុនបានឯកភាពក្នុងការចាប់ផ្តើមចរចាលើកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នាជាមួយកម្ពុជា។ កិច្ចប្រជុំចរចាលើកទី១នៃកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នានេះ បានប្រព្រឹត្តទៅកាលពីថ្ងៃទី១៦-១៨ ខែធ្នូ ឆ្នាំ ២០១៥នៅរាជធានីភ្នំពេញ ប្រទេសកម្ពុជា និងកិច្ចប្រជុំចរចាលើកទី២ បានប្រព្រឹត្តទៅកាលពីថ្ងៃទី ២៣-២៦ ខែមករា ឆ្នាំ២០១៨ នៅទីក្រុងតូក្យូ ប្រទេសជប៉ុន។ កិច្ចព្រមព្រៀងនេះកំពុងស្ថិតក្នុង ដំណាក់កាលចរចានៅឡើយ។

**ង. ប្រទេសឡាវ**

តាមសំណើរបស់ប្រទេសកម្ពុជា ប្រទេសឡាវបានឯកភាពក្នុងការចាប់ផ្តើមចរចាលើកិច្ច ព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នាជាមួយប្រទេសកម្ពុជា។ ចាប់តាំងពីឆ្នាំ ២០១៥ មក កិច្ចព្រមព្រៀងទ្វេភាគីនេះពុំទាន់ទទួលបាននូវវឌ្ឍនភាពជាវិជ្ជមាននៅឡើយទេ ដោយភាគីទាំងពីរបានត្រឹមតែផ្លាស់ប្តូរគំរូកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធ ត្រួតគ្នាទៅវិញទៅមក ដើម្បីធ្វើការសិក្សាប៉ុណ្ណោះ។ ក្រោយមកតាមរយៈកិច្ចប្រជុំគណៈកម្មការ ចម្រុះសម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-ឡាវលើកទី១៣ និងទស្សនកិច្ចផ្លូវការនៅប្រទេស ឡាវនៅថ្ងៃទី២១-២២ ខែកុម្ភៈ ឆ្នាំ២០១៩ ភាគីកម្ពុជាបានស្នើសុំឱ្យភាគីឡាវបង្កើនល្បឿនក្នុងការចាប់ផ្តើមចរចា។ ក្នុងខែមេសា ឆ្នាំ២០២០ ភាគីកម្ពុជាបានស្នើភាគីឡាវចាប់ផ្តើមការចរចាតាមរយៈទំនាក់ទំនងជាសារអេឡិចត្រូនិកជាថ្មីម្តងទៀត និងជាលទ្ធផលភាគីឡាវបានយល់ស្របឱ្យចាប់ផ្តើមការចរចាជុំទី០១ ក្នុងអំឡុងខែកុម្ភៈ ឆ្នាំ២០២១ តាមរយៈប្រព័ន្ធអនឡាញ (Video Conference) ដោយភាគីកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះ។ កិច្ចព្រមព្រៀងនេះកំពុងស្ថិតក្នុងដំណាក់កាលនៃការចាប់ផ្តើម ចរចានៅឡើយ។

**ច. ប្រទេសមីយ៉ាន់ម៉ា**

កម្ពុជាធ្លាប់បានស្នើសុំជាផ្លូវការទៅកាន់ភាគីមីយ៉ាន់ម៉ាដើម្បីចាប់ផ្តើមកិច្ចចរចាលើកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នាតាំងពីឆ្នាំ២០១៥ មកម្ល៉េះ។ ប៉ុន្តែមកដល់ ពេលនេះពុំទាន់ទទួលបានការឆ្លើយតបជាវិជ្ជមាននៅឡើយទេ គឺភាគីទាំងពីរបានត្រឹមតែផ្លាស់ប្តូរ គំរូកិច្ចព្រមព្រៀងទ្វេភាគីស្តីពី

ការចៀសវាងការយកពន្ធត្រួតគ្នាទៅវិញទៅមកដើម្បីធ្វើការសិក្សាប៉ុណ្ណោះ។ កិច្ចព្រមព្រៀងនេះកំពុងស្ថិតក្នុងដំណាក់កាលនៃការចាប់ផ្តើមចរចានៅឡើយ។

**ឆ. ប្រទេសស្លូវ៉ាក**

តាមសំណើរបស់ប្រទេសស្លូវ៉ាក នៅក្នុងជំនួបពិភាក្សាការងាររវាង **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងឯកឧត្តម **PETER KAZIMIR ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីហិរញ្ញវត្ថុនៃសាធារណរដ្ឋស្លូវ៉ាក** កាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ប្រទេសកម្ពុជាបានឯកភាពជាគោលការណ៍ក្នុងការចាប់ផ្តើមចរចាលើកិច្ច ព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នាជាមួយប្រទេសស្លូវ៉ាក។ កិច្ចព្រមព្រៀងនេះ កំពុងស្ថិតក្នុងដំណាក់កាលនៃការស្នើសុំចាប់ផ្តើមចរចានៅឡើយ។

ជារួម ចាប់តាំងពីចាប់ផ្តើមដំណើរការចរចាលើកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការ យកពន្ធត្រួតគ្នា មករហូតដល់ឆ្នាំ២០២០នេះ មានកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការ យកពន្ធត្រួតគ្នាចំនួន៩ ដែលត្រូវបានបញ្ចប់ការចរចាជាស្ថាពរដូចបានបកស្រាយនៅខាងលើ ដែលក្នុងនោះមាន៦ប្រទេសយុត្តាធិការ គឺះ កម្ពុជា-សិង្ហបុរី កម្ពុជា-ចិន កម្ពុជា-ព្រុយណេ កម្ពុជា-ថៃ កម្ពុជា-វៀតណាម និងកម្ពុជា-រដ្ឋបាលពិសេសហុងកុង បានចូលជាធរមាន និងមានប្រសិទ្ធភាពអនុវត្តរួចរាល់ហើយ។ ចំណែកឯកិច្ចព្រមព្រៀងចំនួន៣ផ្សេងទៀត ដែលបានចុះហត្ថលេខា និងមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ គឺះ កម្ពុជា-ឥណ្ឌូនេស៊ី និងកម្ពុជា-ម៉ាឡេស៊ី ដោយឡែកកិច្ចព្រមព្រៀងទ្វេភាគីកម្ពុជា-កូរ៉េខាងត្បូងមានប្រសិទ្ធភាពអនុវត្តចាប់ ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២២។

កិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា ចំនួន៧ទៀតដែលបាន និងកំពុងស្ថិតក្នុងដំណាក់កាលនៃការចរចា គឺមានះ កម្ពុជា-ម៉ាកាវ កម្ពុជា-មីយ៉ាន់ម៉ា កម្ពុជា-ហ្វីលីពីន កម្ពុជា-ឡាវ កម្ពុជា-ជប៉ុន កម្ពុជា-ទួកគី និងកម្ពុជា-ស្លូវ៉ាក ហើយកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា ចំនួន២ផ្សេងទៀតគឺះ កម្ពុជា-កៀហ្ស៊ីស៊ីស្ថាន និងកម្ពុជា-រុស្ស៊ី កំពុងស្ថិតក្នុងដំណាក់កាលចាប់ផ្តើមនៃការចរចា។

ខ្លឹមសារនៃកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា ដែលបានចុះហត្ថលេខា ជាមួយប្រទេសទាំងអស់ខាងលើបានឆ្លុះបញ្ចាំងអំពីគោលការណ៍សំខាន់ៗនៃគោលនយោបាយពន្ធ អន្តរជាតិ និងបញ្ញត្តិស្តីពីពន្ធដាររបស់កម្ពុជា ដែលបានកំណត់តាមលំនាំគំរូ UN និងគំរូ ASEAN ដែលមានលក្ខណៈអំណោយផលដល់ប្រទេសកំពុងអភិវឌ្ឍន៍ដូចជាប្រទេសកម្ពុជាជាដើម។




| ឆ្នាំ | កំពុងចរចា | ចំនួនជុំនៃការចរចា | ចំនួនប្រទេស-យុត្តាធិការចុះហត្ថលេខា | កិច្ចព្រមព្រៀងមានប្រសិទ្ធភាពអនុវត្ត |
|---|---|---|---|---|
| 2014 | - | 1 | 0 | 0 |
| 2015 | - | 7 | 0 | 0 |
| 2016 | - | 9 | 2 | 0 |
| 2017 | - | 6 | 2 | 0 |
| 2018 | - | 5 | 2 | 2 |
| 2019 | - | 4 | 3 | 2 |
| 2020 | 7 | - | - | 4* |
| សរុប | 7 | 32 | 9 | 8 |





# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

ជាធម្មតាការវិភាគចំណុចខ្លាំង និងចំណុចខ្សោយលើការអនុវត្តការងារ ឬច្បាប់ដែលបានកំណត់តែងតែមាន។ ការវាយតម្លៃពិតជាមានសារៈសំខាន់ណាស់ ដើម្បីឱ្យយើងដឹងពីចំណុចខ្លាំងចំណុចខ្សោយសម្រាប់យកកែលម្អឱ្យកាន់តែល្អប្រសើរ និងកាន់តែច្បាស់លាស់ក្នុងការអនុវត្តជាក់ស្តែងក៏ដូចជាការគ្រប់គ្រងផងដែរ។ ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើកិច្ចព្រមព្រៀងទ្វេភាគីអន្តរជាតិ នៅអគ្គនាយកដ្ឋានពន្ធដារ ស្តីពីកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នាមក រួចមកខ្ញុំបាទបានរកឃើញនូវចំណុចខ្លាំង និងចំណុចខ្សោយ មួយចំនួនដូចជា៖

## ៤.១ ការវិភាគលើចំណុចខ្លាំង

ដោយសារតែការខិតខំប្រឹងប្រែងរបស់អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុក្នុងការកែទម្រង់គោលនយោបាយសារពើពន្ធ និងពង្រឹងអភិបាលកិច្ចល្អរបស់រដ្ឋ។

អគ្គនាយកដ្ឋានពន្ធដារ បានខិតខំយ៉ាងខ្លាំងក្នុងការធ្វើគំរូកិច្ចព្រមព្រៀងស្តីពីការយកពន្ធត្រួតគ្នាជាមួយនិងប្រទេសដែលមានទំនាក់ទំនងសេដ្ឋកិច្ចជាមួយប្រទេសកម្ពុជា ដើម្បីជំរុញការវិនិយោគិននៅកម្ពុជាឱ្យមានការរីកចម្រើន ក្នុងរយៈពេលវែង និងផ្តោតទៅនិវាសនជន និងអនិវាសនជនដែលមានសកម្មភាពអាជីវកម្មនៅក្នុងប្រទេស ឬដែនដីប្រភពដែលសកម្មភាពបង្កើតចំណូលជាក់ស្តែង ឬការទូទាត់កើតឡើង។

អគ្គនាយកដ្ឋានពន្ធដារក៏បានខិតខំទប់ស្កាត់ការគេចពន្ធ ការលួចបន្លំ ពន្ធ និងការឃុបឃិតគ្នា រវាងប្រទេសមួយទៅប្រទេសមួយទៀត ដោយអ្នកជាប់ពន្ធ ដោយដាក់ចេញនូវវិធានការតឹងរឹងផ្នែកផ្លូវច្បាប់ផងដែរ។

បង្ហាញពីផលប្រយោជន៍នៅពេលអ្នកជាប់ពន្ធបានដាក់ពាក្យស្នើសុំ និងភ្ជាប់ឯកសារត្រឹមត្រូវនិងគ្រប់ចំនួន ហើយត្រូវបានពិនិត្យឃើញថាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបានឥណទានពន្ធនៅកម្ពុជាពីពន្ធដែលបានបង់លើចំណូលនៅប្រភពបរទេស អគ្គនាយកដ្ឋានពន្ធដារនឹងចេញលិខិតជូនដំណឹងស្តីពីការបញ្ជាក់ឥណទានពន្ធអនុលោមតាម LOT និង DTA ក្នុងរយៈពេល១៤ថ្ងៃ។

នៅពេលដែលអគ្គនាយកដ្ឋានពន្ធដារចេញលិខិតជូនដំណឹងស្តីពីការបញ្ជាក់ឥណទានពន្ធអនុលោមតាម LOT និង DTA អ្នកជាប់ពន្ធនឹងទទួលបានសារជូនដំណឹង តាមរយៈទូរស័ព្ទដៃ ឬសារអេឡិចត្រូនិក។

**សម្រាប់ការស្នើសុំដំបូង៖** អត្ថប្រយោជន៍ក្រោម DTA នឹងមានប្រសិទ្ធភាពអនុវត្តគិតចាប់ពីថ្ងៃចុះហត្ថលេខាតទៅ រហូតដល់ដំណាច់ឆ្នាំជាប់ពន្ធចរន្ត។

**សម្រាប់ការស្នើសុំបន្ត៖** អត្ថប្រយោជន៍បន្តក្រោម DTA នឹងមានប្រសិទ្ធភាពអនុវត្តសម្រាប់រយៈពេលមួយឆ្នាំពេញដោយចាប់គិតពីថ្ងៃទី០១ ខែមករា នៃឆ្នាំជាប់ពន្ធចរន្ត ក្នុងករណីអ្នកជាប់ពន្ធទទួលបានការអនុញ្ញាតឱ្យបន្តអត្ថប្រ-យោជន៍ក្រោម DTA ពីអគ្គនាយកដ្ឋានពន្ធដារ។ ក្នុងករណីអ្នកជាប់ពន្ធពុំទាន់ទទួលបានការអនុញ្ញាតឱ្យបន្តអត្ថប្រយោជន៍ក្រោម DTA នេះអ្នកជាប់ពន្ធត្រូវអនុវត្តកាតព្វកិច្ចសារពើពន្ធតាមច្បាប់និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារជាធរមាន។

ចំណុចសំខាន់ៗរួមមាន៖

- លុបបំបាត់ការយកពន្ធត្រួតគ្នា

- លុបបំបាត់ឬកាត់បន្ថយពន្ធមួយចំនួនដែលនឹងត្រូវបង់ដោយវិនិយោគិនបរទេស
- លុបបំបាត់ការរើសអើងពន្ធ
- ផ្តល់វិធានច្បាស់លាស់លើការកំណត់សិទ្ធិយកពន្ធរវាងរដ្ឋភាគីនៃកិច្ចព្រមព្រៀង
- ផ្តល់ដំណោះស្រាយលើបញ្ហាការគេចវេះពន្ធ ការចៀសវាងពន្ធ និងការបន្ថយមូលដ្ឋានពន្ធ
- ផ្តល់ក្របខ័ណ្ឌក្នុងការដោះស្រាយវិវាទសារពើពន្ធ
- បង្កើនការវិនិយោគផ្ទាល់ពីបរទេស ដោយផ្តល់ភាពប្រាកដប្រជាដល់វិនិយោគិនបរទេស
- បង្កើនភាពប្រកួតប្រជែងអន្តរជាតិ។
- ផ្តល់នូវតល្លាភាព ចំពោះអ្នកជាប់ពន្ធ
- ដើម្បីទាក់ទាញ និងសម្រួលការវិនិយោគ និងពាណិជ្ជកម្មអន្តរជាតិ ព្រមទាំងទប់ស្កាត់ និងបង្ក្រាបការគេចវេះពន្ធ ការចៀសវាងពន្ធ, ទាំងក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ។

## ៤.២ វិភាគលើចំណុចខ្សោយ

ទន្ទឹមនឹងការរកឃើញចំណុចខ្លាំងមួយចំនួនខាងលើ ចំណុចខ្សោយទាំងនោះ មានដូចខាងក្រោមគឺ៖

- នៅក្នុងតំណាក់កាលនៃការអនុវត្តដំបូងអាចមានផលប៉ះពាល់ផ្ទាល់ដល់ចំណូលពន្ធរបស់ប្រទេសប្រភព ដោយសារការកាត់បន្ថយអត្រាពន្ធកាត់ទុក ដែលត្រូវអនុវត្តចំពោះអ្នកជាប់ពន្ធអនិវាសនជន និងការបែងចែកសិទ្ធិយកពន្ធលើប្រភេទប្រាក់ចំណូលមួយចំនួនឱ្យទៅប្រទេសនិវាសនដ្ឋាន
- មិនទាន់មានការលុបបំបាត់ការយកពន្ធត្រួតគ្នានៅឡើយទេ ដោយសារមិនទាន់បានចុះហត្ថលេខាជាមួយប្រទេសមួយចំនួន ដែលមិនបានចុះកិច្ចព្រមព្រៀង
- ហានិភ័យនៃការកេងចំណេញផលប្រយោជន៍ពី DTA និងការបង្វែរប្រាក់ចំណេញ
- នៅតែមានការរើសអើងពន្ធ ពីសំណាក់ប្រទេសដែលមានកិច្ចព្រមព្រៀង និងប្រទេសដែលកំពុងចរចា
- ផ្តល់វិធានច្បាស់លាស់លើការកំណត់សិទ្ធិយកពន្ធរវាងរដ្ឋភាគីនៃកិច្ចព្រមព្រៀង នៅមានកំរិតនៅឡើយ
- នៅកំពុងចរចាដំណោះស្រាយលើបញ្ហាការគេចវេះពន្ធ ការចៀសវាងពន្ធ និងការបន្ថយមូលដ្ឋានពន្ធ
- ផ្តល់ក្របខ័ណ្ឌក្នុងការដោះស្រាយវិវាទសារពើពន្ធ នៅមានកំរិត
- មិនទាន់មានភាពច្បាស់លាស់នៃការវិនិយោគផ្ទាល់ពីបរទេស និងមិនបានផ្តល់ភាពប្រាកដប្រជាដល់វិនិយោគិនបរទេស
- ដោយសារតែព្រះរាជាណាចក្រកម្ពុជាជាប្រទេសកំពុងអភិវឌ្ឍន៍ ភាពប្រកួតប្រជែងអន្តរជាតិយើងស្ថិតការប្រកួតជែងនៅឡើយទេ។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

សរុបមកអគ្គនាយកដ្ឋានពន្ធដារ បានរួមចំណែកយ៉ាងខ្លាំងក្នុងការអភិវឌ្ឍន៍ប្រទេសជាតិលើ គ្រប់វិស័យ។ រដ្ឋាភិបាលបានប្រមូលពន្ធ ដើម្បីយកប្រាក់ចំណូលសម្រាប់ចំណាយលើការគ្រប់គ្រងរដ្ឋ រួមទាំងសងបំណុលបរទេសផងដែរ។ ចំណូលពន្ធដារបានមកពីការបែងចែកប្រាក់ចំណូលរបស់អ្នកជាប់ពន្ធ ពោលគឺអ្នកមានចំណូលច្រើនត្រូវបង់ពន្ធច្រើន ចំណែកឯអ្នកមានចំណូលតិចត្រូវបង់ពន្ធតិច។

តាមរយៈការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះរួចមក យើងអាចសន្និដ្ឋានបានថា កិច្ចព្រមព្រៀងទ្វេភាគី គឺជាយុទ្ធសាស្ត្រដ៏សំខាន់មួយ ក្នុងការបង្កើនប្រសិទ្ធភាព ក្នុងការគោរព កាតព្វកិច្ចបង់ពន្ធ និងការជួយបង្កើនចំណូលចូលថវិកាជាតិ។ ទោះជាយ៉ាងណាក៏ដោយ ច្បាប់សារពើពន្ធ និងបទប្បញ្ញត្តិពាក់ព័ន្ធ គឺបានចែងមិនទាន់គ្រប់ជ្រុងជ្រោយនៅឡើយនោះទេ ពោលគឺនៅមាន ភាពខ្វះចន្លោះមួយចំនួនទៀតដែលត្រូវការបំពេញបន្ថែម។

សរុបមកក្នុងបរិបទ បច្ចុប្បន្ននេះការបំពេញកាតព្វកិច្ចពន្ធពីសំណាក់អ្នកជាប់ពន្ធកាន់តែប្រសើរឡើងពីមួយឆ្នាំ ទៅមួយ ឆ្នាំតាមរយៈការកែទម្រង់របស់អគ្គនាយកដ្ឋានពន្ធដារ ដោយបានបញ្ជ្រាបវប្បធម៌បង់ពន្ធឱ្យបាន ទូលំទូលាយ។ ចំណែកឯនីតិវិធីនៃការបង់ពន្ធត្រូវបានកែលម្អឡើងវិញ មន្ត្រីពន្ធក៏បានកែប្រែអត្តចរិករបស់ខ្លួនព្រមទាំងបានពង្រឹងសមត្ថភាពរបស់ខ្លួនឱ្យកាន់តែប្រសើរជាងមុន។

## ៥.២ ការផ្តល់អនុសាសន៍

បន្ទាប់ពីធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទ **កិច្ចព្រមព្រៀងស្តីពីចៀសវាងការយកពន្ធត្រួតគ្នា នៃអគ្គនាយកដ្ឋានពន្ធដារ** រួចមក ដើម្បីឱ្យការប្រមូលពន្ធ មានប្រសិទ្ធភាពខ្ពស់ យើងអាចផ្តល់នូវអនុសាសន៍មួយចំនួនដូចខាងក្រោម៖

- ផ្តល់ជាចំណេះដឹងពន្ធដារ បន្ថែមទៀត (ព្រោះអ្នកជាប់ពន្ធមួយចំនួនតូចនៅមិន ទាន់យល់ច្បាស់ អំពីកាតព្វកិច្ចរបស់ខ្លួន ជាហេតុធ្វើឱ្យមានការយល់ច្រឡំ ការមិនពេញចិត្ត និង ការគេចវេសមិនព្រមបង់ពន្ធ) តាមរយៈការបើកវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលា ស្តីពីពន្ធដារឱ្យច្បាស់លាស់បន្ថែមទៀត ដើម្បីឱ្យមន្ត្រីដកហូតពន្ធ និងប្រជាជនកាន់តែងាយ ស្រួល ក្នុងការអនុវត្តន៍ និងយល់ដឹងកាន់តែច្បាស់ជៀសវាងពេលបង់ពន្ធធ្វើពន្ធដារឱ្យមានការខុសឆ្គង
- សូមពង្រឹងសមត្ថភាពលើការប្រមូលពន្ធបន្ថែម ជៀសវាងការក្លែងបន្លំឯកសារផ្សេងៗរបស់ក្រុមហ៊ុនឬស្ថាប័នមួយចំនួន ដែលជាកត្តាធ្វើឱ្យមានភាពមិនស្មោះត្រង់ចំពោះការបង់ពន្ធ
- បន្ថែមចំណេះដឹងទាក់ទងនឹង ការប្រកាសពន្ធតាមអនឡាញ ដល់អ្នកជាប់បន្ថែមទៀត ដើម្បីឱ្យ អ្នកជាប់ពន្ធមានភាពងាយស្រួលក្នុងការបង់ពន្ធ ចំណេញពេលវេលា ពន្ធដារប្រមូលពន្ធបានឆាប់រហ័ស និងប្រសិទ្ធិភាពខ្ពស់។

# ឯកសារយោង


- ឯកសារយោង ឯកសារផ្សេងៗក្នុងបណ្ណាល័យនៃ វិទ្យាស្ថានវ៉ាន់ដា ទាក់ទងនឹងកិច្ចព្រមព្រៀងស្តីពីការចៀសវាងយកពន្ធត្រួតគ្នា
- ឯកសារវគ្គបណ្តុះបណ្តាលស្តីពី កិច្ចព្រមព្រៀងស្តីពីការយកពន្ធត្រួតគ្នា របស់អគ្គនាយកដ្ឋានពន្ធដារ
- ប្រកាសលេខ៣១៨សហវ.ប្រក ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១
- កំណែទម្រង់ពន្ធដារកម្ពុជា២០១៣-២០២០
- បណ្ណាល័យវិទ្យាស្ថាន វ៉ាន់ដា
- អគ្គនាយកដ្ឋានពន្ធដារ | ព្រឹត្តិបត្រពន្ធដារ (tax.gov.kh)
- ស៊ឹម សូលីនៈ Master of Business Administration
- https://www.tax.gov.kh/en
- http://cambotax.com/taxes-law/cambodia-taxes-law/
- https://opendevelopmentcambodia.net/km/tag/phnom-penh-tax- department/
- https://en.wikipedia.org/wiki/Tax
- clint.oconnell@dfdl.com
- https://www.ynn.com.kh/61357.html
- https;//www.ato.gov.au/General/Other-languages/In-detail/Khmer/Tax-and-super-in-Australia---what-you-need-to-know---Khmer/?page=2(10, December,2023)
- វិទ្យាស្ថានវ៉ាន់ដាៈ របាយការណ៍ស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី១៨ ទំព័រទី៤ របស់និស្សិតឈ្មោះ វ៉ែន រដ្ឋា
- អ្វីជានីតិ? ក្រម? ច្បាប់? 1.... - Law and social phally | Facebook (15.December.2023)
- ដកស្រង់ពីបណ្ណាល័យវិទ្យាស្ថានវ៉ាន់ដាៈ របាយការណ៍ស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី១៩ ទំព័រទី៥ របស់និស្សិតឈ្មោះ ជួន សៅវណ្ណា

# <u>ឧបសម្ព័ន្ធ</u>

## <u>រូបភាព ៖ ទាក់ទង់នៃការសាកសួរព័ត៌មាន</u>



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...០០១៩...........សហវ.ប្រក

ប្រកាស

ស្តីពី

ការដោះស្រាយបណ្តឹងតវ៉ាតាមនីតិវិធីនៃការព្រមព្រៀងទៅវិញទៅមក
ក្រោមកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ និងវិសោធនកម្មជាបន្តបន្ទាប់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៧/០២២ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើ÷ (១) កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone : (+855)23 890 666

# រូបភាព ៖ មេរៀនដែលទាក់ទងនឹងពន្ធ



**មេរៀនទី១**

## សញ្ញាណទូទៅនៃពន្ធដារ

I. **លក្ខណៈពិសេស នៃពន្ធដារ**

ផ្តើមចេញពីពេលដែលសង្គមមនុស្ស ត្រូវបានបែងចែកជាវណ្ណៈ មានការតស៊ូវណ្ណៈ និងមានការកើតឡើងនៃរដ្ឋាភិបាល ដើម្បីគ្រប់គ្រងវេទនាសម្ព័ន្ធនៃប្រទេសមួយ រហូតមកដល់បច្ចុប្បន្ន ពន្ធដារ ត្រូវបានគេអនុវត្តច្រើនបែបយ៉ាង ហើយកាន់តែទូលំទូលាយ ។

**ពន្ធដារគឺជាអ្វី**? What is taxation?

១. ពន្ធ គឺជារូបភាពនៃការបែងចែកឡើងវិញ នូវចំណូលជាតិ ដែលរដ្ឋាភិបាលបានប្រើប្រាស់ដើម្បីប្រមូលចំណូល មួយផ្នែកពីគ្រប់សមាសភាពសេដ្ឋកិច្ច ដូចជា ក្រុមហ៊ុន សហគ្រាស អាជីវកម្ម សិប្បកម្ម ពាណិជ្ជកម្ម...និងប្រជាពលរដ្ឋ ដើម្បីបម្រើឲ្យ តំរូវការរួមរបស់សង្គមជាតិទាំងមូល។

២. ពន្ធ គឺជារូបធាតុ នៃការប្រមូលចំណូលមួយ ដែលផ្សារភ្ជាប់ ជាមួយនិង សិទ្ធអំណាច នយោបាយរបស់រដ្ឋាភិបាល ដែលក្រឹត្យច្បាប់បើជាកំណត់ ។

៣. ពន្ធ គឺជាការបង់វិភាគទាននូវកាតព្វកិច្ច របស់គ្រប់សមាសភាពសេដ្ឋកិច្ច ដែលរួមទាំងរូបវន្តបុគ្គល និង និតិបុគ្គល ជូនរដ្ឋាភិបាលដែលមានច្បាប់កំណត់។

ពន្ធមានលក្ខណៈបង់ ហើយមិនសងឲ្យវិញផ្ទាល់ឡើយ ប៉ុន្តែនិងអាចសងឲ្យវិញជាលក្ខណៈរូបភាពប្រយោល ទៅតាមគោលនយោបាយរដ្ឋាភិបាលប្រទេសនីមួយៗ ។ គ្រប់អង្គភាពអាជីវកម្ម ផលិតកម្ម សេវាកម្ម ដែលចំណុះឲ្យគ្រប់សមាសភាពសេដ្ឋកិច្ច ត្រូវមានកាតព្វកិច្ច និងទំនួញខុសត្រូវ ចំពោះមុខច្បាប់រដ្ឋ ក្នុងការអនុវត្តឲ្យបានគ្រប់គ្រាន់ក្នុងខ្ទង់ពន្ធទាំងឡាយដែលបានកំណត់ ។ និងមានសិទ្ធស្មើៗគ្នា ក្នុងការទទួលមកវិញនូវផលប្រយោជន៍ ពីរដ្ឋាភិបាលដែលប្រកបដោយយុត្តិធម៌ និង ត្រូវបានរដ្ឋាភិបាលបង្គលក្ខណៈងាយស្រួលមកវិញតាមរយៈគោលនយោបាយ ដែលមានបែងចែកក្នុងច្បាប់ ។

ពន្ធបានធ្វើឲ្យមានការផ្លាស់ប្តូរកម្មសិទ្ធនៃប្រភពចំណូលដែលបានប្រមូល ។បន្លាស់ប្តូរកម្មសិទ្ធិនៃប្រភពចំណូលនេះបានកំណត់ដោយមុខងារគ្រប់គ្រងសេដ្ឋកិច្ចរបស់រដ្ឋាភិបាល ហើយបានស្តែងឡើងការឯកភាពគ្នា អំពីគោលចរិតផលប្រយោជន៍របស់រដ្ឋជាមួយ និងផលប្រយោជន៍ របស់ក្រុមហ៊ុនអាជីវកម្ម សេវាកម្ម និងប្រជាជនគ្រប់រូប។ នៅក្នុងឃឿនសេដ្ឋកិច្ចទីផ្សារ ដែលមានសមាសភាពសេដ្ឋកិច្ចច្រើនគោលនយោបាយពន្ធដារត្រូវយកមកប្រើប្រាស់ជាចាំបាច់ ជាទូទៅពន្ធត្រូវបានចាត់ទុកជា ឧបករណ៍ហិរញ្ញវត្ថុមួយយ៉ាងមានប្រសិទ្ធភាព ក្នុងការគ្រប់គ្រងសេដ្ឋកិច្ចហិរញ្ញវត្ថុរបស់រដ្ឋាភិបាល ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសជាតិ ។

II. **លក្ខខណ្ឌ សំណុមពរនៃពន្ធដារ**

**ក. ចំពោះការគ្រប់គ្រង**

ពន្ធដារ បានចូលរួមក្នុងការកែសំរួលឃឿនសេដ្ឋកិច្ចជាតិទាំងមូល ដែលបានគ្រប់គ្រងដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ធ្វើការណែនាំឧបត្ថម្ភចំពោះគ្រប់សមាសភាពសេដ្ឋកិច្ចដោយសារ មូលហេតុនេះហើយរដ្ឋាភិបាល មានលទ្ធិភាពគ្រប់គ្រាន់ និងចាំបាច់បែងចែកចំណូលមួយផ្នែក របស់បណ្តាគ្រប់សមាសភាពសេដ្ឋកិច្ច ក្នុងគោលបំណងអនុវត្តន៍នូវគោលដៅសេដ្ឋកិច្ចរបស់រដ្ឋាភិបាល ។

**ខ. ទំនាក់ទំនងរបស់ពន្ធដារ**

គឺជាទំនាក់ទំនងរវាងកាតព្វកិច្ច និងសិទ្ធអំណាចសង្គម ។ ប្រការនេះទៀមទារឲ្យគ្រប់សមាសភាព សេដ្ឋកិច្ច និងបុគ្គលមានកាតព្វកិច្ចចំពោះរដ្ឋាភិបាល ។ កាតព្វកិច្ចនោះនៅក្នុងទំនាក់ទំនងហិរញ្ញវត្ថុត្រូវបានអនុវត្តដោយមាត់ា បង់ភាគទានមួយផ្នែកប្រាក់ចំណូលដែលរាល់សកម្មភាពរបស់វាបានបង្កើតឡើង។

**គ. លក្ខខណ្ឌចាំបាច់ នៃពន្ធដារ**

លក្ខណៈសត្យានុម័តៈ ក្រៅពីប្រមូលចំណូលថវិការដ្ឋ ពន្ធគឺជាឧបករណ៍ដែលមានប្រសិទ្ធភាពក្នុងការណែនាំ ផលិតកម្ម អាជីវកម្ម សេវាកម្ម ។ បំណែងចែកការប្រើប្រាស់ រួមចំណែកឡើងវិញនូវបញ្ហាការផលិតកម្ម បញ្ហាការសមាសមាត្រចំណូលកាន់តែសមស្រប ។

លក្ខណៈអត្តនោម័តៈ អនុវត្តការទប់ស្កាត់ សម្របសម្រួលចំណូលរវាងបណ្តាស្រទាប់ប្រជាជនចុះល្មម ក្នុងការគ្រប់គ្រងសេដ្ឋកិច្ចទីផ្សារ គ្រប់គ្រងបញ្ជីការហិរញ្ញវត្ថុ ថវិការដ្ឋ ធ្វើឲ្យមានស្ថេរភាពថ្លៃ និង ចរាចរណ៍ហិរញ្ញវត្ថុ ។

**ឃ.អត្ថប្រយោជន៍ នៃពន្ធដារ**

ពន្ធដារមិនត្រឹមតែជាប្រភពចំណូលដ៏សំខាន់របស់ថវិការដ្ឋតែមួយមុខប៉ុណ្ណោះនោះទេ ប៉ុន្តែពន្ធដារបានផ្សាភ្ជាប់ជាមួយបញ្ហាទាំងឡាយអំពីការបង្កើនល្បឿនអភិវឌ្ឍសេដ្ឋកិច្ចអំពីសមាសភាពក្នុងការបែងចែកនិងស្ថេរភាពសង្គម។

ប្រសិនបើគោលនយោបាយពន្ធខុសឆ្គង អាចនាំឲ្យមានភាពអន់ថយដល់ល្បឿនសេដ្ឋកិច្ចសង្គម ផ្ទុយទៅវិញបើគោលនយោបាយពន្ធត្រឹមត្រូវ នាំឲ្យមានភាពរុងរឿងសំបូរ និងមានស្ថេរភាពយូរអង្វែងឲ្យប្រទេសជាតិយើង ។

III.**តួនាទីជាមូលដ្ឋានរបស់ពន្ធដារ**

ពន្ធដារមានតួនាទីជាមូលដ្ឋានដូចខាងក្រោម ៖

**១. បង្កើតប្រភពចំណូលថវិការដ្ឋ**

ឆ្លងតាមរយៈក្រិតច្បាប់នានា ច្បាប់សារពើពន្ធ ច្បាប់គ្រប់គ្រងហិរញ្ញវត្ថុ ស្តីអំពីកម្រិតកំណត់អត្រាពន្ធដែលក្រុមហ៊ុន សាជីវកម្ម សេវាកម្ម និង ប្រជាពលរដ្ឋ ដែលជាប់ពន្ធ ត្រូវបង់ពន្ធជូនរដ្ឋហើយប្រាក់នេះ ត្រូវបញ្ចូនចូលក្នុងថវិការដ្ឋ តាមរូបភាពជាក់ស្តែងផ្សេងៗគ្នា ។ នេះគឺជាតួនាទីសំខាន់ៗរបស់ពន្ធដារ ។ តួនាទីនេះចាប់ផ្តើមពីចំណុចពិសេសអំពីសិទ្ធអំណាចរបស់រដ្ឋាភិបាលក្នុងសង្គម ។ រដ្ឋាភិបាលបានប្រើប្រាស់ សិទ្ធអំណាចខាងរដ្ឋបាល បានដាក់ចេញនូវពន្ធដែលមានចែងបណ្តា ប្រភេទពន្ធ កម្រិតពន្ធ អត្រាពន្ធ ការណែនាំអនុវត្ត និងការកែសំរួលផ្សេងៗ។

ក្នុងគោលនយោបាយពន្ធរបស់រដ្ឋាភិបាលនៃបណ្តាប្រទេសភាគច្រើន ជាទូទៅបានដាក់ចេញនូវ សំណួមពរបីដែលត្រូវឆ្លើយតប ហើយរាល់ក្រិត្យច្បាប់ ច្បាប់សារពើពន្ធ ត្រូវតែតាមដានថ្លឹងថ្លែងជាប្រចាំដើម្បីឆ្លើយតបនូវសំណូមពរទាំងឡាយ ។

**ក.** សំណូមពរបង្កើតប្រភពចំណូលឲ្យថវិការដ្ឋ ត្រូវបានស្តែងឡើងនូវបរិមាណពន្ធ ដែលប្រមូលបាន និង លទ្ធភាពឆ្លើយតបរបស់វា រាល់តម្រូវការចំណាយរបស់រដ្ឋាភិបាល។

**ខ.** ដើម្បីបង្កើនប្រភពចំណូលថវិការដ្ឋ ត្រូវតែកសាងប្រព័ន្ធពន្ធមួយឲ្យបានសមស្រប គ្រប់ជ្រុងជ្រោយ ទៅតាមស្ថានភាពជាក់ស្តែងរបស់សេដ្ឋកិច្ចជាតិ និង ទៅតាមតំបន់សេដ្ឋកិច្ច ។

**គ.** ទន្ទឹមនោះ រដ្ឋាភិបាលត្រូវតែលើកកំពស់ប្រសិទ្ធភាពនៃប្រព័ន្ធក្បាលម៉ាស៊ីនគ្រប់គ្រង និងប្រមូលពន្ធប្រឆាំងនឹងការគេចពន្ធ លួចបន្លំពន្ធ ស៊ីសំណូកពុករលួយ និងការប្រមូលពន្ធមិនគ្រប់ជ្រុងជ្រោយ ។

**២. ជម្រុញបង្កើនល្បឿនអភិវឌ្ឍន៍សេដ្ឋកិច្ច ហិរញ្ញវត្ថុ**

ត្រូវបានស្តែងឡើង នូវការសាងប្រព័ន្ធសមស្របមួយ និងស្តែងឡើងនូវបណ្តាការអនុវត្តន៍ដ៏ប្រពៃរបស់ពន្ធដារ ។ នៅបណ្តាប្រទេសដែលកំពុងអភិវឌ្ឍន៍ និងអន់ថយមួយចំនួន ពីមុនក្នុងរយៈពេលដែលខិតខំលើកកម្ពស់អត្រាពន្ធនៃប្រភពមួយចំនួនដូចជា ៖ **អាករលើផលរបរ ពន្ធលើចំណូលបុគ្គលិក ពន្ធលើប្រាក់ចំណេញ អាករពិសេស**

**លើទំនិញ** និងសេវាមួយចំនួន...ប៉ុន្តែមិនបានយកចិត្តទុកដាក់ដល់ ប្រភេទពន្ធមួយចំនួនទៀតដូចជាៈ **ពន្ធលើធនធាន ពន្ធលើដីធ្លី**... ដែលនាំឲ្យមានការប្រើប្រាស់ធនធានពាសពេញ ឥតសណ្តាប់ធ្នាប់ និងខ្ជះខ្ជាយ ។ ឧទាហរណ៍ៈ ព្រៃឈើត្រូវបានគេកាប់បំផ្លាញ និងខ្ជះខ្ជាយ ធនធាន ហើយដែលជាហេតុបណ្តាលឲ្យវិនាសធនធានធម្មជាតិដែលជាសម្បត្តិរបស់រដ្ឋ និងអាចបណ្តាលឲ្យមានគ្រោះធម្មជាតិចំពោះប្រទេសជាតិ។

**៣. ទប់សម្រួលចំណូលរបស់ប្រជាពលរដ្ឋនៅក្នុងសង្គម**

-ពន្ធមានតួនាទីយ៉ាងសំខាន់ ក្នុងការរក្សាសមាមាត្ររវាងអ្នកមាននិងអ្នកក្រ កុំឲ្យឃ្លាតឆ្ងាយពីគ្នាពេក ។ មានន័យថា ពន្ធដារបានកាត់បន្ថយចំណូលរបស់អ្នកដែលមានទ្រព្យធនច្រើន និងបង្កើនប្រភពចំណូលថវិកា ដើម្បីធ្វើការបែងចែកឡើងវិញឲ្យអ្នកក្រីក្រ ដោយឆ្លងកាត់តាមគោលនយោបាយចំណាយរបស់រដ្ឋាភិបាល ។

-រវាងអាជីវករដែលមានទ្រព្យសម្បត្តិ និងចំណូលខ្ពស់ ជាមួយនិងពលរដ្ឋក្រីក្រ ក៏មានទំនាក់ទំនងចំណុះ ឲ្យគ្នា ដើម្បីមានស្ថេរភាពក្នុងសង្គម ។ មានន័យថា នៅពេលដែលមានព្រំដែនមួយនៃការបែងចែកឡើងវិញហើយដែលកម្រិតយល់ដឹងយ៉ាងច្បាស់របស់អាជីវករ នោះអាជីវករ ប្រជាពលរដ្ឋទាំងអស់បានត្រៀមជាស្រេច រួមវិភាគទានមួយផ្នែកចំណូលរបស់ខ្លួន ឲ្យរាល់សំណូមពររបស់សង្គម។ គេអាចកំណត់ក្របខណ្ឌព្រំដែននោះដោយ ឆ្លងកាត់តាមប្រតិកម្មរបស់បណ្តាអង្គភាពអាជីវកម្ម ផលិតកម្ម សិប្បកម្ម សេវាកម្មនីមួយៗ ។

ដើម្បីទប់សំរួលចំណូល និងការបែងចែកឡើងវិញនូវចំណូល រវាងបណ្តាលស្រទាប់វណ្ណៈផ្សេងៗគ្នានៅក្នុងសង្គម ជាទូទៅ រដ្ឋាភិបាលបានបង្កើតពន្ធប្រយោល ចំពោះប្រភេទទំនិញ ឬសេវាមួយចំនួន របស់មុខសញ្ញាណាដែលមានចំណូលខ្ពស់ ជំនួសឲ្យការយកពន្ធដោយផ្ទាល់ ។ វិធីសាស្ត្រនេះល្អក្នុងវិស័យគ្រប់គ្រង និងទាំងវិស័យចិត្តសាស្ត្រ ហើយងាយស្រួលនឹងបានទទួលស្គាល់ ។

IV. **បណ្តាកត្តារួមផ្សំរបស់ពន្ធ**

គោលនយោបាយពន្ធមួយរបស់រដ្ឋាភិបាល ជាទូទៅមានកត្តារួមផ្សំដូចខាងក្រោម៖

**១.បុគ្គលជាប់ពន្ធ**( TAX PAPER )

បុគ្គលជាប់ពន្ធគឺជារូបវន្តបុគ្គល( Natural person ) ឬ នីតិបុគ្គល( legal entities )ទាំងឡាយដែលបានកត់ត្រាចូលក្នុងបញ្ជី ផលិតកម្ម អាជីវកម្ម សេវាកម្ម...របស់រដ្ឋាភិបាល ហើយរាល់សកម្មភាពផ្សេងៗ ត្រូវបានរដ្ឋទទួលស្គាល់ជាសាធារណៈ និងបានកំណត់កាតព្វកិច្ចបង់ពន្ធ ជូនរដ្ឋាភិបាលទៅតាមការកំណត់របស់អង្គការពន្ធ។

-បុគ្គលជាប់ពន្ធគឺជាបុគ្គលដែលទទួលរងពន្ធដោយផ្ទាល់ និងមានកាតព្វកិច្ចត្រូវបង់ពន្ធដោយផ្ទាល់ទៅអង្គការពន្ធទៅតាមច្បាប់ដែលបានកំណត់។

-បុគ្គលទទួលរងពន្ធគឺជាបុគ្គលដែលមានចំណូល ហើយទទួលការជះឥទ្ធិពលដោយប្រយោលពីពន្ធ។

**២.មូលដ្ឋានគិតពន្ធ**( THE BASIS OF TAXES )

មូលដ្ឋានគិតពន្ធ គឺជាខ្ទង់ចំណូលទាំងឡាយដែលចំណុះឲ្យសកម្មភាព ផលិតកម្ម អាជីវកម្ម សេវាកម្ម សិប្បកម្ម ពាណិជ្ជកម្ម និងសកម្មភាពផ្សេងៗទៀត ដែលត្រូវបានចាត់ទុកជាមូលដ្ឋាន ដើម្បីគណនាពន្ធអាករ។ មូលដ្ឋានគិតពន្ធប្រែប្រួលទៅតាមប្រភេទពន្ធនីមួយៗ។

គេអាចកំណត់ប្រភេទពន្ធនីមួយៗ ផ្សេងៗគ្នា ដោយផ្អែកលើ មូលដ្ឋានគិតពន្ធខុសៗគ្នា។ ឧទាហរណ៍ៈ ពន្ធកសិកម្ម អាករលើផលរបរ ពន្ធលើប្រាក់ចំនេញ អាករពិសេសលើទំនិញ និងសេវាមួយចំនួន ពន្ធសត្តឃាត។

**៣.អត្រាពន្ធ**( TAX RATE )

អត្រាពន្ធគឺ ជាកម្រិតដែលកំណត់ទៅលើមូលដ្ឋានគិតពន្ធ ដើម្បីធ្វើជា បង្អែកក្នុងការគណនាប្រាក់ពន្ធអាករ។ អត្រាពន្ធ គឺជាកម្រិតដែលបានកំណត់ ត្រូវតែបង់ពន្ធជូនរដ្ឋាភិបាល នៅលើមួយឯកតាមូលដ្ឋានគិតពន្ធ។

អត្រាពន្ធចែកចេញជាច្រើនប្រភេទដូចជា:

ក. អត្រាពន្ធគិតតាមសមាមាត្រជាភាគរយ គឺជាអត្រាពន្ធ ប្រមូលតាមសមាមាត្រជាភាគរយ ទៅលើមូលដ្ឋានគិតពន្ធ នៃប្រភេទ ពន្ធនីមួយៗ ។

ខ. អត្រាពន្ធកំណើនតាមថ្នាក់ គឺជាអត្រាពន្ធដែលគណនាទៅតាមសមាមាត្រជាភាគរយ ហើយដែលកើនឡើងជាបន្តបន្ទាប់ ព្រមជាមួយនឹងការកើនឡើងនៃចំណូលជាប់ពន្ធ របស់បុគ្គលជាប់ពន្ធ។

គ. កម្រិតប្រមូលថេរ គឺជាកម្រិតប្រមូលថេរ ទៅលើឯកតាផលិតផលទំនិញ អចលនទ្រព្យផ្សេងៗ ដែលត្រូវជាប់ពន្ធ។

### ៤.ឯកតាគិតពន្ធ( THE UNIT OF TAX)

ឯកតាគិតពន្ធ គឺជាឯកតាដែលត្រូវបានប្រើប្រាស់ដើម្បីធ្វើជាមធ្យោបាយទូទាត់ពន្ធ។ យោងតាមប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រិតច្បាប់ និងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ ឯកតាគិត ពន្ធត្រូវបានគិតជាប្រាក់រៀល និងប្រាក់ដុល្លារ ប៉ុន្តែមានប្រទេសមួយចំនួនអាចគិតជា វត្ថុ ឧទាហរណ៍ គិតជាគីឡូក្រាម។

### ៥.តម្លៃគិតពន្ធ

តម្លៃគិតពន្ធគឺជាថ្លៃទីផ្សារ ឬថ្លៃ CIF(Cost Insurance and Freight) FOB(Free On Board) ដែលមានកត់ត្រានៅក្នុងកែីយប័ត្រ ដោយឆ្លងកាត់តាម SGS(Societe Generale de Surveillance) ឬជាតម្លៃដែល ត្រូវបានកំណត់ឡើងដោយ អង្គការគយ ចំពោះប្រភេទទំនិញ ដែលត្រូវបានអនុញ្ញាតិ ឲ្យ ធ្វើការនាំចេញ នាំចូលដោយឆ្លងកាត់តាមច្រកព្រំដែន។

តម្លៃគិតពន្ធ គឺជាថ្លៃទីផ្សារ ឬជាតម្លៃដែលកំណត់ដោយក្រសួងហិរញ្ញវត្ថុ ទៅលើទ្រព្យសម្បត្តិ ផលិតផលទំនិញ ឬសេវា និងមធ្យោបាយដឹកជញ្ជូន ដែលត្រូវជាប់ពន្ធ របស់បុគ្គលជាប់ពន្ធ។

### ៦.ការលើកពន្ធ( TAX EXEMPTION)

ការលើកលែងពន្ធ គឺជាការកំណត់ទាំងឡាយរបស់រដ្ឋាភិបាលដែលមានចែងក្នុងច្បាប់ អំពីករណីបង់ពន្ធដែលជាផលប្រយោជន៍ដល់បុគ្គលជាប់ពន្ធ។

-រាល់ករណីដែលត្រូវបានលើកលែងពន្ធទាំងស្រុង ឬក៏ត្រូវបានលើកលែងពន្ធមួយផ្នែក អាស្រ័យទៅតាមលក្ខណ:សម្បត្តិរបស់អាជីវកម្ម។

-ការលើកលែងពន្ធបានស្តែងតាមរយ:គោលនយោបាយរបស់រដ្ឋាភិបាល ចំពោះបុគ្គលជាប់ពន្ធ ដើម្បីលើកទឹកចិត្តដល់អ្នកវិនិយោគ ក្នុងស្រុក និងបរទេស ផលិតកម្ម អាជីវកម្ម សេវាកម្ម និង អនុវត្តនូវ សមភាពសង្គម។

### ៧.បែបបទបង់ពន្ធ

បែបបទបង់ពន្ធ គឺជាការកំណត់ទទួលខុសត្រូវជាធរមាន និងបែបផែននៃការបង់ពន្ធចូលថវិការដ្ឋ របស់បុគ្គលជាប់ពន្ធ។ គឺជាបែបបទ ធ្វើលិខិតប្រកាស ជូនទៅអង្គការពន្ធ តាមកាលកំណត់ នៃប្រភេទពន្ធនីមួយៗ និងជាវិធីសាស្រ្តប្រមូលប្រាក់ពន្ធ ដែលផ្សាភ្ជាប់ជាមួយក្របខណ្ឌនៃសិទ្ធអំណាច ការទទួលខុសត្រូវនៃស្ថាប័នទាំងឡាយ ដែលមានការពាក់ព័ន្ធ ។